២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៤២ ខែ កុម្ភៈ

ព.ស. ២៥១៣ គ.ស. ១៩៧០

-ភ្នំពេញ-

២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : លាង ហ័បអាន

និពន្ធនាយក-អ្នករៀបចំ : ពី ធាមតេង

គណៈកម្មការនិពន្ធ :

ព្រះមុនីកោសល សូរ-ហាយ

លោក លិម-លានជិន លោក ឌុក-តាម

លោក ជល-ធិត លោក ព្រួច-កុម

អ្នកស្រី ពេជ-សល់

# បញ្ជីរឿង

អត្ថបទ ទំព័រ

## ផ្នែកសាសនា

១— កើតទៀតឬទេ ? ព្រះវីរិយបណ្ឌិតោ ប៉ាង-ខាត់ រៀបរៀង . . . ១២៥

២— រឿងសុខសាមណេរ លោក ប៊ូ-ប៊ូ ប្រែរៀបរៀង . . . . ១៣៨

## ផ្នែកអក្សរសាស្ត្រ

៣— ល្បើកចចក ឧកញ៉ាសុត្ថរវោហារ ម៉ុក តែង សហ. លី-ធាមតេង ចម្លងផ្ទៀងផ្ទាត់ . . . . . . . . . ១៥៩

៤— រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . ១៩៤

៥— រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ អ្នកស្រីពេជ-សល់ ប្រែរៀបរៀង . . ២០៣

៦— រឿងខ្លី ៗ មានន័យវែង សហ. ឆិល-ទិត នៅក្រុមជំនុំព្រះត្រៃបិដករៀបរៀង ២១៤

## ផ្នែកកំណត់–ប្រវត្តិការណ៍

៧— វិជ្ជាអប់រំសុខភាពចំពោះព្រះសង្ឃ . . . . . . ២៣០

តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ៛

អាណត្តិសូមដាក់ថាៈ លោកនាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមួក ឲ្យធ្វើល្អទៅ,
ឲ្យផុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ។

— ព. ព —

# កើតទៀតឬទេ?

ព្រះមហាវីរិយបណ្ឌិតោ ម៉ា ង៉ - ខាត់ រៀបរៀង

## បទទីមួយ

## ដើមកំណើតកម្បូងនៃជីវិត

តាំងតែពីអតីតកាលកន្លងមកប៉ុន្មានឆ្នាំៗ កន្លងទៅយូរលង់ណាស់ហើយ ជីវិត "ការរស់នៅ" របស់មនុស្សសត្វនេះ ជាប្រស្នាមួយដែលគេចោទឡើងមុនគេបង្អស់ថា "អ្វីជាដើមកំណើតកម្បូងនៃជីវិត?" សំនួរនេះជាប្រស្នាចង្អៀតក្តីរបស់អ្នកគិតជាទាស់គ្នាៗ សព្វថ្ងៃ ចម្លើយប្រស្នានេះ សម្បត្តិគ្រប់សត្វទុកជាព្រោះមកព្រោះហើយក៏ដោយ គឺនៅតែមានអ្នកគិតនៅឡើយ ៗ មិនចេះចប់ទេ, ប្រស្នានេះ ជាចំណាប់ចិត្តគិតអ្នកគិតឡើយ ធ្វើឲ្យមានមនសិការៈជាប់ស្អិតនៅក្នុងចិត្តគ្រប់គ្នា តែតាំងអស់

គ្នា ទោះគេក្តី ទោះយើងក្តី ធ្វើឲ្យមានហេតុផលសមរម្យបានដោយលំបាកបំផុត ព្រោះតែពុំមានបញ្ញាចក្ខុនេះឯង ។

ដើម្បីជាការសិក្សា យើងគួរសើរើមើលទស្សនៈអ្នកគិតខ្លះទៅ ដែលគេបានផ្ចង់ចិត្តគិតចំពោះប្រស្នាចាក់ស្រេះនេះតាំងពីដើមទីមក ។ សម័យឧបនិស័ទ មុនសម័យពុទ្ធកាល ប្រមាណជា ៦០០ ឆ្នាំ យើងបានដឹងថាមានអ្នកប្រាជ្ញព្រាហ្មណ៍ច្រើននាក់ ដោយពិសេស លោកយជ្ញវល្ក្យៈបានបបួលគ្នាយកប្រស្នាជីវិតនេះមកត្រិះរិះដោះស្រាយ ។ សម័យឧបនិស័ទនេះ ព្រាហ្មណ៍អ្នកគិតទាំងឡាយ ដោះស្រាយថា ដើមកំណើតតម្រូវនៃជីវិតនេះ កើតចេញមកពី “ព្រហ្មន៍” ឬ បរមាត្មន៍” ប្រែថា “ព្រលឹងសាកលថេរនៅនិត្យ” គោលគឺ ព្រលឹងសាកលថេរនៅនិត្យនេះ ផ្សាយចេញពីប្រភពដើមរបស់ខ្លួនចេញទៅជា អាត្មន៍ “ព្រលឹង” មនុស្សសត្វឬអ្វីៗទៅទាំងអស់ ហើយអាត្មន៍=ព្រលឹងនេះ ចេះតែត្រាច់រង្គាត់ពីភពមួយទៅភពមួយទៀតៗ ទៅយូរអង្វែងណាស់ ក្នុងទីបំផុត ដោយការប្រតិបត្តិព្រហ្មចរិយធម៌គឺតបៈនិងយោគៈ អាត្មន៍=ព្រលឹងនេះ វិលទៅរលាយចូលជាមួយគ្នាក្នុងប្រភពដើមគឺ ព្រហ្មន៍=ព្រលឹងសាកលថេរនៅនិត្យរបស់ខ្លួនវិញ ដូចមានសេចក្តីពន្យល់បែងទុកក្នុងគម្ពីរឧបនិស័ទថា :

« ក្រពេញទឹក ពុះពុលកើតឡើងពីទឹក ទីបំផុត ក៏បែកធ្លាយហើយ រលាយចូលជាមួយគ្នាជាទឹកវិញ » ។

ចម្លើយទី១នេះ ពីរោះស្ដាប់ដែរ តែបើគន់គិតមើលឲ្យល្អិតតទៅ ឃើញថា ពុំមានហេតុផលសមរម្យគួរទុកជាការពិតបានទេ ។

មើលព្រាហ្មណ៍ហើយ, ឥឡូវ ទៅមើលលទ្ធិសាសនាគ្រិស្ដផង ។ លទ្ធិសាសនាគ្រិស្ដនេះ, តាមមើល, វិតខំពន្យល់ពីជីវិតមនុស្សណាស់ដែរ តែគេដើរទៅតាមតែគម្ពីរជាបន្ទាត់ព្រះអាទិទេព ដែលលោកបានប្រទានទុកមក មិនដើរចេញពីបន្ទាត់ដើម ហើយព្រមដើររកតាមច្បាប់ហេតុផលឡើយ ។ គេនិយាយថា(១) " លោកនេះ ព្រះអាទិទេពសាងចេញមកពី សភាពសូន្យ" =(Néant) ហើយថែមនិយាយពីមនុស្ស ក៏ថា(២) ព្រះអាទិទេពសាងមនុស្ស ឲ្យដូចជារូបព្រះអង្គ " គឺបង្កើតឲ្យមានព្រលឹងមិនស្លាប់ "=(Âme immortelle) មានចិត្ត មានប្រាជ្ញាចេះពិចារណា ។ គម្ពីរជំនាន់ក្រោយ មានសេចក្ដីប្រហែលគ្នាដែរ គឺមានសេចក្ដីថា " ដោយអំណាចជំនឿ យើងដឹងថា ពិភពលោកនេះ ព្រះអាទិទេពសាងដោយព្រះទស្សចិត្ត ហើយអ្វីៗ គ្រប់យ៉ាងដែលយើងមើលឃើញ សុទ្ធតែកើតចេញពីសភាពសូន្យទាំងអស់ " ។

ចម្លើយលទ្ធិសាសនាគ្រិស្ដនេះទៀត ក៏នៅតែក្នុងងងឹត មិនមានហេតុផលសមរម្យយកជាគតិបានដែរ ។

---

១ – Le Monde a été créé par Dieu du Néent ( 2 Maschab. 7, 28 )

២ – Dieu créé l'homme à son image ( Gem. 1, 26 )

បែរទៅមើលទស្សនៈអ្នកគិតក្នុងបច្ចុប្បន្នកាលនេះ ដោយពិសេស លោក ឝូប៉េនហាវែរ (Shopenhauer) ដែលជាអ្នកប្រាជ្ញមានកេរ្តិ៍ឈ្មោះប្រ-សើរម្នាក់ លោកបានស្តីពីប្រស្នាដើមកំណើតដំបូងនៃជីវិតនេះថា(១) ៗ

បើប្រសិនជាគេត្រិះរិះគិតឃើញថា "ខ្លួនឯងបានកើតចេញមកពីភាពសូន្យទទេ" ក៏គួរគិតទៀតថា "ខ្លួនឯងត្រូវតែវិលត្រឡប់ទៅកាន់ភាពសូន្យទទេនោះ" វិញដែរ ព្រោះថា "អាទិភាពថេរនៅនិច្ច" ដែលបានប្រព្រឹត្តកន្លងទៅមុនពេលដែលខ្លួនបានកើតមកហើយនោះ មិនមែនឬ? រួចមក មានភាពថេរនៅនិច្ចទីពីរចាប់ផ្តើមកើតឡើងបន្តទៅទៀត ហើយដោយមានភាពថេរនៅនិច្ចទីពីរនេះ មិនមានការឈប់សោះ ដើម្បីកើតមានភាពថេរនៅនិច្ចតទៅទៀត មិនចេះចប់" ។ បញ្ចប់ប្រយោគនេះហើយ លោកប៉េនឝូហាវែរញ្ញាក់ថា :

"គំនិតនេះ ដូចជាគំនិតគិតហួសប្រមាណពេក"

ហើយលោកបន្តសេចក្តីទៅទៀតថា :

"បើគេយល់ឃើញថា កំណើតគឺជាតិ មានកំណត់ខាងដើមបំផុតពិតមែន, សេចក្តីស្លាប់គឺមរណៈក៏ត្រូវតែមានកំណត់ខាងចុងបំផុតពិតមែនដែរ, ហើយបើគេសន្មតថា មនុស្សកើតឡើងមកពីភាពសូន្យទទេ, គំនិត

១— THE WORLD AS WILL AND IDEA

យល់នេះ ក៏ជាហេតុនាំឲ្យមានសន្ទូតទៀតថា ស្លាប់គឺមរណៈ ក៏ជាទានចុងបំផុតរបស់គេដែរ" ។

មួយទៀត តាមគោលទ្រឹស្តីនៃទេវវិទ្យា គេយល់ថា: "មនុស្សកើតឡើងឯកឯងតាមធម្មជាតិ មិនមានចេតនាជាធម៌នាំឲ្យកើតទេ តែក្នុងពេលដែលកើតក្លាយ ។ មនុស្សនោះឯង ដែលទទឹងបានទៅជាល្អឬអាក្រក់ ក៏បានដោយអំណាចកិច្ចសក្តិសិទ្ធិ "ព្រះអាទិទេព" បណ្តាលឲ្យដែរ ។ ដូច្នេះហើយ មនុស្សមានល្អ មានអាក្រក់ មានកុសល អកុសល បានប្រសើរ ឬទៅជាជាតិបាប ស្រេចហើយតែព្រះអាទិទេពលិខិតឲ្យស្រេចតែម្តង ចាប់តាំងពីដើមតម្បូងនៃការកើតឡើង មានរូបរហូតស្លាប់ទៅវិញ អស់ខ្យល់ពេញចូលជាទីបំផុត ពុំមែនអាស្រ័យដោយចំណង់ខ្លួនតែបំណងខ្លួន ឬព្យាយាមធ្វើ ឬកិច្ចការស្វ្រូបទន្រ្ទន់នៃបុគ្គលម្នាក់ ៗ ឡើយ" ។ សេចក្តីខាងលើនេះ ជាទស្សនៈជាតិកុសលនៃទេវវិទ្យា ។ នេះជាចម្លើយពីបាកស្លាប់ដែរ ។

មួយវិញទៀត ក្នុងលទ្ធិសាសនាគ្រិស្តដែល មានពាក្យស្តីថា "មនុស្សទាំងអស់សុទ្ធតែមានបាប ជាមត៌កកើតមកពីមនុស្សដើមគឺអាដាំ (Adam) ។ ពាក្យនេះផ្ទុយស្រឡះពីច្បាប់យុត្តិធម៌ ច្បាប់មេត្តា ករុណាទៀត ។ ពិចារណាមើលសត្វត្រូវពីបុព្វហេតុដែលស្តីថា "អ្វីទាំងអស់សុទ្ធតែកើតមកពីភាពឬឡេទទេ" ក្នុងលទ្ធិសាសនាគ្រិស្តនេះ ឃើញថា

គំនិតនេះ មិនខុសគ្នាពីបុព្វហេតុដែលស្តីថា អាត្មន៍=ព្រហ្មន៍ ដែលនិយាយថា កើតចេញមកពីព្រហ្មន៍ក្នុងលទ្ធិសាសនាព្រាហ្មណ៍ដែរ ។ មើលគ្រប់ជ្រុងទៅនាំឲ្យយល់ថា " គំនិតមួយចេញមកពីគំនិតមួយទៀតពិត " ។

យើងបានដើរសិក្សា មើលតាមលទ្ធិសាសនានិងទ្រឹស្តីធំ ៗ ដែលសម្តែងយោបល់របស់ខ្លួនទុកមក, ទ្រឹស្តីទាំងនេះ មានសារៈគួរឲ្យចង់ចេះដឹង គួរឲ្យសិក្សាឲ្យចេះដឹងពិតដែរ តែយើងនឹកស្តាយថា សេចក្តីដែលយើងលើកយកមកជាគ្រឿងនិរូបន៍នេះ ជាអត្ថបទសង្ខេបពេក មិនពិស្តារអស់ជើងដៃ តែទោះម្តេចម្តា កំគង់បានជាពន្លឺកូនទៀនតូចមួយគ្រាន់ជួយបំភ្លឺមើលដែរ ។ តទៅ ដើម្បីឲ្យការសិក្សាយើងមានវិសាលភាពបរិបូណ៌បន្តិច យើងគួរចូលទៅសិក្សាវិជ្ជាបច្ចុប្បន្ន ដែលស្តីពីដើមកំណើតមនុស្សសត្វ ដោយពិសេស យើងសិក្សាមនុស្សវិទ្យា-សាស្ត្រមើលទៅទៀត ។

វិទ្យាសាស្ត្រទំនើប ជាវិជ្ជាប្រើហេតុផលដោយត្រង់ មិនពាក់ព័ន្ធដោយជំនឿលទ្ធិសាសនាទេ ជាវិជ្ជាសេរី មិនប្រកាន់យកលទ្ធិសាសនាឬ មនុស្សៈអ្នកណាមួយដោយចំពោះទេ ជាវិជ្ជាពឹងផ្អែកតែទៅលើមតិទូទៅ ហើយខំព្យាយាមដោះស្រាយប្រស្នា ដែលកោតឡើងដោយវិចារ-ណញ្ញាណ និងដោយប្រាជ្ញាជាំរបស់មនុស្សពិត ៗ ។ តើប្រស្នាល្អិតសុខុមរបស់យើង អាចដោះស្រាយបានដោយវិទ្យាសាស្ត្រនេះដែរឬទេ ?

ចំពោះប្រស្នានេះ តើវិទ្យាសាស្ត្រឆ្លើយថាដូចម្តេច ? វិទ្យាសាស្ត្រឆ្លើយតាមបែបវិទ្យាសាស្ត្រថា :

"យើងកើតមកពី សុក្កកោសិកា (Sperm) និង អណ្ឌកោសិកា (Ovum Cells) ដោយការរួមសង្វាសនៃមាតាបិតារបស់យើង" ។

នេះជាចម្លើយដ៏ខ្លីរបស់វិទ្យាសាស្ត្រ ជាចម្លើយមិនទាន់សមហេតុផលអស់ជើង ព្រោះមិនបានគិតដល់ធម៌ដែលជាគូ មនៈ ឬ ចិត្ត ដែលជាធម៌មានសារៈសំខាន់បំផុត ជាងម៉ាស៊ីនពោលគឺរូបកាយមនុស្សនោះទៅទៀត គឺថាៈវិទ្យាសាស្ត្រនិយាយត្រឹមតែរូបកាយ មិននិយាយពីអ្វីដែលមាននៅក្នុងរូបកាយឡើយ ។

បំណែកឯអ្នកវត្ថុនិយម ត្រង់ចំណុចដែលនិយាយថា "ជីវិតទាំងអស់ សុទ្ធតែកើតមកពីជីវិត" =(Omne vivume vivo) នេះ គេជឿថា "ជីវិតនិងមនៈ ឬ ចិត្ត ជាធម៌វិវឌ្ឍន៍ជាប់គ្នាពីអជីវៈ" ។ ដោយអ្នកវត្ថុនិយមមានសេចក្តីយល់ដូច្នេះហើយ បានជាគេពោលថា "មនុស្សកើតក៏កើតមកឯង ហើយស្លាប់ទៅ មិនមានបុណ្យ មិនមានបាប មិនមានកាយកម្ម វចីកម្ម មនោកម្ម ដែលឲ្យផលទៅជាវិបាកទេ" ។

យើងបានមើលទស្សនៈអ្នកគិត គ្រប់លទ្ធិគ្រប់មតិហើយ យើងយល់ថាចម្លើយទាំងអស់នេះ ដោះស្រាយប្រស្នារបស់យើង មិនទាន់អស់ជើងទេ ។ តទៅ យើងមើលទស្សនៈតាមពុទ្ធសាសនា តើព្រះសម្ពុទ្ធទ្រង់

ត្រាស់ថាដូចម្ដេច ចំពោះប្រស្នាដែលយើងបានដណ្ដឹងសួរទុកថា " ដើមកំណើតតម្បូងនៃជីវិត " នោះ តើដូចម្ដេច ?

ដើម្បីឆ្លើយតបប្រស្នានេះ, មុនតម្បូង យើងគួរយល់ថា ព្រះសម្ពុទ្ធទ្រង់ពុំបានយកព្រះទ័យទុកដាក់ ចំពោះដើមកំណើត និងផលចុងបំផុតនៃជីវិតនេះ ទាល់តែសោះ ព្រោះការប្រើគំនិតឲ្យខំសួរស្វែងតាមរកធម៌ទាំងអស់បែបនេះ មិនមានប្រយោជន៍សោះទេ ។ សេចក្ដីនេះ យើងបានឃើញនៅក្នុងមាលុង្ក្យសូត្រច្បាស់ស្រេចហើយ ។ ព្រះអង្គពុំព្រមព្យាករទេ ដោយទ្រង់យល់ថា ប្រស្នាបែបនេះ មិនមែនជាប្រស្នាត្រូវដោះស្រាយភ្លាមទេ, ឯប្រស្នាដែលត្រូវដោះស្រាយភ្លាមៗនោះ គឺប្រស្នា " ទុក្ខ " ។ ទុក្ខគ្រប់ប្រការ ដែលយើងកំពុងរងគ្រោះសព្វថ្ងៃនេះ ទើបជាប្រស្នាប្រញាប់ប្រញាល់ ត្រូវដោះស្រាយភ្លាមៗ ឆាប់ៗបំផុត ដូចសេចក្ដីសង្ខេបពុទ្ធភាសិតតទៅនេះ (១)

" មាលុង្ក្យបុត្ត ! ការប្រព្រឹត្តព្រហ្មចរិយធម៌ មិនពឹងផ្អែកទៅលើទិដ្ឋិនេះទេ ការដែលត្រូវធ្វើភ្លាមៗ គឺប្រស្នាទុក្ខដែលកំពុងដុតសត្វឲ្យឆេះក្ដៅក្រហាយរោលរាល ស្ទន់ស្មោ អន្ទះសាដាច់ទ្រូងរាល់ថ្ងៃ, អ្វីទៅ គឺ ជាតិ ជរា ព្យាធិ មរណៈ សោក បរិទេវ ទុក្ខ ទោមនស្ស ឧបាយាស,

១ សុត្តន្តបិដកភាគ ១៤ មជ្ឈិមនិកាយ សីលក្ខន្ធវគ្គ ចូឡមាលុង្ក្យសូត្រ ទំព័រ ១១៤ មានមតិអ្នកវត្តនិយមប្លែកៗ គួរមើល ។

ធម៌តាំងនេះ ជាប្រស្នាបន្ទាន់ ត្រូវដោះស្រាយភ្លាមៗ បង្អង់ទុកយូរទៅទៀតពុំបានទេ ។

"មាលុង្ក្យបុត្ត ! ចូរអ្នកចាំទុកចុះថា នេះជាធម៌ដែលតថាគតត្រូវសម្តែង ដូចតថាគតបានសម្តែងរួចហើយ ។ ឯធម៌ដែលតថាគតមិនសម្តែងនោះគឺ :

១ លោក ទៀង

២– លោក មិនទៀង

៣– លោក មានទីបំផុត

៤– លោក មិនមានទីបំផុត

៥– ជីវិត គឺសរីរៈ

៦– ជីវិតផ្សេង សរីរៈផ្សេង

៧– សត្វស្លាប់ហើយ កើតទៀត

៨– សត្វស្លាប់ហើយ មិនកើតទៀត

៩– សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន

១០– សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។

ហេតុអ្វីក៏តថាគតមិនសម្តែងទិដ្ឋិការយល់ឃើញនោះ ?

"មាលុង្ក្យបុត្ត ! មុនជាតថាគតមិនសម្តែង ព្រោះទិដ្ឋិនេះមិនមាន

ប្រយោជន៍ មិនមែនជាការចាំបាច់ មិនមែនជាខាងដើមព្រហ្មចរិយធម៌ មិនមែននាំឲ្យកើតក្ដីនឿយណាយ ការប្រាសចាករាគៈ ការរលត់ទុក្ខ ការស្ងប់ ការដឹងច្បាស់ ការត្រាស់ដឹង និព្វាន ឡើយ" ។

"មាលុង្ក្យបុត្ត! តថាគតតែងសម្ដែងថា នេះទុក្ខ នេះហេតុនាំឲ្យកើតទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះបដិបទាជាផ្លូវនាំទៅកាន់ការរំលត់ទុក្ខ" ។

ហេតុអ្វីក៏តថាគតសម្ដែងប្រាប់ធម៌នេះ?

"មាលុង្ក្យបុត្ត! ព្រោះថាធម៌ទាំងនេះ មានប្រយោជន៍សំខាន់ណាស់ ចាំបាច់ណាស់ ជាខាងដើមនៃព្រហ្មចរិយធម៌ នាំឲ្យកើតក្ដីនឿយណាយ ប្រាសចាករាគៈ រំលត់ទុក្ខ ស្ងប់ ដឹងច្បាស់ ត្រាស់ដឹង និព្វាន" ។

នេះជាពុទ្ធដីកា ។ ដូច្នេះ ពុទ្ធសាសនាមិនបង្រៀនវិជ្ជាសម្រាប់តែពន្យល់ប្រស្នាគ្រប់ប្រការ សីលធម៌ក្ដី ទស្សនវិជ្ជាក្ដី ដែលមនុស្សលោកជួញចិត្តគិតឲ្យអស់ដែងនោះទេ ។ ពុទ្ធសាសនាមិនព្រមស្ដីសោះ នូវមតិឬទ្រឹស្ដីឥតប្រយោជន៍ ដែលជាធម៌មិននាំឲ្យកើតសេចក្ដីសុខចម្រុងចម្រើននោះទេ ។ ពុទ្ធសាសនា មិនបង្ខំពុទ្ធសាសនិកជនឲ្យមានជំនឿចំពោះដើមកំណើតនៃជីវិតនោះទេ ។ ពុទ្ធសាសនា ជាមាគ៌ានាំទៅកាន់ការរួចស្រឡះចេញពីចំណងគ្រប់ប្រការ ដែលហៅថា "មោក្ខធម៌" ឬជាមាគ៌ានាំទៅឲ្យបានយល់ច្បាស់នូវចតុរារិយសច្ច ។ ពុទ្ធសាសនា មាន

គោលដៅយ៉ាងប្រត្យក្សច្បាស់លាស់ ដោយពិសេស គោលដៅអវសាន គឺ "ការរំលត់ទុក្ខគ្រប់ប្រការ" ។

ហើយៈដោយមានគោលដៅជាក់លាក់ប្រាកដនេះ គេអាចកម្ចាត់បង់ចោលនូវឧបក្កិលេសទាំងអស់បានអស់ដើង, មិនតែប៉ុណ្ណឹងទេ វីរិយភាពទាំងអស់ដែលយើងបានបំពេញ មានអានុភាពខ្លាំងក្លាពិសេស អាចជូនយើងឲ្យដើរទៅដល់ការយល់ពិតតាមពិត ដែលជាប្រស្នាសុខុមគម្ភីរភាពដែលពោទឡើងខាងលើនេះបានទៀត ។ ដោយសារចេះដឹងត្រឹមត្រូវតាមគន្លងធម៌ ឬ ដោយការសម្រេចសេរីភាពបរិបូណ៌ចេញពីចំណងពោលគឺទុក្ខនេះស្រេចហើយ យើងម្នាក់ ៗ មិនបាច់ខ្វល់អំពល់អ្វី ចំពោះប្រស្នាដើមកំណើតនៃជីវិតនេះទៀតឡើយ ។

ឧបមាថា យើងចេះដឹងថា "ក" ជាដើមកំណើតទៅចុះ, តើការដឹងបែបនេះ អាចជូនយើងឲ្យចូលទៅជិតគោលបំណងអវសាននៃទុក្ខបានដែរឬទេ ? មួយទៀត វិជ្ជាដែលយើងចង់ចេះដឹងបែបនេះ ប៉េនឹងប្រៀបធៀប ប្រៀបដូចកុមារតូច ៗ ដែលមើលឃើញអ្វី ៗ កើតក្ដីឆ្ងល់ ហើយសួរផុកថា នុ៎ះហៅអ្វីឪ ? ប្រសិនបើលទ្ធិសាសនាទាំងឡាយ (ពាហិរសាសនា) និងវិទ្យាសាស្ត្រ អាចបង្រៀនមនុស្សលោកឲ្យចេះដឹងកំណើតជីវិតពិតមែនក៏ដោយ ពុទ្ធសាសនានៅតែមានហេតុផលសមរម្យ

ទ្រង់ពោលថា[១] :

“ភិក្ខុទាំងឡាយ! សង្សារនេះ មិនមានទីបំផុតខាងដើម ដែលមនុស្សអាចកំណត់បានទេ ។ ទីបំផុតខាងដើមនៃសត្វទាំងឡាយ ដែលបិទបាំងដោយអវិជ្ជា ព្រមទាំងជាប់ដោយគ្រឿងចងគឺតណ្ហា ហើយអន្ទោលទៅវិញទៅមកនេះ ទ្រង់ស្ដីបញ្ជាក់មិនបានទេ” ។

សេចក្ដីខាងលើនេះ ដូចជាទ្រង់បញ្ជាក់ប្រាប់អ្នកចង់សប្បាយចំស្ទុះស្វែងរកដើមកំណើតនៃជីវិត កុំឲ្យដេញរវល់ឡើយ ដោយព្រះតម្រាស់ថា: “កុំឡើយ យុវជនទាំងឡាយ! កុំដេញរវល់ធ្វើអ្វី ឥតប្រយោជន៍ទេ ដើមកំណើតខាងដើមនោះ មិនមានដើមកំណើតខាងដើមក្នុងអតីតកាលទេ ។ ជីវិតនេះមិនមែនជា “ភាពមានស្ថាពរ” របស់កាយទេ គ្រាន់តែជាការហូរទៅ ដូចជាការហូរទៅនៃខ្សែទឹកក៏ដូច្នោះឯង ” សេចក្ដីពិត ជីវិតជាការហូរទៅមិនចេះដាច់ ឬជាថាមពលដូចជាថាមពលអគ្គិសនី ជាធម៌តែងតែមានអតីតកាលដែលមិនមានទីបំផុតខាងដើមសោះទេ ។ ទោះបើមនុស្សកើតពីស្វានៅលើដើមឈើ ឬកើតលើផែនដី ដោយការសាងព្រះអាទិទេព ឬព្រះព្រហ្មក៏ដោយ សុទ្ធតែគេចមិនរួចពីធម៌គឺ ជាតិជរា ព្យាធិ មរណៈ ទុក្ខ សោក ដែរ ក្នុងកាលដែលខ្លួនអន្ទោលទៅ

១— អនមតគ្គោយំ ភិក្ខវេ សង្សារោ ។ បុព្វាកោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសំយោជនានំ សន្ធាវតំ ។

អស់កាលជាយូរលង់ ។ ដូច្នេះ គួរស្វែងរកដើមកំណើតសង្ខារ ជាការមានប្រយោជន៍ដល់សត្វលោកទាំងមូល ប្រសើរជាង, យើងគួរប្រើវិរិយភាពដ៏មានតម្លៃរបស់យើងគ្រប់គ្នា ដើម្បីចម្លងក្រសែជីវិតឲ្យបានទៅដល់ជិតសិវដ្ឋាន មិនមានទុក្ខសោកគឺនិព្វានវិញ ។

អ្នកផ្ញួរវល់គិតពីទ្រឹស្តី "ដើមកំណើតខាងដើមនៃជីវិត" នេះ ដើម្បីទេសនាប្រោសសត្វឲ្យរួចពីទុក្ខ, ការទេសនានេះ នឹងទៅជាអសារបង់ឥតប្រយោជន៍ទទេ មិនទុះសពីសេចក្តីយល់ពុទ្ធសាសនាឡើយ ។ អ្នកផ្ញួចិត្តគិត "ជីវិតមានទីបំផុតខាងដើម ទៅក្នុងអតីតកាល ដែលមិនមានទីបំផុត" នេះ គេបង់និយាយថា "ទីបំផុតខាងដើមនោះ មិនគឺអ្វីដទៃទេ គឺព្រះអាទិទេពដែលសាងពិភពលោកនេះឯង" ទេដឹង ?

បើគេយល់ថា អាទិទេព សាងពិភពលោក ពិតមែន ក៏គួរតែគេបេះទឹកឆ្លើយខ្លួនវិញផង ហើយគេទៅដណ្តឹងសួរខ្លួនឯងថា "ចុះបើព្រះអាទិទេពជាអ្នកសាងពិភពលោក តើលោកណា សាងព្រះអង្គ ? ឯដើមកំណើតខាងដើមព្រះអង្គនោះ មកពីណា ? ម្តេចឡើយ ក៏គេមិនឃើញទៅឆ្លើយសួរគ្នាផង ?

# រឿងសុខសាមណេរ

អដ្ឋកថាធម្មបទ ទណ្ឌវគ្គទី ១០ ភាគទី ៥

លោក ប៊ូ - ប៉ូ រៀបរៀង

---

កាលព្រះបរមសាស្តាគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនឹងសុខសាមណេរ ត្រាស់សម្តែងធម៌ដោយបទគាថា ថា ឧទកំ ហិ នយន្តិ នេត្តិកា ដូច្នេះជាដើម ។

សេចក្តីពិស្តារថា: ក្នុងអតីតកាល មានបុត្ររបស់សេដ្ឋីអ្នកនគរពារាណសីម្នាក់ ឈ្មោះថា គន្ធកុមារ ។ កាលបិតារបស់កុមារនោះក្ស័យជីវិតទៅហើយ ព្រះរាជាត្រាស់ឲ្យហៅកុមារនោះចូលមកគាល់ ទ្រង់លួងលោម ហើយប្រោសព្រះរាជទានតំណែងសេដ្ឋីដល់ គន្ធកុមារនោះ ដោយគ្រឿងសក្ការៈដ៏ច្រើន ។ ចាប់ដើមអំពីកាលនោះមក កុមារនោះ មាននាមប្រាកដថា គន្ធសេដ្ឋី ។ គ្រានោះ អ្នករក្សាឃ្លាំងរបស់សេដ្ឋី គឺបើកទ្វារឃ្លាំងទ្រព្យ យកចេញមក រួចប្រាប់ថា លោកម្ចាស់! ទ្រព្យប៉ុណ្ណេះនេះជារបស់បិតាលោកម្ចាស់ ទ្រព្យប៉ុណ្ណេះនេះជារបស់បុព្វបុរសមានជីតាជាដើម ។ សេដ្ឋីសម្លឹងមើលគំនរទ្រព្យនោះហើយនិយាយថា អើ! លោកទាំងនោះមិនយកទ្រព្យនេះទៅជាមួយផងទេឬ ។ បពិត្រលោកម្ចាស់! ធម្មតាមនុស្សដែលស្លាប់ហើយ យកទ្រព្យទៅជាមួយខ្លួន

ផង តុំដែលមានទេ, ដ្បិតថា ពួកសត្វដែលស្លាប់ រមែងនាំយកទៅផងបាននោះ ចំពោះតែកុសលនិងអកុសល ដែលខ្លួនធ្វើទុកហើយប៉ុណ្ណោះ ។

សេដ្ឋីគិតថា "លោកទាំងនោះ សន្សំប្រមូលទ្រព្យទុក ហើយស្លាប់ទៅលទៅ ព្រោះខ្លួនជាមនុស្សល្ងង់ខ្លៅ, ចំណែកអញ នឹងកាន់យកទ្រព្យនេះទៅជាមួយខ្លួនផងឲ្យបាន", កាលដែលសេដ្ឋីគិតយ៉ាងនេះ ក៏មិនមែនគិតថា "អញនឹងឲ្យទានឬនឹងធ្វើការបូជា" ទេបែរជាគិតថា "អញនឹងចាយវាយទ្រព្យទាំងនេះឲ្យទាល់តែអស់រលីង ហើយសឹមស្លាប់ទៅចុះ" ។ សេដ្ឋីចំណាយប្រាក់មួយសែនឲ្យជាងធ្វើបន្ទប់សម្រាប់ងូតទឹកដែលសម្រេចទៅដោយកែវផ្លេក, ចំណាយប្រាក់មួយសែន ឲ្យជាងធ្វើផែនក្ដារសម្រាប់ងូតទឹកដែលសម្រេចទៅដោយកែវផ្លេកដែរ, ចំណាយប្រាក់មួយសែន ឲ្យជាងធ្វើបល្ល័ង្កសម្រាប់អង្គុយ, ចំណាយប្រាក់មួយសែន ឲ្យជាងធ្វើថាសសម្រាប់ដាក់ភោជន, ចំណាយប្រាក់មួយសែន ឲ្យជាងធ្វើមណ្ឌបក្នុងទីបរិភោគ, ចំណាយប្រាក់មួយសែន ឲ្យជាងធ្វើតុសម្រាប់ទ្រថាសភោជន, ឲ្យជាងធ្វើសីហបញ្ជរនៅទីផ្ទះ ដោយប្រាក់មួយសែនដូចគ្នា, បានចំណាយប្រាក់មួយពាន់ទៀត ដើម្បីឲ្យធ្វើអាហារព្រឹកសម្រាប់ខ្លួន, បានចំណាយមួយពាន់ទៀតឲ្យធ្វើអាហារល្ងាចសម្រាប់ខ្លួន, ប៉ុន្តែ ក្នុងថ្ងៃពេញបូណ៌មីកល់ខែ ឲ្យចំណាយប្រាក់មួយសែនទៀត ដើម្បីតាក់តែងធ្វើភោជន,

ពល់ក្នុងថ្ងៃបរិភោគនោះ ឲ្យចំណាយប្រាក់មួយសែនរៀលស្អិតស្អាងនគរ ហើយប្រើមនុស្សឲ្យវាយស្គរត្រាច់ទៅប្រកាសថា សូមជូនជាដំណឹង ។ មហាជន ចូរនាំគ្នាទៅមើលលំនាំអាការបរិភោគភត្តរបស់គន្ធសេដ្ឋី ៗ មហាជន ក៏តែងចូលមកមើលប្រជ្រៀតគ្នា បងគ្រែតម្រួតលើគ្រែ ៗ ចំណែកគន្ធសេដ្ឋី នោះ អង្គុយលើផែនក្តារដ៏មានតម្លៃមួយសែន ក្នុងបន្ទប់សម្រាប់ងូតទឹកមានតម្លៃមួយសែន, ងូតទឹកក្រអូប ៩០ ក្អម, បើកសីហបញ្ជរនោះ ហើយអង្គុយលើបល្ល័ង្ក ៗ ទើបពួកអ្នកបម្រើលើកថាសមកដាក់លើតុសម្រាប់ទ្រ ហើយជូនភោជនមានតម្លៃមួយសែន ជូនសេដ្ឋីនោះ ៗ មានពួកស្រីច្រៀងរាំចោមរោម ហើយបរិភោគភត្តនោះ ដោយសម្បត្តិបែបនេះឯង ៗ

សម័យតមកទៀត មានមនុស្សអ្នកស្រុកក្រៅម្នាក់ ដុកឧសជាដើមក្នុងរទេះតូចរបស់ខ្លួន ដើម្បីទៅដូរយកស្បៀងសម្រាប់ខ្លួន, លុះទៅដល់នគរហើយ ក៏ឈប់សម្នាក់នៅទីផ្ទះសំឡាញ់ ៗ ក៏វេលានោះ ជាថ្ងៃពេញបូណ៌មី ៗ គេដើរវាយស្គរប្រកាសក្នុងនគរថា ចូរមើលលំនាំអាការបរិភោគរបស់គន្ធសេដ្ឋី ៗ ទើបសំឡាញ់ប្រាប់អ្នកដំណើរមកពីស្រុកក្រៅនោះថា សំឡាញ់ ។ លំនាំអាការបរិភោគរបស់គន្ធសេដ្ឋី អ្នកឯង ធ្លាប់ឃើញដែរឬទេ ៗ ខ្ញុំមិនធ្លាប់ឃើញទេ សំឡាញ់ ៗ បើដូច្នោះមកសំឡាញ់ យើងទាំងទៅមើល, ស្គរនេះ គេតែងវាយប្រកាសប្រាប់ក្នុង

នគរ, យើងនឹងឃើញមហាសម្បត្តិ ។ អ្នកនគរ ក៏នាំអ្នកស្រុកក្រៅ
នោះទៅមើល ។ ឯមហាជន ក៏ឡើងត្រែតូចនិងត្រែធំមើល ។ អ្នក
ស្រុកក្រៅ គ្រាន់តែជុំកូនកត្តក្ងាម ក៏និយាយនឹងអ្នកនគរថា យើងចង់
បរិភោគកត្តកូងថាសន្ធុះណាស់ ។- កុំប្រាថ្នាកត្តនោះឡើយ សំឡាញ់!
យើងមិនអាចបានបរិភោគទេ ។- កាលបើមិនបានទេ, ខ្ញុំក៏មិនរស់
ទៀយសំឡាញ់! ។ អ្នកនគរ កាលបើហាមឃាត់អ្នកស្រុកក្រៅនោះ
មិនបានហើយ ក៏ឈរនៅខាងក្រោយបំផុតចរសែវស្រែកដោយសម្លេង
យ៉ាងខ្លាំងថា លោកម្ចាស់អើយ! ខ្ញុំសូមសំពះលោកម្ចាស់ ។
កត្តុះសេដ្ឋីសួរថា នុះនរណា ។ ខ្ញុំម្ចាស់អានប្រោស ។ ចុះឯង
មានការអ្វី ។- អ្នកស្រុកក្រៅម្នាក់នេះ ចង់បរិភោគជុំកត្តកូងថាស
របស់លោក, សូមលោកមេត្តាឲ្យនឹងជុំកត្តបន្តិចមក ។- អ្នកឯងមិន
អាចនឹងម្ទេះនឹងបានទេ ។- អ្នកឯងបានព្រះភក្ត្ររបស់លោកសេដ្ឋីហើយឬទេ?
សម្លាញ់ ។ ខ្ញុំបានឮហើយ សម្លាញ់! ប៉ុន្តែ កាលបើបាន ទើបខ្ញុំនៅ
រស់, បើមិនបានទេ ខ្ញុំមុខជាស្លាប់មិនខានឡើយ ។ អ្នកនគរស្រែក
ទៀតថា បពិត្រលោកម្ចាស់អើយ! បានឮថា អ្នកស្រុកក្រៅនោះ កាល
បើមិនបានបាយនេះបរិភោគទេ មុខជាដាច់ខ្យល់ស្លាប់មិនខាន, សូមទាន
លោកម្ចាស់មេត្តាឲ្យជីវិតដល់គ្នាផងទៅ ។- នែអ្នក! ជម្មតាបាយមួយជុំ
ថ្ងៃមួយរយរៀលក៏មាន ពីររយរៀលក៏មាន, កាលបើចេះឲ្យដល់អ្នកមក

សូមគ្រប់គ្នាទៅ, តែយើងនឹងបានអ៊ីបរិភោគ ។ - លោកម្ចាស់អើយ! អ្នកស្រុកក្រៅនេះ បើមិនបានបាយនេះទេ មុខជាស្លាប់ហើយ សូមលោកម្ចាស់ឲ្យជីវិតដល់គ្នាផង ។ - យើងឲ្យបាយទៅឯងទទេ ៗ មិនបានទេ, បើអ្នកឯង សុខចិត្តស៊ីឈ្នួលធ្វើការក្នុងផ្ទះយើងចំនួនបីឆ្នាំ, ហើយយើងនឹងឲ្យបាយដល់អ្នកឯងមួយថាសបាន ។ អ្នកស្រុកក្រៅឮដូច្នោះហើយ ក៏ប្រាប់សំឡាញ់ថា "បើដូច្នឹង, ខ្ញុំទទួលបានសំឡាញ់!" ហើយក៏លះបង់កូនប្រពន្ធចោល ទៅនៅផ្ទះលោកសេដ្ឋី ដោយតាំងចិត្តថា នឹងធ្វើការឈ្នួលរហូតគ្រប់បីឆ្នាំ ដើម្បីឲ្យបានបាយមួយថាស ។ កាលបុរសនោះធ្វើការឈ្នួល ក៏បានធ្វើកិច្ចការទាំងពួងដោយរៀបរយ ។ ការងារដែលនឹងត្រូវធ្វើក្នុងផ្ទះ ក្នុងព្រៃ ឬក្នុងទីវាលក្រើ ប្រាកដជាបុរសនោះធ្វើបានទាំងអស់ ។ បុរសនោះ មហាជនហៅថា កត្តិកតិកា: គឺអ្នកធ្វើការឈ្នួលគ្រោះគត្ត ហើយល្បីឈ្មោះទៅ ពេញទាំងនគរ ។ តមកថ្ងៃរបស់កត្តកតិកា: គ្រប់បរិបូណ៌ហើយ, អ្នកចាត់ការគត្ត ក៏ជម្រាបលោកសេដ្ឋីថា លោកម្ចាស់, ថ្ងៃរបស់កត្តកតិកា:គ្រប់បរិបូណ៌ហើយ, គាត់ធ្វើការឈ្នួលរហូតដល់បីឆ្នាំ ពប់ថា ធ្វើការងារដែលធ្វើបានសែនក្រ, សូម្បីការងារមួយយ៉ាង ក៏គាត់ធ្វើមិនដែលឲ្យមានសៅហ្មងឡើយ ។ ទើបលោកសេដ្ឋីបង្គាប់ឲ្យចំណាយប្រាក់បីពាន់រៀល ឲ្យបុរសស៊ីឈ្នួលនោះ គឺពីពាន់រៀល ឲ្យធ្វើអាហារល្ងាចនិងអាហារព្រឹករបស់ខ្លួន, មួយពាន់

រៀល ឲ្យធ្វើអាហារព្រឹករបស់បុរសឈ្នួលនោះ ហើយបង្គាប់ថា "ថ្ងៃនេះ ពួកអ្នក ចូរធ្វើការបម្រើបុរសឈ្នួលនោះ ឲ្យដូចជាបម្រើយើងចុះ" លុះបង្គាប់ស្រេចហើយ ក៏ប្រាប់មនុស្សក្នុងផ្ទះទាំងអស់ សល់តែភរិយាជាទីស្រឡាញ់ឈ្មោះនាងចិន្តាមណីម្នាក់ប៉ុណ្ណោះ ថា "ថ្ងៃនេះ ពួកឯង ចូរចោមរោមបុរសឈ្នួលនោះចុះ" រួចហើយ ក៏ប្រគល់សម្បត្តិគ្រប់មុខឲ្យបុរសឈ្នួលនោះ ។ កត្តុកតិកៈចូលទៅអង្គុយលើផែនក្តារកង់ចន្ទប់នោះឯង ហើយផ្លូតទឹកដែលសេដ្ឋីទុកសម្រាប់ផ្លូត, ផណ្តាប់សំពត់សាដកដែលសេដ្ឋីទុកសម្រាប់ផណ្តាប់, អង្គុយលើបល្ល័ង្ករបស់សេដ្ឋី ។ លោកសេដ្ឋី ក៏ប្រើបម្រើឲ្យវាយស្គរដើរប្រកាសពេញនគរថា កត្តុកតិកៈធ្វើការឈ្នួលរៀតដល់គ្រប់កំណត់បីឆ្នាំ ក្នុងផ្ទះរបស់ គន្ធសេដ្ឋី ហើយបានគត្តមួយចាស, មហាជន ចូរមកមើលសម្បត្តិនៃការបរិភោគរបស់កត្តុកតិកៈនោះ ។ មហាជន ក៏មកប្រជុំគ្នា បានឡើងលើគ្រែតូចខ្ពង់គ្រែធំមើល ។ គ្រប់ទីឋានដែលកត្តុកតិកៈក្រឡេកមើល ។ បានដល់នូវអាការញាប់ញ័រ ។

ពួកអ្នកបម្រើបានឈរហែរចោមរោមជុំវិញកត្តុកតិកៈ បុរសនោះ ។ ពួកអ្នកក្រែ ក៏លើកចានភក្ត យកមកដាក់ខាងមុខ កត្តុកតិកៈ ។ នៅវេលាដែល កត្តុកតិកៈ លាងដៃដើម្បីនឹងបាយអាហារបរិភោគ ស្រាប់តែទាំងព្រះបច្ចេកពុទ្ធមួយព្រះអង្គនៅក្នុងគន្ធមាទន៍ ដែលចេញពាក

សមាបត្តិក្នុងថ្ងៃទីប្រាំពីរ ពិចារណាមើលថា “ តើក្នុងថ្ងៃនេះ អញទៅដើម្បីប្រយោជន៍ភិក្ខាចារនៅទីណាហ្ន៎ ? ” ក៏បានឃើញ កត្តកតិកៈ ។ ទើបព្រះបច្ចេកពុទ្ធនោះពិចារណាមើលតទៅទៀតថា “ បុរសនោះ ធ្វើការឈ្នួលទាល់តែគ្រប់កំណត់បីឆ្នាំ ទើបបានគោមួយថាស, តើសទ្ធារបស់បុរសនេះ មានឬពុំមានទេ ” ជ្រាបថា “ មាន ”, ទើបគិតថា “ ជនចំពួកខ្លះ សូម្បីមានសទ្ធាហើយ តែមិនអាចធ្វើការសង្គ្រោះក៏មានដែរ, ឯបុរសនេះនឹងអាចដើម្បីធ្វើការសង្គ្រោះដល់អាត្មាបានដែរឬទេ ” ហើយជ្រាបថា “នឹងអាចធ្វើបាន, អាស្រ័យហេតុនៃការសង្គ្រោះដល់អាត្មានេះមុខជាគាត់នឹងបានសម្បត្តិធំ” ទើបលោកស្រង់ចីវរកាន់បាត្រហោះឡើងកាន់វេហាស៍ ទៅតាមចន្លោះបំពេង បង្ហាញខ្លួននៅចំមុខកត្តកតិកៈនោះមួយរំពេច ។ កត្តកតិកៈ ឃើញព្រះបច្ចេកពុទ្ធហើយគិតថា “ អញបានធ្វើការឈ្នួលក្នុងផ្ទះគេដទៃ រហូតដល់គ្រប់កំណត់បីឆ្នាំ ដើម្បីឲ្យបានគោមួយសម្រាប់ខ្លួន ព្រោះតែអញមិនបានឲ្យទានក្នុងកាលមុន, គោរបស់អញនេះ អាចរក្សាអញបានត្រឹមយប់មួយនឹងថ្ងៃមួយ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ, បើប្រសិនអញថ្វាយគោនេះដល់ព្រះបច្ចេកពុទ្ធហើយ បុញ្ញកោដ្ឋាសៈ គឺចំណែកផលបុណ្យ នឹងរក្សាអញបានច្រើនពាន់កោដិកប្ប, អញនឹងថ្វាយគោនេះដល់ព្រះបច្ចេកពុទ្ធប្រសើរជាង”, កត្តកតិកៈ គិតដូច្នេះហើយ មិនយកបាយ សូម្បីតែ

មួយដុំអំពីថាសដែលខ្លួនធ្វើការឈ្នួលអស់បីខែទើបបាននោះ ពុំមកងមាត់ឡើយ, ទំកម្លាំតំបំណាំងចេញបាន ហើយលើកថាសឡើងដោយខ្លួនឯង កាន់ដើរទៅជិតព្រះបច្ចេកពុទ្ធ រួចឲ្យថាសទៅអ្នកដទៃកាន់ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយកាន់ថាសដោយដៃឆ្វេង ដួសភត្តដាក់ចូលក្នុងបាត្រព្រះបច្ចេកពុទ្ធដោយដៃស្តាំ ។ ក្នុងវេលាដែលភត្តនៅសល់ពាក់កណ្តាល ព្រះបច្ចេកពុទ្ធយកដៃបិទបាត្រ ។ លំដាប់នោះ គហបតិទុគ្គតៈ ទូលលោកថា ព្រះករុណាម្ចាស់ ! ភត្តនេះល្មមតែមួយចំណែកប៉ុណ្ណោះ, ខ្ញុំមិនចែកឲ្យជាពីរចំណែកទេ, សូមលោកម្ចាស់កុំសង្គ្រោះខ្ញុំក្នុងលោកនេះឡើយ, សូមសង្គ្រោះក្នុងបរលោកវិញចុះ, ខ្ញុំមិនឲ្យទានឲ្យមានចំណែកនៅសេសទេ, ខ្ញុំសូមប្រគេន មិនឲ្យនៅសេសសល់ឡើយ ។ មែនពិត, ទានដែលបុគ្គលមិនទុកឲ្យសល់ដើម្បីខ្លួនសូម្បីតែបន្តិច គឺឲ្យទាល់តែអស់ ឈ្មោះថា ទានមិនមានចំណែកសេសសល់, ទាននេះ រមែងមានផលច្រើន ។

គហបតិទុគ្គតៈនោះ ធ្វើទានបូជាដោយភត្តទាល់តែអស់ រួចទើបលើកដៃប្រណម្យទូលទៀតថា បពិត្រព្រះករុណាម្ចាស់ ! ខ្ញុំធ្វើការឈ្នួលក្នុងផ្ទះអ្នកដទៃអស់បីឆ្នាំ ដោយទុក្ខលំបាកមកហើយ ព្រោះតែអាស្រ័យភត្តមួយថាស, តទៅនេះ, ខ្ញុំសូមឲ្យតែមានសេចក្តីសុខ ក្នុងទីដែលខ្ញុំកើតហើយទៀត, ខ្ញុំសូមឲ្យជាអ្នកមានចំណែកនៃធម៌ដែល

លោកម្ចាស់ឃើញហើយនោះផង ។ ព្រះបច្ចេកពុទ្ធទទួលថា សេចក្តីប្រាថ្នាដែលអ្នកតាំងទុកហើយយ៉ាងនេះ ចូរឲ្យបានសម្រេច, សេចក្តីត្រិះរិះតាំងឡាយ ចូរឲ្យបានសម្រេច, វត្ថុគ្រប់មុខ ដែលបុគ្គលគប្បីប្រាថ្នា ចូរបរិបូណ៌ដល់អ្នក ដូចកែវចិន្តាមណី និងដូចព្រះចន្ទពេញវង់ ដូច្នោះចុះ ។ ព្រះបច្ចេកពុទ្ធ ធ្វើអនុមោទនាគាថា :

ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ
សព្វេ បូរេន្តុ សង្កប្បា ចន្ទោ បណ្ណរសោ យថា
ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ
សព្វេ បូរេន្តុ សង្កប្បា មណិ ជោតិរសោ យថា

សូមឲ្យរបស់ដែលអ្នកប្រាថ្នាហើយ និងរបស់ដែលអ្នកតាំងចិត្តទុកហើយសម្រេចដល់អ្នក ដោយឆាប់រហ័ស, សូមសេចក្តីត្រិះរិះតាំងអស់ពេញដល់អ្នក ដូចព្រះចន្ទដ៏គំរប់ ១៥ កើតដូច្នោះចុះ; សូមរបស់ដែលអ្នកប្រាថ្នាហើយ និងរបស់ដែលអ្នកតាំងទុកចិត្តហើយ សម្រេចដល់អ្នក ដោយឆាប់រហ័ស, សូមសេចក្តីត្រិះរិះតាំងអស់ពេញដល់អ្នក ដូចកែវមណីជោតិរសដូច្នោះចុះ ។

ចប់ហើយ ទើបលោកអធិដ្ឋានថា "សូមឲ្យមហាជនទាំងនេះមើលឃើញអត្ថហេតុលុះកាលទៅដល់ភ្នំគន្ធមាទន៍ ចុះ" ហើយក៏បានហោះ

ទៅកាន់ភ្នំគន្ធមាទន៍ តាមអាកាស ។ ចំណែកមហាជន ក៏បានឈរសម្លឹងមើលទៅលោកទាំងអស់គ្នា ។ លោកទៅដល់ភ្នំគន្ធមាទន៍ហើយ បានចែកបិណ្ឌបាតនោះ ឲ្យដល់ព្រះបច្ចេកពុទ្ធទាំងប្រាំរយអង្គ ។ ព្រះបច្ចេកពុទ្ធទាំងអស់ ទទួលយកបិណ្ឌបាតត្រឹមតែល្មមផ្គត់រៀងខ្លួន ៗ ។ បុគ្គលមិនគួរគិតថា "បិណ្ឌបាតតែបន្តិចសោះ ម្ដេចក៏ចែកគ្រប់ព្រះបច្ចេកពុទ្ធប្រាំរយអង្គបាន" ដូច្នេះទេ ។ ដ្បិតថា ព្រះមានព្រះភាគ ក៏បានត្រាស់ហេតុដែលមិនគួរគិត ៤ យ៉ាងទុកហើយ, ក្នុងហេតុដែលមិនគួរគិត ៤ យ៉ាងនោះ ចំពោះហេតុដែលបិណ្ឌបាតតែបន្តិចសោះ ទៅជាចែកបានគ្រប់ ដល់ព្រះបច្ចេកពុទ្ធប្រាំរយអង្គនេះ គឺជាវិស័យរបស់ព្រះបច្ចេកពុទ្ធ ។

មហាជន បានឃើញបិណ្ឌបាតដែលព្រះបច្ចេកពុទ្ធអង្គនោះបែងចែកឲ្យដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ញុំាងពាន់នៃសាធុការឲ្យប្រព្រឹត្តទៅហើយ សម្លេងសាធុការនោះ បីដូចជាសម្លេងនៃរន្ទះ ។ គន្ធសេដ្ឋី បានឮសម្លេងសាធុការនោះហើយ គិតថា ភត្តភិក្ខា: ប្រហែលជាទ្រង់មិនអាចទ្រទ្រង់សម្បត្តិដែលអញឲ្យហើយបានទេ បានជាមហាជននេះស្រែកចំអកឡកឡឺយបន្ទឺលាន់ឮឡើងដូច្នេះ ។ លោក គន្ធសេដ្ឋី បានប្រើពួកអ្នកបម្រើទៅសួរឲ្យដឹងប្រវត្តិហេតុនោះ ។ អ្នកបម្រើត្រឡប់មកជម្រាបវិញថា "បពិត្រលោកម្ចាស់! ធម្មតាបុគ្គលអ្នកទ្រទ្រង់សម្បត្តិទុកបាន រមែងជាអ្នកយ៉ាងនេះ" រួចជម្រាបប្រវត្តិហេតុនោះសព្វគ្រប់ ។

សេដ្ឋីឮដូច្នោះ ក៏មានសរីរកាយតឹបតិមានពណ៌ប្រាំពាល់ត្រូវហើយ គិតថា "យីអើ! កត្តកត្តិកា:នេះ ធ្វើកម្មដែលគេធ្វើបានដោយកម្រណាស់, អញស្ថិតនៅក្នុងសម្បត្តិថែបនេះ អស់កាលយូរប៉ុណ្ណោះ ក៏មិនដែលបានឲ្យអ្នកៗជាគេឡើយ" គិតរួចក៏ឲ្យហៅបុរសនោះចូលមកជួបសួរថា "ឮដំណឹងថា អ្នកឯងធ្វើកម្មដូច្នេះមែនឬទេ?", កាលបុរសនោះឆ្លើយថា "មែនហើយ លោកម្ចាស់!", ក៏និយាយថា "បើដូច្នោះ អ្នកឯងចូរទទួលយកប្រាក់មួយពាន់រៀលនេះ ហើយចូរឲ្យចំណែកផលបុណ្យក្នុងទានរបស់អ្នកឯងមកដល់ខ្ញុំផង" ។ កត្តកត្តិកា: ក៏ព្រមចែកចំណែកបុណ្យតាមពាក្យសេដ្ឋីសូម ។ ឯលោកសេដ្ឋី ក៏បានចែងចែកសម្បត្តិរបស់ខ្លួនទាំងអស់ ឲ្យបុរសឈ្នួលនោះពាក់កណ្ដាល ។

ក៏ធម្មតា សម្បទា មាន ៤ គឺ វត្ថុសម្បទា ១ បច្ច័យ-សម្បទា ១ ចេតនាសម្បទា ១ គុណាតិរេកសម្បទា ១ ។ បណ្ដាសម្បទាទាំង ៤ នោះ ព្រះអរហន្តក្តី ព្រះអនាគាមីក្តី ដែលគួរដល់និរោធសមាបត្តិបាន ចាត់ជាទក្ខិណេយ្យបុគ្គល ឈ្មោះថា វត្ថុសម្បទា (សម្បត្តិជាគ្រឿងដល់ព្រមគឺវត្ថុ) ។ ការកើតឡើងនៃបច្ច័យទាំងឡាយដោយធម៌ដ៏ស្មើ ឈ្មោះថា បច្ច័យសម្បទា ។ ចេតនាក្នុងកាលទាំងបី គឺក្នុងកាលមុនអំពីកិរិយាឲ្យ ១ ក្នុងកាលកំពុងឲ្យ ១ ក្នុងកាលជាចំណែកខាងក្រោយ ១ ប្រកបព្រមដោយសោមនស្ស សម្បយុត្ត

ដោយញាណ ឈ្មោះថា ចេតនាសម្បទា (សម្បត្តិជាគ្រឿងដល់ព្រម គឺចេតនា) ១ ការដែលព្រះទក្ខិណេយ្យបុគ្គល ជាអ្នកទើបនឹងចេញអំពីសមាបត្តិហើយ ឈ្មោះថា គុណាតិរេកសម្បទា (សម្បត្តិជាគ្រឿងដល់ព្រមគឺបដិគ្គាហកៈអ្នកក្រៃលែងដោយគុណ) ១ មែនពិត សម្បទាទាំង ៤ គឺព្រះបច្ចេកពុទ្ធជាព្រះខីណាស្រព ឈ្មោះថា ជាទក្ខិណេយ្យបុគ្គល, បច្ច័យ ឈ្មោះថា កើតឡើងហើយដោយធម៌ ព្រោះបុរសនោះធ្វើការឈ្នួលបានហើយ, ចេតនាក្នុងកាលទាំងបី ឈ្មោះថា បរិសុទ្ធ, ព្រះបច្ចេកពុទ្ធ ដែលទើបនឹងចេញចាកសមាបត្តិភ្លាម ឈ្មោះថា មានគុណយ៉ាងក្រៃលែង បានសម្រេចព្រមហើយដល់កត្តកតិកាៈនេះ, ដោយអានុភាពនៃសម្បទាទាំងបួននោះ កត្តកតិកាៈត្រូវតែបានមហាសម្បត្តិក្នុងភពបច្ចុប្បន្ន ឃើញទាន់ភ្នែកដោយពិត ។ ព្រោះដូច្នោះ កត្តកតិកាៈនេះ ទើបបានសម្បត្តិអំពីសម្នាក់លោកសេដ្ឋី ។

លុះក្នុងកាលកន្លងមក, ចំណែកព្រះរាជា បានទ្រង់ព្រះសណ្ដាប់កម្ម ដែលកត្តកតិកាៈនេះធ្វើហើយ ក៏ត្រាស់ឲ្យហៅបុរសនោះចូលមកគាល់ ហើយប្រោសព្រះរាជទានប្រាក់មួយពាន់រៀល ទ្រង់ទទួលយកចំណែកបុណ្យនោះ មានព្រះហឫទ័យរីករាយ ប្រោសប្រទានទូរភោគៈជាច្រើនទៀត ហើយបានព្រះរាជទានតំណែងសេដ្ឋីដល់ កត្តកតិកាៈនោះ ។

បុរសនោះក៏មាននាមថា ភត្តភតិកសេដ្ឋី បានជាសំឡាញ់នឹងគន្ធសេដ្ឋី បរិភោគផឹកដេករួមគ្នា ស្ថិតនៅដរាបដល់អស់អាយុ ហើយច្យុតពីអត្តភាពនោះទៅកើតក្នុងទេវលោក សោយសម្បត្តិទិព្វ អស់កាលមួយពុទ្ធន្តរ, ក្នុងពុទ្ធុប្បាទកាលនេះ បានមកចុះចាប់បដិសន្ធិក្នុងត្រកូលឧបដ្ឋាករបស់ព្រះសារីបុត្តត្ថេរ ក្នុងក្រុងសាវត្ថី ។ គ្រានោះ មាតារបស់ទារកក្នុងផ្ទៃ ក៏បានគ្រឿងបរិហារគព្ភគតិ ដោយកាលកន្លងទៅពីរបីថ្ងៃ, ជាស្ត្រីចាញ់ផ្ទៃ (មានចំណង់) ថា " ឱហ្ន៎ ! ធ្វើម្ដេចអញនឹងបានថ្វាយភោជនដែលគាត់តែងផ្សំដោយសេកបរ៉យ ដល់ព្រះសារីបុត្តត្ថេរ ព្រមទាំងភិក្ខុប្រាំរយរូបផង ហើយបានស្លៀកសំពត់កាសាយៈ កាន់ផ្ដិលមាសអង្គុយក្នុងទីបំផុតអាសនៈ ហើយបានបរិភោគភោជន សល់ដែលពីពួកភិក្ខុភាជន៍នោះនាំ " ទំរង់ដូច្នេះហើយ ក៏ធ្វើបានតាមចំណង់នោះឯង ទើបបន្ទោបង់ចំណង់ចេញបាន គឺថាលែងចង់ទៀត ។ សូម្បីក្នុងមង្គលក្រៅពីនេះ នាងក៏ថ្វាយទានដូច្នោះដែរ, លុះប្រសូតបុត្ររួចហើយ ក្នុងថ្ងៃដែលឲ្យឈ្មោះបុត្រ, ទើបនាងនិយាយនឹងព្រះថេរៈថា សូមលោកម្ចាស់ឲ្យសិក្ខាបទដល់បុត្ររបស់ខ្ញុំផង ។ ព្រះថេរៈសួរថា ក្មេងនេះឈ្មោះអ្វី ? ។ មាតាទូលថា បពិត្រលោកដ៏ចម្រើន ! ចាប់ដើមតាំងអំពីកាលកូននេះមកចាប់ផ្ទៃខ្ញុំ, អ្នកណាម្នាក់ក្នុងផ្ទះនេះ មិនដែលឈ្មោះថាមានកើតទុក្ខឡើយ, ព្រោះហេតុនោះឯង ទើបឲ្យឈ្មោះវាថា សុខកុមារ ។

ព្រះថេរៈ ក៏ប្រគាន់យកពាក្យនោះឲ្យជាឈ្មោះរបស់កុមារ ហើយបានឲ្យសិក្ខាបទ ។

គ្រានោះ មាតារបស់កុមារគិតថា អញនឹងមិនធ្វើឲ្យទាស់អធ្យាស្រ័យរបស់កូនអញទេ ។ ដូច្នេះ សូម្បីក្នុងមង្គលទាំងឡាយមានមង្គលព្រោះហេតុចោះត្រចៀកនៃកុមារនោះជាដើម នាងក៏បានឲ្យធ្វើ ដូច្នោះដែរ ។ ចំណែកកុមារ ក្នុងកាលដែលខ្លួនមានអាយុ ៧ ខួប ក៏និយាយថា ម៉ែ ! ខ្ញុំចង់បួសក្នុងសម្នាក់ព្រះថេរៈ ។ មាតាឆ្លើយថា "ល្អហើយកូន ! ម៉ែ មិនកាត់អធ្យាស្រ័យរបស់ឯងទេ" ថាហើយក៏ឲ្យទៅនិមន្តព្រះថេរៈមកឆាន់ចង្ហាន់ រួចទូលថា "លោកម្ចាស់ ! បុត្ររបស់ខ្ញុំចង់បួស, វេលារសៀលត្រជាក់ ខ្ញុំនឹងនាំយកវាទៅឯវិហារ" ហើយឲ្យព្រះថេរៈនិមន្តទៅវត្តមុន ទើបប្រមូលពួកញាតិឲ្យមកជួបជុំគ្នាប្រាប់ថា "ខ្ញុំនឹងធ្វើកិច្ចដែលគួរធ្វើក្នុងវេលាជាគ្រហស្ថ ដល់បុត្ររបស់ខ្ញុំ ក្នុងថ្ងៃនេះឯង" ហើយក៏ស្អិតស្អាងបុត្រនាំទៅឯវិហារដោយសិរីសោភាគ្យដ៏ធំ ប្រគេនដល់ព្រះថេរៈ ។ ចំណែកព្រះថេរៈប្រាប់កុមារនោះថា នែបា ! ធម្មតាបព្វជ្ជា គេធ្វើបានដោយកម្រណាស់, ឯងនឹងអាចដើម្បីត្រេកអរឬទេ ? កុមារនោះទូលថា ព្រះករុណា ខ្ញុំនឹងធ្វើតាមឱវាទរបស់លោកម្ចាស់បាន ។ ព្រះថេរៈក៏ឲ្យកម្មដ្ឋានហើយបំបួស ។

ឯមាតាបិតារបស់សាមណេរ កាលធ្វើសក្ការៈក្នុងវេលាបួស ក៏ថ្វាយ

ភោជនលាយដោយរសជាតិកប់រយមុខ ដល់ភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធានអស់ ៧ ថ្ងៃ ក្នុងវត្តនោះឯង, ហើយទើបត្រឡប់ទៅឯផ្ទះរបស់ខ្លួននាវេលារសៀល ។ ក្នុងថ្ងៃទី ៨, កាលភិក្ខុសង្ឃចូលទៅក្នុងស្រុកដើម្បីបិណ្ឌបាត, ព្រះសារីបុត្តត្ថេរ ធ្វើកិច្ចដែលគួរធ្វើក្នុងវិហារវត្តរួចហើយក៏ឲ្យសាមណេរកាន់បាត្រនិងចីវរ ចូលតាមទៅក្នុងស្រុកដើម្បីបិណ្ឌបាត ។ សាមណេរបានប្រទះឃើញប្រឡាយទឹកជាដើមនៅកណ្ដាលផ្លូវ ក៏សួរព្រះថេរៈ! ដូចជាបណ្ឌិតសាមណេរដែរ ។ សាមណេរស្ដាប់ហេតុទាំងនោះហើយក៏ទូលថា បើព្រះគុណទទួលយកបាត្រនិងចីវររបស់ព្រះគុណទៅបាន ខ្ញុំព្រះករុណាសូមត្រឡប់ទៅវត្តវិញ ។ ព្រះថេរៈមិនអាចកាត់អធ្យាស្រ័យរបស់សាមណេរ ទើបប្រាប់ថា "អ្នកយកបាត្រនិងចីវរមកឲ្យយើងចុះ" ហើយទទួលយកបាត្រនិងចីវរពីសាមណេរ ។ សំពះលាព្រះថេរៈរួច រៀបនឹងត្រឡប់ ក៏ផ្ដាំថា ទាន[ប្រោស]! កាលបើព្រះគុណនឹងយកអាហារមកផ្ញើខ្ញុំ សូមនាំយកភោជនដែលលាយផ្សំដោយរសជាតិកប់រយមក ។ - យើងនឹងបានភោជនបែបនោះមកពីណា ? ។ - កាលបើព្រះគុណមិនបាន ដោយបុណ្យរបស់ខ្លួនទេ គង់តែបានដោយបុណ្យរបស់ខ្ញុំដែរ ។ ទើបព្រះថេរៈហុចកូនសោទ្វារកុដិទៅឲ្យសាមណេរ ហើយចូលទៅក្នុងស្រុកដើម្បីបិណ្ឌបាត ។

សុខសាមណេរនោះ ទៅដល់វត្តហើយ ក៏បើកទ្វារបន្ទប់របស់ព្រះថេរៈចូលទៅ រួចបិទទ្វារវិញ អង្គុយភាវនាបញ្ជូនញាណឲ្យស៊ុងចុះក្នុងកាយរបស់ខ្លួន ៗ ដោយតេជះនៃគុណរបស់សាមណេរនោះ អាសនៈរបស់ព្រះឥន្ទ្រសម្តែងអាការក្តៅ ៗ ទើបព្រះឥន្ទ្រពិចារណាមើលថា "នោះជាអ្វីហ្ន៎" ទ្រង់ឃើញសាមណេរហើយ ក៏គិតថា "សុខសាមណេរឲ្យបាត្រនិងចីវរដល់ឧបជ្ឈាយ៍ហើយវិលទៅកាន់វត្តវិញ ដោយតាំងចិត្តថាអញនឹងធ្វើសមណធម៌, ការដែលអញទៅក្នុងទីនោះ គួរ" ហើយទើបហៅមហារាជទាំងបួនមក ទ្រង់បញ្ជូនទៅ ដោយបានបង្គាប់ថា "នែអ្នកទាំងឡាយ! ពួកអ្នកចូរទៅដេញហ្វូងសត្វស្លាបដែលមានសម្លេងអាក្រក់គ្រប់ព្រៃជិតវត្ត ឲ្យរត់អស់ទៅ ៗ មហារាជទាំងបួននេះ ក៏ធ្វើតាមបង្គាប់ព្រះឥន្ទ្រដូច្នោះ ហើយបានទៅកាន់ការថែរក្សាជុំវិញវត្ត ៗ ព្រះឥន្ទ្រទ្រង់បង្គាប់ចន្ទិមទេវបុត្រ និង សុរិយទេវបុត្តថា ពួកអ្នកចូរទាញវិមានរបស់ខ្លួនបញ្ឈប់ទុកសិន ៗ ចន្ទិមទេវបុត្រនិងសុរិយទេ-វបុត្រនោះ ក៏បានធ្វើតាមបង្គាប់ព្រះឥន្ទ្រ ៗ ចំណែកព្រះអង្គឯងបានកាន់ការថែរក្សាក្នុងទីសម្រាប់ទាញខ្សែ ៗ វត្តក៏បានស្ងប់ស្ងាត់សម្រេក ៗ ឯសាមណេរ មានចិត្តនឹងហ្ន៎ ចម្រើនវិបស្សនា ក៏បានសម្រេចមគ្គផលទាំងបី ៗ

ចំណែកព្រះថេរៈ ដែលសាមណេរបានផ្តាំថា "ព្រះគុណ ! សូមមេត្តាយកគោជនលាយផ្សំដោយរសជាតិរាប់រយ មកផ្ញើខ្ញុំ" ក៏ពិចារណាមើលថា "អញនឹងអាចដើម្បីបានគោជនបែបនោះ នៅផ្ទះរបស់អ្នកណាអេះ !" ក៏ឃើញត្រកូលឧបដ្ឋាកមួយដែលសម្បូណ៌ដោយអធ្យាស្រ័យ ទើបនិមន្តទៅផ្ទះឧបដ្ឋាកនោះ ។ ត្រកូលនោះ មានចិត្តរីករាយ ទូលថា "បពិត្រលោកម្ចាស់ ! ថ្ងៃនេះ ដែលលោកម្ចាស់និមន្តមកក្នុងទីនេះ រាប់ថា ជាការប្រពៃណាស់" រួចក៏ទទួលបាត្រ និមន្តឲ្យព្រះថេរៈគង់ ហើយប្រគេនបបរនិងបង្អែម រួចអារាធនាធម្មកថា ទម្រាំដល់ពេលឆាន់ចង្ហាន់ថ្ងៃត្រង់ ។ លោកក៏សម្តែងធម្មកថាជាទីតាំងនៃសេចក្តីត្រេក ដល់ជនទាំងនោះ តាមកាលវេលាដែលកំណត់ហើយ ក៏បញ្ចប់ទេសនា ។ លុះចប់ទេសនាហើយ ពួកឧបដ្ឋាកប្រគេនគោជនលាយផ្សំដោយរសជាតិរាប់រយមុខ ដល់ព្រះថេរៈ, ឃើញព្រះថេរៈប្រុងប្រៀបនឹងយកគោជននោះទៅឯវត្ត, ទើបទូលថា និមន្តលោកម្ចាស់ឆាន់គោជននេះ ឲ្យអស់ទៅចុះ, ពួកខ្ញុំនឹងប្រគេនគោជនបែបនេះ មួយចំណែកទៀត" លុះឲ្យព្រះថេរៈឆាន់ រួចហើយ ក៏បានប្រគេនគោជនពេញបាត្រទៀត ។ ព្រះថេរៈទទួលគោជនលាយផ្សំដោយរសជាតិរាប់រយមុខ ក៏ប្រញាប់វិលទៅវត្តវិញ ដោយគិតថា ប្រហែលជាសាមណេររបស់អញឃ្លានបាយណាស់ហើយ ។

ថ្ងៃនោះ ព្រះសាស្តាស្តេចចេញអំពីព្រឹកព្រហាមគង់នៅក្នុងព្រះគន្ធ-កុដិ បានទ្រង់រំពឹងថា ថ្ងៃនេះ សុខសាមណេរ ឲ្យបាត្រនិងចីវរដល់ព្រះឧបជ្ឈាយ៍ហើយត្រឡប់ទៅវត្តវិញ ដោយតាំងចិត្តថា នឹងធ្វើសមណ-ធម៌, តើកិច្ចរបស់គេ សម្រេចហើយឬនៅឡើយ ” ព្រះអង្គទ្រង់ឃើញ-ថា “ សាមណេរ ទើបតែនឹងបានសម្រេចមគ្គផលត្រឹមបីថ្នាក់ប៉ុណ្ណោះ ” កាលទ្រង់ពិចារណាឲ្យល្អិតក្រៃលែងទៅទៀត ទ្រង់ព្រះតម្រិះថា “ ថ្ងៃនេះ សុខសាមណេរ នឹងអាចដើម្បីបានសម្រេចព្រះអរហត្តពិត ប៉ុន្តែ សារីបុត្ត កំពុងយកភត្តប្រញាប់ចេញមកពីស្រុក ដោយគិតថា សាម-ណេររបស់អញឃ្លានបាយ, បើសារីបុត្ត យកភត្តមកក្នុងកាលសាម-ណេរមិនទាន់បានសម្រេចព្រះអរហត្តទេ មុខជានឹងកើតអន្តរាយ ដល់សាមណេរនេះមិនខាន, ការដែលតថាគតទៅជួយរក្សាការពារត្រង់មាត់ទ្វារ ទើបគួរ ” ហើយក៏ស្តេចចេញពីព្រះគន្ធកុដិ ស្តេចទៅឈរនៅត្រង់មាត់ទ្វារ ដើម្បីជួយរក្សាការពារ ។ លុះព្រះថេរៈ នាំយកភត្តមកដល់ ៗ ទើបព្រះអង្គត្រាស់សួរប្រស្នា ៤ ប្រការនឹងព្រះថេរៈនោះ ដោយន័យដែលពោលហើយក្នុងខាងក្រោយ[១] នោះឯង ។ នៅទីបំផុតការឆ្លើយប្រស្នា សាមណេរក៏បានសម្រេចព្រះអរហត្ត ។ ទើបព្រះសាស្តាទ្រង់ត្រាស់នឹងព្រះថេរៈថា សារីបុត្ត ! អ្នកទៅចុះ, ចូរ

១- គឺនិយាយរួចមកហើយក្នុងរឿងបណ្ឌិតសាមណេរ ។

ឲ្យភត្តដល់សាមណេររបស់អ្នកចុះ ។ ព្រះថេរៈទៅដល់ ក៏គោះទ្វារ ។ សាមណេរ ក៏ចេញមកធ្វើវត្តដល់ព្រះឧបជ្ឈាយ៍, កាលព្រះថេរៈប្រាប់ថា "អ្នកចូរធ្វើភត្តកិច្ចចុះ", លុះដឹងថា "ព្រះថេរៈមិនត្រូវការដោយភត្តទេ" ជាក្មេងមានអាយុត្រឹមតែ ៧ ខួបប៉ុណ្ណោះ បានសម្រេចព្រះអរហត្ត ក្នុងពេលមួយរំពេចនោះឯង ក៏ពិចារណានូវបាសនស្ថាន គឺទីនៃអាសនៈ ទាប ធ្វើភត្តកិច្ចស្រេចហើយលាងបាត្រទុកដាក់ ។ វេលានោះ មហារាជទាំងបួនក៏លែងទៅចាំរក្សា ។ ឯចន្ទិមទេវបុត្រនិងសុរិយទេវបុត្រ ក៏ពាខ្លួនវិមានទៅ ។ សូម្បីព្រះឥន្ទ្រ ក៏លែងនៅរក្សាក្នុងទីសម្រាប់ទាញខ្សែ ។ ព្រះអាទិត្យក៏ខ្វងហួសពាក់កណ្តាលផ្ទៃអាកាស ឃើញប្រាកដ ។ ពួកភិក្ខុក៏និយាយគ្នាថា វេលារសៀលប្រាកដហើយ សាមណេរធ្វើភត្តកិច្ចថ្ងៃនេះ, ហេតុម្តេចហ្ន៎ ទើបវេលាព្រឹកយឺតយូរ វេលារសៀលឆាប់យ៉ាងនេះ ។ ព្រះបរមសាស្តាស្តេចមកដល់ហើយក៏ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ! ឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាពីរឿងអ្វីហ្នឹង?",កាលភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន! ថ្ងៃនេះ! វេលាព្រឹកយឺតយូរ វេលារសៀលឆាប់ហ័ស, សាមណេរ ទើបនឹងឆាន់ភត្តស្រេច វេលាថ្ងៃនេះ ឃើញថាព្រះអាទិត្យ កខ្វងហួសពាក់កណ្តាលផ្ទៃអាកាសជាប្រាកដ ", ទើបព្រះពុទ្ធអង្គទ្រង់ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ! ក្នុងវេលាធ្វើសមណធម៌ របស់អ្នកមានបុណ្យទាំងឡាយ តែងកើតមាន

ហេតុដូច្នេះឯង, ព្រោះថ្ងៃនេះ មហាជនទាំងបួនមកនៅចាំថែរក្សាជុំវិញវត្ត ចន្ទិមសុរិយទេវបុត្រ បានទាញវិមានបញ្ឈប់ទុក, ព្រះឥន្ទនៅចាំការពារត្រង់ទីសម្រាប់ទាញខ្សែ, សូម្បីតថាគត ក៏នៅចាំថែរក្សាត្រង់មាត់ច្រាំងដែរ; ថ្ងៃនេះ សុខសភាមណោរ ឃើញពួកអ្នកបាចបង្ហូរទឹកដោយស្អាច, ឃើញពួកជាងសរពត់កូនសរឲ្យត្រង់ ឃើញពួកជាងចាំងឈើធ្វើកង់រទេះ ជាដើម ហើយក៏ទូន្មានខ្លួន ទាល់តែបានសម្រេចព្រះអរហត្ត" រួចទើបទ្រង់ត្រាស់គាថា ថា ៖

ឧទកំ ហិ នយន្តិ នេត្តិកា
ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា
អត្តានំ ទមយន្តិ សុព្វតា ។

ធម្មតា អ្នកបង្ហូរទឹក តែងបង្ហូរទឹក, អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់), ឯអ្នកចាំងតែងចាំងឈើ ឯអ្នកមានវត្តល្អ ក៏តែងទូន្មានខ្លួនដែរ ។

សេចក្ដីសង្ខេបក្នុងរឿង សុខសាមណេរ ៖

មានកុមារម្នាក់អាយុ ៧ ខួប ក្នុងត្រកូលព្រះ សារីបុត្តត្ថេរ ចេញបួសជាសាមណេរ, អាស្រ័យគុណវុឌ្ឍិដែលខ្លួនបានធ្វើទុកអំពីបុព្វជាតិមកបណ្ដាលឲ្យជាអ្នកឈ្លាសវៃ បានត្រាស់ដឹងមគ្គផលយ៉ាងឆាប់រហ័ស ។

រឿងសុខសាមណេរ ចប់ ។

អ្នកប្រាជ្ញមិនធ្វេសប្រហែសទេ
តែងទូន្មានខ្លួនជារឿយ ៗ

# ល្បើកចចក

ឧកញ៉ាសុត្តរេហា ម៉ុក រៀបរៀង

សហ. លី-ជាមតេជ៍ ចម្លងផ្ទៀង-ផ្ទាត់

( បទកាកគតិ )

នេះបទកាកា គតិបវរ តែងចងរឿងរាយ
តាមពាក្យពីព្រេង គេតែងនិយាយ ដំណើរគេប្រាយ
ពីសត្វចចក ។
យោនយកកំណើត កំណត់កាលកើត ពីងពួនជ្រៀតជ្រក
កន្ទុយរួញថ្កំ ធារធំសៀតសឹក សត្វព្រៃចចក
ស្វែងរកភោជនា ។
ប្របដេរស្ករស្វឹង គ្រញាំងបួបឹង ជ្រោះជ្រោយចត្តា
លុះយប់ផ្លាល់ផ្លាប់ ចុះហាប់មច្ឆា តែងបរិភោគា
សត្វព្រៃប្រក្រតី ។
រូបភាពក្រញេញ បាទបួនតឿទេញ កាយខ្ចបស្រើយ
តែងដើរលោកលះ ស្វែងស្វះរកស៊ី ព្រួយទៀយឥន្ទ្រីយ
ស្គាំងស្គមអាត្មា ។

ពីកាលក្មេងនៅ មេស្លាប់ចោលទៅ នៅតែនឹងប៉ា
នាំដើររកស៊ី ប្រចទីផលសា លុះធំកាលណា
ប៉ាស្លាប់បង់បាត់ ៗ

ចចកនោះទៅ ទល់ទុក្ខកាត់ក្ដៅ ក្នុងថ្លើមប្រមាត់
ឥតមេឥតប៉ា កំព្រាព្រាកព្រាត់ ស្ងប់ស្ងួតស្ងៀមស្ងាត់
ត្រមោចម្នាក់ឯង ៗ

ចចកគន់គិត រំពឹងក្នុងចិត្ត រងរែកបំបែង
ដើររកគោជនា គោក្ដាកណ្ដែង កណ្ដោចឯកឯង
ឥតមានគ្នីគ្នា ៗ

វេលាចូលដេក ក្នុងទីដំណេក ត្រូវក្ងៀនរងា
ខ្យល់បក់ស្ងប់ស្ងួត ថ្លើមស្ងួតគ្រាំគ្រា ក្រៀមក្រំកំព្រា
កំប្រោនពេកពន់ ៗ

ចចករិះគិត បានឃើញគំនិត មួយនោះជាលន់
ថាអញត្រូវរក ត្រូវយកប្រពន្ធ ទើបបាននឹងស្រន់
នឹងស្រោលទុក្ខា ៗ

គ្រាន់ជាគូទៅ ស្នេហាថែបនៅ ក្នុងរូងបព្តា
ចចកគិតថ្លោះ ក្រោកស្ទុះយាត្រា ត្រាច់ក្នុងព្រឹក្សា
ស្រន្ទូតស្រអាក់ ៗ

ដើរគ្រាច់តែឯង កណ្ដោចកណ្ដែង កំព្រាព្រាត់ព្រាត់

ត្រមោចត្រមង់ នៅក្នុងព្រៃស្ងាត់ ប្រទះហ្វូងសត្វ

គោតគោមហឹងក្រ ។

ទទៀនទទ្រាយ ដំរីប្រើសព្រាយ ឈ្លូសក្ដាន់ស្លូកព

រមាសរមាំង ខ្ទីងខ្លាំងខ្លាងខ្លា ដើររកគោក្ដា

សឹងសត្វយង់យួង ។

បបកឃើញសត្វ សាហាវផ្ដាត់ ច្រើនក្រៃកន្លង

គៀងកាល់ត្បូវ ខ្ទៀវខ្ទាវអើងកង ភិតភ័យកន្លង

ស្ញើរបាត់ស្មារតី ។

ខំដើររំលង គៀសសត្វយង់យួង បានដល់ទទី

ស្ទឹងមួយថ្លាជ្រះ ត្រចះយល់ដី បបកចាប់ត្រី

បំភែតកាយា ។

ហើយហែលផ្លាស់ខ្លួន ស្ទឹងនោះរំលង ដល់ត្រើយគង្គា

គ្រាច់ក្នុងវេញ្ញាះ ចន្លោះអណ្ដា មានរូងគុហា

ជិតជើងគិរី ។

បបកចូលជិត ប្រុងប្រាណមូលមិត្ត មៀងមើលរកញី

ដុនចុះលើបះលើត ចំអើតមើលទី ក្បែរណានោះមានញី

បបកមួយណា ។

នៅក្នុងរូបថ្ម សិលាដ៏ល្អ ក្បាលសមកាយា
បបកឈ្មោលគិត ក្នុងចិត្តថ្លៃថា គួរអញសួរសា
បន្តិចទើបបាន ។
ទើបឈ្មោលហាក ថាប្អូនពន្លក មិត្តមុំកល្យាណ
នៅក្នុងរូបថ្ម ល្អះល្អថ្កើងថ្កាន សព្វថ្ងៃតើមាន
ប្ដីជាគួរគ្រង ។
ប្ដូរនៅឯកឯង ប្អូនអើយចូលថ្លែង ប្រាយប្រាប់បងផង
ឲ្យបងសោយ ក្នុងកាយនេះហោង បើគតគួរគ្រង
បងសុំស្នេហា ។
បបកញីស្ដាប់ ឆាកហើយថ្លែងប្រាប់ ថាអ្នកសោភា
ប្អូននៅសព្វថ្ងៃ អាស្រ័យគុហា មិនមានទីណា
ជាគួរឡើយនៃ ។
កាលដើមមានមេ មានបាបំពេ ទុបក្រុងសព្វថ្ងៃ
ឥឡូវមេបា មរណាក្សិណក្ស័យ ប្អូននៅសព្វថ្ងៃ
កំព្រាពេកពន់ ។
ឈ្មោលឮដូច្នោះ ព្រឺព្រួចពង់ពោះ ហឫទ័យទោរទន់
ទើបឆ្លើយតបថា ប្អូនក្លាសន្ធន់ ប្អូនអើយបងគន់
បងគិតអនិច្ចា ។

អាសូរប្អូនស្ងួន មាសមិត្រខ្ញុំខ្លួន កំព្រាឯកា
ផុតកលខ្លួនបង់ សៅហ្មងចិត្តា សព្វថ្ងៃបង់មហា
ព្រួយណាស់ប្អូនអើយ ។

បងកញ្ញីស្តាប់ ពាក្យឈ្មោលថ្លែងប្រាប់ ឆ្លើយថាអ្នកអើយ
ប្អូនស្តាប់ពាក្យអ្នក ជឿជាក់ទៅហើយ ក្នុងចិត្តឥតស្បើយ
កើតទុក្ខទៀតថ្មី ។

ប្អូនចង់សុំសួរ ហៅមហាមិនគួរ ត្បិតខ្លួនជាស្រី
អ្នកថាព្រួយចិត្ត ព្រោះគិតរឿងអ្វី ប្រុសប្រាជ្ញប្រឹមប្រិយ
ប្រាយប្រាប់ប្អូនក៏ ។

ឈ្មោលថាមាសមិត្រ បងព្រួយព្រោះគិត ដល់គូស្នេហា
គ្មានគ្នាជាពីរ ចំណោរអនា- គតបង់ហៅមហា
ថប់ណាស់មាសបង ។

ញីថាប្រុសអើយ កុំថប់អ្វីឡើយ ប្អូនណានារង់
រិះរកជួយគិត តាមចិត្តអ្នកបង ត្រង់តាមបំណង
ចិត្តអ្នកប្រាថ្នា ។

ឈ្មោលថាមាសមិត្រ បងចង់ឆ្ងល់ចិត្ត ធ្វើដួងជីវ៉ា
នៅលើប្អូនស្ងួន សូមខ្ញុំទបេត្តា បងមិនប្រាថ្នា
ជាខ្ញុំពីពៅ ។

ញ៉ាខ្ញើយជាអ្នក ចិត្តចង់ស្រម័ក្យ មូលមួយលំនៅ
ផ្ញើជួនចិន្តា ស្នេហាគេទៅ ទិនប្អូននេះក្បែរ
ពេញមហាអរពេក ៗ

ប៉ុន្តែប្អូនយល់ ប្អូនគិតទៅដល់ ឆ្ងាយឆ្ងល់ចំឡែក
បានអ្នកឯនាយ សប្បាយអនេក មានញ៉ាំយ៉ាងឯក
គួរស្នេហា ៗ

មេត្តាអ្នកមិនមាន ចិត្តជាប់ចង់បាន ជាគូដីកា
ហើយប្រែលាកលះ ស្រួនស្រុះយាត្រា កូនព្រៃអគ្គា
មកដល់បាននាយ ៗ

ពេលស្តាប់ខ្ញើយឆ្ងាស់ ថាហៃប្អូនមាស មានរូបឆោមឆាយ
ឆោមឆេតខ្វង់ បានបងឯនាយ មែនហើយសប្បាយ
ដូចពាក្យប្អូនថា ៗ

គឺមោះបងរក គួរាប់ទិនយក ជាតិជាពនិតា
ទឹងផ្ញើចិត្តខ្លួន ដូចស្ងួននេះណា គ្មានសោះបងយេហា
ជប់ពេកខាងកាយ ៗ

ហេតុនោះបងស្រុះ បងស្រួងលាកលះ មកដល់បាននាយ
បងប៉ងផ្ញើខ្លួន ល្មើខ្លួនឆោមឆាយ ព្រួយទៀយអង្គកាយ
មេត្ត ៗ មិនគិត ៗ

លែងតែប្អូនស្រី មាសមាននេត្រី មេត្តាមូលមិត្ត
មួយមួយចិន្តា ស្នេហាជួបជិត ជួបតាប់ប្រព្រឹត្ត
ជាគូរាសនា ។

ញីស្តាប់ឆ្លើយឆ្លៀត ឆ្លើយជូនវិញទៀត ថាប្រុសស្នេហា
ពាក្យគ្រៅល្អល្អះ គួរសះសង្ការ លួងលោមចិន្តា
បានហើយបោះបង់ ។

ឈ្មោលឆ្លើយថាហៃ ប្អូនមាសថ្លើមថ្លៃ បណ្ឌិលសាច់ស-
ង្ហាសមសេកា កាយាវរវង្ស វរាសអស់អង្គ
អស់ឥតសង្ស័យ ។

បងមហាស្រឡាញ់ ប្អូនមាសឈ្ងុយឆ្ងាញ់ ចិត្តតាប់អាល័យ
អាលោះលើសលន់ ពេកពន់គ្រាស់ក្រៃ ពុំបានបង់ក្ស័យ
ជីវិតជាម្តង ។

ឈ្មោលថាតែម៉្លោះ ចូលជិតចំពោះ ផ្ទឹមផ្អាប់ហើយះហាង
ថើបថ្ពាល់ឮខ្សឹត ចំភឹតថ្ពឹងខ្នង ថាហៃមាសបង
នាងកុំទទឹង ។

បំណាច់បងមក រកប្អូនពានក ឆ្លងអូរឆ្លងស្ទឹង
មិនស្តាយជីវិត ព្រោះចិត្តរំពឹង ទុកប្អូនព្រលឹង
ជាដួងស្នេហា ។

ញីអៀនអេនអាក់ នុនមុះខុកក័ត្រ ក្ដួលចិត្តចិន្ដា
សេពសុខគ្រេមក្សាន្ត កុំបាននុះបា ទើបឈ្លោលលោមថា
ព្រលឹងបងអាយ ។

បងចង់នាំទៅ នុះនុះពេញក្ដៅ (១) . . .
. . . . . . . . . . . . .
. . . . ។

. . . . . . . . . . . . . .
អញចង់តែអត់ គន្និតះប្រស់គៅ ឲ្យស្លាប់ធាប់ទៅ
កុំឲ្យវេទនា ។

ផល់គិតតែងទៅ ក្រែងកើតហ្មងសៅ កើតកើរទិន្នា
ថានុចចក កំត្រកមោហា ក្សែណក្សែយផន្នា
ព្រោះញ៉េចញ្ញោត ។

បើនឹងស្លាប់សៅ ឲ្យគ្មកើរយស គេមានក៏ណាត
មាននាម្ស្រសៃសើរ ថាបើអញគោត ចចកទេះសាត
ពេញហៅបារនក្ទា ។

គិតហើយផ្ទាលទៅ ដេតទឹករណ្ដៅ ថាយើនណា
បង្កើតជាក្ដៅ ហ្គុង៖សៅចិន្ដា ឆើយមើលមេឃថា
យើក្ដៅព្រោះថ្ងៃ ។

---

១- [illegible] ។

អើអញជាតិនេះ  លំបាកតាំងម្ល៉េះ  ព្រោះតែភពក្រ
កើតជាចចក  កំព្រាកចង្រៃ  ជាតិក្រោយអញខ្ពៃ
អញសូមសច្ចា  ៗ
ពោះបែកបកើត  យោនយកកំណើត  ជាតិណាកពណា
អញសូមសម្រេច  សេចក្តីប្រាថ្នា  កើតជាសុរិយា
រុងរឿងរង្សី  ៗ
កាលនោះមានយក្ស  ប្រេតមួយសំណាក់  ឋិតបានប្រក្រតី
នៅបព្វតា  ទៀបនាវិថី  យក្សព្រុសម្តី
ចចកប្រាថ្នា  ៗ
យក្សគិតថាកើ  មហាលាភណាស់តើ  ទឹងបានភោជមា
ត្រកាលចំណី  ល្អក្រៃថ្ងៃថ្លា  ទឹងបរិភោគ្គា
នូវសាច់ចចក  ៗ
គួរអញក្រឡា  ជាអគ្គឥន្ទ្រា  ប្រាប់វាឲ្យយក
សាច់ឈាមជាទាន  ទឹងបានវិះរក  កំណើតបានមក
កើតជាសុរិយា  ៗ
យក្សគិតដូច្នោះ  កាឡាចំពោះ  ជាអគ្គឥន្ទ្រា
ហិចហោះប្រៀវប្រែ  លើផ្ទៃវេហាស៍  ហើយមានវាចា
សាកសួរមេត្រី  ៗ

ថាហៃបបក　អ្នកត្រាច់ដើរមក　ពីណាទេគឺ
បបកក្រឡេក　ឈ្មៀងភ្នែករំពៃ　ស្ថានអន្ដរកាស័យ
　ទើបទូលទៅថា　។

បពិត្រព្រះភ-　ស្ត្រាទ្រើសទរិទ្ធ　ភស្សូរសុជាតា
ខ្ញុំមកស្ថានស្ថាះ　ចំពោះព្រាហ្ម　រកចាប់មច្ឆា
　នៅក្នុងជលធី　។

បើបានមច្ឆា　ដូចប៉ងព្រាហ្ម　យកទៅឲ្យញី
ត្បិតមានផ្ទៃពោះ　ចិត្តសោះចង់ស៊ី　ត្រីក្នុងជលធី
　ទើបច្បាញ់ណាស់ណា　។

ហេតុនោះខ្ញុំមក　រុកពនរះរក　សមុទ្រមច្ឆា
ដើរជាន់ក្រសក្តៅ　ហួងសៅចិន្តា　ព្រពេងបាតា
　រន្ធត់អង្គប្រាណ　។

បែកញើសហូរហត់　ក្តៅណាស់ព្រាកដ　អាចអត់ពុំបាន
ព្រោះថ្ងៃចាំងចែង　សូរ្យសែងក្តើងក្តាន　ទើបខ្ញុំប្រណិធាន
　អធិដ្ឋានថា　។

បើខ្ញុំនឹងកើត　យកជាតិកំណើត　ក្រោយខ្ញុំព្រាហ្ម
គាំងចិត្តចង់បាន　ដូចភាទចិន្តា　កើតជាសុរិយា
　ព្រាកដដូចប៉ង　។

បពិត្រឥន្ទ្រា　　សូមស្តេចមេត្តា　　ជួយខ្ញុំផង
ធ្វើម្តេចនឹងបាន　　ដូចគ្មានបំណង　　ប្រេតយក្សឆ្លើយឆ្លង
　　ជាង៉ាយណាស់ណា៎　　ៗ
បើទៅចង់បាន　　ដូចចិត្តបំណាន　　បំណងប្រាថ្នា
ចូរទៅផ្តិលផ្តាច់　　សម្រេចជ្នា　　យកសាច់ឲ្យជា
　　មានយក្សបីសាច　　ៗ
ហេតុអាទិសង្ស　　ជួយជូនទ្រទ្រង់　　កើតមានអំណាច
ជាសែងសុរីយ៍　　រស្មីចិញ្ចាច　　ចែញ្ចងត្រដាច
　　ដូចចិត្តប្រាថ្នា　　ៗ
ចចកស្តាប់គិត　　ជឿជាក់ចូលចិត្ត　　ទើបទូលទៅថា
ខ្ញុំចង់ឲ្យមាន　　សាច់ប្រាណហើយណា៎　　ប្រេតយក្សឆ្លើយថា
　　សាធុពីរដង　　ៗ
ប្រេតយក្សថាម៉្លោះ　　និម្មិតចំពោះ　　បាំងបាត់ទៅហោង
ចចករត់ចេញ　　ពោលខ្ញាញ់ជាម្តង　　គិតថាអញបីង
　　បានដូចសេចក្តី　　ៗ
ចចកគិតប្មោះ　　ពោលដល់ទឹកចុះ　　លុយលបចាប់ត្រី
លុះចាប់ត្រីបាន　　ដូចគ្មានសេចក្តី　　ប្រាថ្នាពាំត្រី
　　ឲ្យញីគោក្តា　　ៗ

ញីឃើញឈ្មោលដល់ បានត្រីខ្វាយខ្វល់ ទទួលមច្ឆា
បរិភោគផ្សាយផ្សព្វ ស្កល់ស្កប់ចិន្តា ទើបឈ្មោលប្រាប់ថា
ហៃប្អូនពិសី ។
កាលបងទៅយក មច្ឆានាំមក ឲ្យប្អូនប្រឹមប្រិយ៍
ហៅមហាព្រួយប្រាណ ពុំក្សាន្តណាស្រី ស្ទើរខានបានត្រី
មកផ្ញើប្អូនគ្នា ។
ប្អូនអើយថ្ងៃក្តៅ ដើរចរពាសទៅ រកាមអក្កា
ក្តៅដល់ក្នុងថ្ងើម ដង្ហើមទំហោ ដល់ដួលច្រើនគ្រា
ស្ទើរវិលក្រោយទាន ។
បងចាំបោលទៅ ប្អូនអើយរាំងក្តៅ រន្ធត់អង្គប្រាណ
បងបោលហើយគិត ក្នុងចិត្តថាស្ការ ប្រហែលតាហាន
ចម្រាំងសឹកម្ហូបសោះ ។
គេដះសំណាង សំណូមសូមសាង ពីមុនមកនោះ
បានជួបឥន្ទ្រា យាត្រាចំពោះ ហើយស្តេចអនុគ្រោះ
ស្មោះស្មានមេត្រី ។
ប្រដៅទូន្មាន នាំជានិទាន ឲ្យដឹងសេចក្តី
បុណ្យបាបត្រូវខុស ហើយហោះចេញខ្វី ចង់ចេញចាកទី
រកបាចមច្ឆា ។

ចចកប្រាប់ញី សុសសព្វសេចក្តី គ្មានខ្វះត្រង់ណា
ហើយលោកថាប្អូន ខ្ញុំខ្វល់ស្នេហា អញបង់ចង់លា
ទៅក្បែរជីវិត ។

យកសាច់ជាភាន ប្រាជ្ញាឲ្យប្រាន ជាព្រះអាទិត្យ
តើប្អូនទន់ថា ម្តេចម្តាមាសមិត្ត ញីស្តាប់ហើយគិត
ធុញថែបថា ។

អ្នកមាសប្អូនអើយ ប្អូនថាម្តេចឡើយ ចិត្តអ្នកប្រាប់ថា
មិនហ៊ានទាំងឃាត់ ឲ្យភ្លាត់សង្ខា ក្រែងកើតទោសា
ជាប់ដិតដល់ប្រាណ ។

គឺមោះប្អូនទៅ ក្រោយអ្នកប្រុសទៅ ពោះបង់ពេលបាន
ប្អូនកើតទុក្ខក្រៃ តែក្រៃតាំក្សាន្ត ទុក្ខមួយព្រោះមាន
ចម្ងន់ពេញពោះ ។

ទុក្ខមួយព្រោះព្រាត់ ព្រោះប្រុសស្ងួនខ្យស្ងាត់ ស្ងួនស៊ៀមក្រៀមព្រោះ
ក្រៀមក្រំក្នុងចិត្ត ថ្ងៃរះថ្ងៃគាលោះ អាល័យស្រណោះ
អ្នកប្រុសប្រុសទៅ ។

សក្តៃប្តីរឹង អ្នកមាសព្រាលឹង ស្មានថាអ្នកនៅ
នៃបទិត្យឆ្ងាក ស្នេហានាគោ ប្អូនគតញាតិនៅ
សង្ឃឹមតែអ្នក ។

ជាគូស្នេហា ទុកស៊ើបតា មានារួមរក្ស
រួមរសស្នេហ៍ស្នង ប្អូនប័នទុកដាក់ ផ្ញើខ្លួនលើអ្នក
លុះអស់ជន្មា ៗ

ហេតុនោះប្អូនសុំ ប្អូនសែនលាកលះ ចោលទីគូហា
ដិតដោយតាមអ្នក វរល័ក្ខណ៍សោភា ម្តេចឡើយឃ្លាតឃ្លា
ពីទ្រូងប្អូនទៅ ៗ

ញីថាតែម្ល៉ោះ ទុនមុខទុកចុះ ទុកឈ្លូលក្តៅ
ហាក់ដូចអគ្គី ឆេះពីពោះទៅ ខល់ទុក្ខហ្មង់សៅ
ដោរដល់នេត្រា ៗ

ស្ងៀមស្ងួតស្ងាត់ស្ងប់ ពុំចេញសារសព្ទ សារសង់ហា
រីងក្តៅក្នុងថ្លើម ដង្ហើមទុក ទើបឈ្លោលលោមថា
សំឡាញ់បងអើយ ៗ

កុំខាងអាលោះ អាល័យសោកសោះ សោកសោកតត្រើយ
បើបងបានកើត កំណើតម្តងហើយ បងមិនគោះតើយ
ទីថៃចោលពៅ ៗ

សីមបងមកយក ប្អូនស្ងួនពន្ទក បីបមថ្នមទៅ
ដាក់លើពិមាន ទិព្វឋានខ្ពស់នៅ មូលមួយលំនៅ
នៃបរិក្ស្យស្នេហា ៗ

ចូរប្អូនស្រីស្រួល　ស្រីស្រស់ទទួល　អនុមោទនា
ព្រមព្រះនឹងបង　ដូចបងប្រាថ្នា　កុំទាន់ញញួក
បើកបងតាមចិត្ត　ៗ
ញីស្តាប់ឈ្មោលថា　ហាក់ដូរនុក　សាកាស្បើយស្បៀត
បន្ទោទុក្ខស្រាល　ស្រយាលក្នុងចិត្ត　មើលឡើយប្រឌិត
ថាតាមចិន្តា　ៗ
អ្នកមិនផ្តិលផ្តាច់　ជីវិតយកសាច់　ជាទានប្រាថ្នា
យោនយកកំណើត　កើតជាសុរិយា　ប្អូនសោកជ្រះថ្លា
សាធុនឹងអ្នក　ៗ
ជំណោរបបក　មោហាក់ព្រាក　ឈប់ស្មុះជៀងជាក់
នេះនឹងចាប់នី-　ទានពីប្រេតយក្ស　បិតបាំងសំណាក់
នៅលើបព្វតា　ៗ
យក្សនិម្មិតមក　លបមើលចចក　យក្សស្តាប់ឮថា
ចចកផ្តិលផ្តាច់　សម្រេចជន្មា　យក្សអរហើយថា
បរមលាភពេក　ៗ
ហើយយក្សនិម្មិត　បញ្ចាលក្នុងចិត្ត　ចចកឲ្យក្រោក
កាត់ចិត្តឲ្យភាន　សាច់គ្មានសល់សែក　ហើយប្រេតយក្សស្រែក
សាធុការ　ៗ

ចចកឈ្មោលញី    លុះត្រូវសម្តី    ប្រេតយក្សឲ្យសា-
ធុការជូប្នោះ    ស្រួលស្រុះចិន្តា    លន់លុះសុរិយា
អំពុអស្តង្គត ។

នាំញីចូលដេក    ក្នុងរូងដំណេក    ដូចដើមកំណត់
ទឹងថ្ងៃងងព្រៃ    ធំក្រៃប្រាកដ    ប្របន្ទោរសម្រេ
គាប់កាលនោះណា ។

មានយក្ខិនី    ប្រេតប្រាណឥតប្តី    នៅក្នុងព្រឹក្សា
យក្សត្រេចរកប្តី    ឃ្លាតខ្មីយាត្រា    បានដល់បព្វតា
ដែលយក្សប្រុសនៅ ។

យក្សស្រីឃើញម្ជប់    ត្រដាក់ចូលឈប់    បន្តិចបាត់ក្តៅ
យក្សស្រីថាអញ    ឃ្លាតខ្មាញ់ចេញក្រៅ    ដើរហាលថ្ងៃក្តៅ
សោហ្មងក្រា ។

យក្សស្រីគិតប្នោះ    ដើររកទឹកជ្រោះ    ឆ្លុះមើលមុខា
ឃើញហើយផ្សៀងផ្សង    ឈ្មៀងឈ្មង់នេត្រា    យក្សសើចហើយថា
នៅល្អដែរទេ ។

អញងូតទឹកលាប    ពកងក្អែលពោះផ្អាប    ឲ្យគ្រាន់ជាងគេ
ថាស្រេចយក្សស្រី    ឃ្លាតខ្មីឆាករ    រកជ្រោះងូតថៃ
ផុះសព្វកាយា ។

ហើយយក្សឡើងយក　សំពត់បានមក　ស្លៀកហើយយាត្រា
ដើរទៅហើយគិត　ក្នុងចិត្តយក្សថា　ចង់ព្រៀងសិនណ៎
ឲ្យបានស្បើយទុក្ខ　។
យក្សស្រីគិតព្នោះ　ចាប់ក្បិនចងចុះ　រេក្បាលងើយមុខ
គន់មើលរូបកង　ដូចពានប្រហាក់　ម៉ោះទំញិកញ៉ក់
ញាំញើដើរលេង　។
រេកកែកាំ　បាតាចទ្នាំ　ចន្ទើរចន្ទេន
អង្គុយក្ដាមចុះ　ដើងគោះជាក្ងេន　ទះដៃច្រៀងលេង
ងើកងោកសិរសា　។
ក្រឡេកស្ដាំឆ្វេង　ស្ដាប់ទៅសម្ដេង　ដូចហ៊ុនសោភា
គក្រោតគគ្រាក់　រលាក់ញាក់ស្មា　ព្វល់យក្សា
ប្រេតបិតលើក្នុំ　។
យក្សថាសម្ដេង　នរណាច្រៀងលេង　លាន់ឮធំ
ថាហើយយក្សប្រុស　ចរចុះដើងក្នុំ　ហើយយក្សសម្ងំ
លបលួចមើលមៀង　។
មើលមិញស្គាល់ជាក់　ថាអះនុយក្ស　ស្រីទៅស្រែកច្រៀង
យក្សប្រុសចង់ស្ទួច　បៀតជិតបញ្ចៀង　ផ្ទឹមផ្ទាប់ផ្ទាល់ផ្ទៀង
ឥតកស្នួរទៅថា　។

នាងស្រីក្រមុំ  រូបកាន់ឧត្តម  នាងមកពីណា
យក្សស្រីថាខ្ញុំ  ខិតខំយាត្រា  ចេញពីព្រៃក្បា
ដើររកចំណី  ៗ

យក្សប្រុសថាអើ  លាភលន់លុះលើ  បំណងសេចក្តី
ប្រាថ្នាអញបង  ចង់ចងមេត្រី  នឹងនាងប្អូនស្រី
ជាគូស្នេហា  ៗ

យក្សស្រីថាកុំ  លេងស៊ុនពេកខំ  ហៅម៉ែអញក៏
យើងមិនជាស្រី  អប្រិយ៍ទេណា  យើងមានមេបា
ពូជពង្សគ្រាន់បើ  ៗ

យក្សប្រុសថាទុ  អញបងតែក៏  ពុះពារមេតើ
ឱណាធ្វើក្រើ  ប្អូនស្រីគ្រាន់បើ  យក្សស្រីថាអើ
គ្មានធ្វើក្រើទេ  ៗ

ប៉ុន្តែមាក់ឆាយ  ហ៊ានហាះនិយាយ  ស្រដីចង់តែ
ទំលេនពាក្យជ្រៅ  អញទៅប្រាប់ម៉ែ  យក្សស្រីគិតតែ
ការគេក្ដិចិតែក្មេង  ៗ

ប្រុសថាម៉ែអញ  ព្រោះបងស្រឡាញ់  ទើបបងហ៊ានលេង
បុរសស្ត្រី  សេចក្តីចេះឯង  ហាសមិត្តមិនឈ្លេង
សង្សារសារះប្ញ  ៗ

យក្សស្រីថាស្អប់ ពាក្យប្រុសប្រសប់ ស្រដីពោលលើ
ថ្លែងចិត្តស្រឡាញ់ អស់អញឥតស្ទើ បានហើយបង្ហួសហ្វើ
តើយតោះបោះបង់ ។

ឯយក្សប្រុសនោះ បានឮដូច្នោះ សោមនស្សអស់អង្គ
អរឯងស្រួលសើច សំណើចចំណង់ ថាប្អូនវង្ស
កែវកុំសង្ស័យ ។

ចិត្តបងស្រឡាញ់ ពិតៗពេកពេញ ចិត្តជួបកិមម័យ
បងផ្ញើរបខ្លួន លើទ្រូនថ្លើមថ្លៃ លង់លុះក្សិណក្ស័យ
មរណ៍មួយមូលមិត្ត ។

ហើយយក្សប្រុសនោះ ចរចូលជិតចុះ កៀកកន្ត្រក
ដៃដល់ថនា ប្រះយាទេមផ្ចិត យក្សស្រីកាំងកិត
អៀនទុនកគ្រា ។

ព្រឹព្រួញប្រែប្រាណ រមួសស្ទោះស្ទាន ជិតដើរបញ្ចា
អស្ចារ្យកន្ទន់ ត្រេចត្រន់ត្រើបផ្កា រសាយបុប្ផា
កេសរកែរុះ ។

ព្យុះសង្ឃ្រក ពិរុណរំពក ស្រក់ស្រោចបម្រុះ
នាគភជរពេខពង់ ក្រញ្ញអង្គត្រដុះ នុទកក្បាលលូតចុះ
បូជារន្ធបញ្ចា ។

ព្រួសពិសអង់អាច    សម្តែងអំណាច    ឥតខ្លាចនរណា
ម្លូរពិសពោរពាស    ទិសពាសគ្រៀបគ្រា    ពេញព្រៃបព្វតា
ហើយសម្បុជ្រក    ៗ

ស្មេះរឿងយក្ខទុក    ថ្ងៃឯគទៅមុខ    អំពីបចក
ដេកក្នុងគុហា    ដូចពណ៌នាមក    ក្បាក់ឡើងរិះរក
គិតក្នុងចិន្តា    ៗ

បើអញបាស់ញី    ប្រាយប្រាប់អំពី    ដំណើរអញណា
ក្រែងញីឃាត់ប្រាណ    រំខានការគ្នា    នាំស្ទុខយាគ្រា
មិនដូចបំណង    ៗ

គួរអញលបទៅ    ចេញចាកប្រាកដ    រកះកើតសៅហ្មង
ចចកគិតហ្មោះ    លបស្ទុះចេញហោង    ដើរស្រួតរំលង
ដល់ជ្រងបព្វតា    ៗ

ឃើញយក្ខិនី    ប្រែប្រាណឥស្ត្រីយ    ជាខ្មោចមាយា
ភិតញ័រចំប្រប់    ស្មែងស្ងប់ពេមា    ចចកម្ចីមា
ឡើងលើថ្មផា    ៗ

ឆ្មបភ្លែកលោតចុះ    ធ្លាក់ក្នុងបាតជ្រោះ    បាក់កកាគ្នា
ក្បិណក្បែយដរ៍    យក្ខស្រីនោះណា    ឃើញហើយជ្រះថ្លា
គ្រោតឈរឡើងកំ    ៗ

(បទព្រហ្មគីតិ)

នេះបទព្រហ្មគីតិ ពិតពិនិត្យពិន័យនាំ
សេចក្ដីកែពាក្យពាំ ពាក្យពីកាលបបកនោះ ។
ក្សិណក្ស័យដីពផ្ទា យក្សម្ហីមាលោះលោតបុះ
អើសខ្មោចបបកនោះ នាំប្រពន្ធបរិភោគា ។
ស៊ីសាច់ហែកហុតឈាម ហូរហាមពេញមុខា
ឈាមស្រក់ទៅត្រង់ណា យក្សទុនលិទ្ធឥតមានសល់ ។
ឆ្អឹងឆ្អែងយក្សទំពា ត្រង់លោកក្បាលសំណល់
បរិភោគឆ្អែតស្កប់ស្កល់ នាំប្រពន្ធវិលបាំនបិត ។
រីឯខ្មោចបបក ស្លាប់ទៅយកជាតិដូចចិត្ត
កើតជាព្រះអាទិត្យ រុងរឿងរះត្រចះថ្លា ។
ចុំថែងថែងប្រាលឆ្អៅ ភ្លឺសន្សៅទាំងលោកា
សក្ដិសិទ្ធិវិទ្ធិចេស្ដា បរិហារហោយសម្រាប់បុណ្យ ។
ហេតុផលបបកបាន សាច់ឲ្យទានមកពីមុន
ជួយជូនកើតដោយគុណ បុណ្យចិត្តកាត់ឥតសង្កា ។
សុរិយាបបកគិត អភេក្ខចិត្តឥតឧបមា
ជានុក្ដីប្រាថ្នា អង្គអញអើយឆាប់ឆុតក្រៃ ។

ម្ល៉េះហើយគ្មាននរណា ជុំមបេស្កាមានគេជៃ
រុងរឿងថ្កើងជោគជ័យ នៃអង្គអញពេញក្លៀវក្លា ។
រីន័យដំណើរនេះ ទឹងឈប់ស្ទុះពុំចរោ
ចចកសែនសុំរោ ខណ្ឌខានទុកពុំស្រដី ។
ទើបទឹងនិទានពី ចចកញីភ្ញាក់ឡើងខ្ញី
ឈ្មោលប្ចាត់អគ្គីគ្គី ញីតែរកក្រមា ។
ស្រង់ក្លិនរកតាមផ្លូវ ដល់ជ្រោះជ្រៅឃើញសិរសា
សំណល់យក្សភោគា ញីប្រេះប្រាណដួលសន្ធប់ ។
កាន់កាំងគាំងស្មារតី អស់ឥន្ទ្រីយញីចប្រប់
ដង្ហើមហួតប្រសប់ ប្រដេញខ្យល់សល់សែនទុក្ខ ។
ហើយហៀបហក់ទឹងក្ស័យ ក្សិណប្រល័យជនជីវ៍
ស្ងួន្យស្ងិនស្ងុំនៅទី ជ្រោះដែលឈ្មោលក្ស័យនោះណា៎ ។
លុះបានដឹងស្មារតី ភ្ញាក់ឥន្ទ្រីយខ្ញួញ.ទៅថា
ឱអ្នកប្រុសស្នេហា ម្ដេចអ្នកមកក្ស័យបង់បាត់ ។
ចាកចោលប្អូនស្នា នៅកំព្រាស្ងៀមស្ងប់ស្ងាត់
និរាសប្រាសព្រាកព្រាត់ ផុតពីទ្រង់ប្អូនទៅហើយ ។
តាំងពីថ្ងៃនេះទៅ សមប្អូននៅឯងឥតត្រើយ
អ្នកប្រុសថ្លៃប្អូនអើយ ប្អូនទៅរកអ្នកឯណា ។

ឲ្យដូចប្រុសវរមិត្ត មិត្តខ្ញុំចិត្តឥតសង្កា
ប្អូនបីនផ្ញើប្រាណ ដូនជីវិតនឹងអ្នកថ្លៃ ៗ
មេត្តាអ្នកពោលប្អូនទៅ ឲ្យប្អូននៅកំព្រាក្រៃ
ឥតពឹងឥតអាស្រ័យ ព្រោះបងបាត់ស្ងាត់ទៅហោង ៗ
សូវក្ស័យជីវិតទៅ ជាជាងនៅកើតសៅហ្មង
ទល់ទុក្ខចប់បង់ រងលំបាកលុះអស់កាល ៗ
ធ្លាប់ផឹកធ្លាប់ភោគា ធ្លាប់ចរចាធ្លាប់ស្និទ្ធស្នាល
ធ្លាប់នៃបធ្លាប់ត្រេកអរ ធ្លាប់មេរសមេមណ្ឌល ៗ
ឥឡូវអ្នកប្រុសព្រាស ព្រាសនិរាសពិតពុំយល់
អ្នកហើយសមប្អូនទល់ ទុក្ខកណ្ដែងកណ្ដាលព្រៃ ៗ
គាំងទ្រូញយំព្រលប់ លុះដូចចប់ចូលដល់ថ្ងៃ
រៀងរះព្យាស់ព្រឹកព្រៃ ព្រឹកព្រាងស្ងាងសែនសុរិយោ ៗ
ចចកយំញាំថ្ងៃផាក់ ថានុអ្នកប្រុសស្នេហា
អ្នកបានជាសុរិយោ រុងរឿងរះត្រចះនៅ ៗ
អ្នកយកប្អូនទៅផង សិទ្ធស្នេហ៍ស្ងួនខែបនិត្យនៅ
លើឋានទិព្វសនៅ សោះហ្មងសៅសែនទុក្ខា ៗ
ចចះញ៉ូញញ៉ាំទៀត ដឹងចង្អៀតតក់ទុក
ប្រះព្រាណសែនសោកា សែនអាណោះអាល័យលន់ ៗ

ពីព្រឹកលុះដល់ត្រង់ សោកសូន្យសុងទល់ទុក្ខធំ
លុះថ្ងៃទេរទាបទន់ ទាបទៅទៀតចុងព្រឹក្សព្រៃ ៗ
ក្អួចផឹកក្អួចភោគ្គា អត់ភោជនាស្គមសន្ធៃ
សន្ទឹកទឹកអាល័យ ទៀនខ្ញួញទៀតដួលប្រះប្រាណ ៗ
ថាទ្រព្រះសុរិយា សូនស្នេហាមិត្តកល្យាណ
ជ្រៀងជ្រៃបរបៀតបាន បៀតទៅទៀបចូលសន្ធ្យា ៗ
អ្នកអើយប្អូនក្តៅក្តាត់ ថ្មើមប្រមាត់ឈើផលផ្កា
ដូចអ្នកយកខាន់ថ្វា កាប់កាត់ប្អូនអស់ពង់សោះ ៗ
ចចកញីសន្ធប់ ញីរចិប្រប់សូន្យស្ងួនសោះ
ដួលដេកនៅទីនោះ លុះព្រលប់ចូលសន្ធ្យា ៗ
សនៀមធ្លាក់ចុះត្រង់ ជ្រាបជោគអង្គសត្វរោមា
ត្រជាក់អស់អង្គា ភ្ញាក់ឡើងខ្ញួញសែនសល់ខ្លាក ៗ
ខ្ញួញតាំងពីព្រលប់ លុះខ្ជួបចប់ចូលអធ្រាត្រ
តារារះគ្រាងគ្រាត ភ្លឺត្រចះពេញមេឃា ៗ
ចចកមៀងមើលផ្កាយ ពុំសប្បាយថែមទុក្ខា
ថាខ្ញុំផ្កាយនេះណា ជាបរាំងភ្នែកប្រុសគន់ ៗ
ប្អូនឃើញតែបរាំង ផ្កាត់សង្ក្រាប្រុសល្អួសល្អន់
អ្នកអើយប្អូនគយគន់ រកមើលមិនឃើញអ្នក ៗ

ចចកខ្ញុំទល់ទុក្ខ　　គ្មានសាន្តសុខស្លុយអន់អាក់
លុះព្រឹកព្រាងស្វាងជាក់　　ទៀងខ្ញុំទៀតសព្វវេលា ។
មួយថ្ងៃខ្ញុំបីដង　　រឹងរឹតរឹងទុក្ខវេទនា
មួយយប់ខ្ញុំបីគ្រា　　ជានិរន្តរ៍តរៀងទៅ ។
ពុំផឹកពុំបរិភោគ　　ស្គមស្គាំងស្គោកជោកជាំទៅ
កម្លាំងថយតិចទៅ　　ខ្សោយតាមទន់ពន់ប្រមាណ ។
ដើរដួលទាំងដំហរ　　ទីងគ្រាំឈរដេកពុំបាន
ក្បិណក្បួយចាកពោលឋាន　　តាំងទម្ងន់ពោរពេញពោះ ។
ដំណើរចចកញី　　ក្បួយជីវិតក្នុងគ្រានោះ
ឈប់ស្ងួនទៅនេះចុះ　　ទីងនិពានឯសុរិយា ។
រុងរឿងរង្វើរង្វៀ　　ស្វាងរស្មីក្នុងលោកា
ដួបដួនបុប្ផាសា　　មានពពកមកបាំងបិទ ។
បាំងថែងសែងសុរិយ៍　　អំព្យរស្មីជុំជុកជិត
បាត់វង់ព្រះអាទិត្យ　　ពេញមណ្ឌលទល់មេឃា ។
ក្បិណនោះអង្គសុរិយា　　ចចកណាទ្រង់គ្រោធា
ជាហើយលើកហត្ថា　　ស្ទុះគ្រហ៊ាហាកពីមាន ។

## បទពំនោល

នេះបទពំនោលនិទាន៍ ដំណើរដោយដាន ឯឫទ្ធិបកសុរិយា ។
ក្រេវក្រោធលោលោតស្ទុះស្ទា តប់ទះហត្ថា ក្រឡេកក្រឡៅប្រឹងប្រាណ ។
ថាយើរណាហៅហាន ប៉ាំងមុខអញបាន ទទឹងទទែងមីរមក ។
មើលដាក់ថាយើពពក ហ៊ានដាសពាសមក គបគគបៈទឹងអញ ។
អើយើងមិនញ៉ុមពុះចាញ់ តយុទ្ធវិលវិញ ឲ្យដឹងៈគដៃឥឡូវ ។
សុរិយាប្រឹងចែងចាំងទៅ ពពកទឹងនៅ ពុំមានកក្រើកទៅណា ។
ប៉ាំងបិទជុំជិតសុរិយា រឹងក្រេវក្រោធា ថាអះអង្គអញសព្វថ្ងៃ ។
មិនមាននរណាមួយក្រៃ ផ្ទឹមស្មើគេដៃ ប្រឡងអំណាចខះខែង ។
មានតែអង្គអញឯកឯង ជាធំចំពែង ចំពោះឥតគូផ្ទឹមបាន ។
ឥឡូវពពកសាមាន្យ ប៉ាំងសែងសូរ្យធាន ជុំជិតងងឹតមេឃា ។
អះអញលែងជាតិសុរិយា ហើយសូមប្រាថ្នា កើតជាពពកធុតធាប់ ។
ដេរដាសពេញពាសខ្ពន់ខ្ពប់ សុរិយាអន់អាប់ ងងឹតងងល់ណាស់ណា ។
ពពកបកការឡា អរឯងមហិមា ស្រួលសើចសំណើចក្អាកក្អាយ។
ថាអើនេះហៅសប្បាយ លើសលែងសព្វសាយ ស័ក្តិសិទ្ធិរឹទ្ធិចេស្តា ។
អង្គអញលើសលែងលោកា ម៉េះគ្មាននរណា ជាគូតតបប្រឿងរឹទ្ធិ ។
អញបាំងសូរ្យសែងព្រះអាទិត្យ ដេរដាសងងឹត គ្មានរឹទ្ធិស្មើអញឡើយណា ។
កាលនោះវេវស្សា មានព្យុះព្យាមា សន្ធឹកសន្ធាប់ខ្លាំងក្រៃ ។

បក់បោកលោកជលស័យ បាក់មែកឈើព្រៃ រលំរលើងព្រៀបព្រា ។
ផាត់ផាយផុយផង់ពសុធា ផ្សែងផ្សព្វមហិមា ទះផ្គាលទង្គឹមីរមក ។
បក់ដល់សុរិយាពពក ផាត់ផាយបាចបោក បាត់បង់ពុំគង់បុនល្អង ។
សុរិយាពពកនោះហោង ក្រោមព្រៃគគ្រង ថាយើអគ្គអញសព្វថ្ងៃ ។
មិនមាននរណាតដៃ ឥឡូវនេះព្រៃ មានខ្យល់ដ៏ខ្លាំងបក់ផាត់ ។
កើតជាពពកខ្សោយក្តាត់ អញចង់គិតកាត់ ជាតិជាពពកហោលហេញ ។
ប្រាថ្នាកើតជាខ្យល់វិញ ខ្យល់នេះគ្មានចាញ់ គ្មានខ្លាចអំណាចនរណា ។
កាលនោះពពកសុរិយា តាំងចិត្តប្រាថ្នា កើតជាវាយោផាត់ផាយ ។
ផាត់ផង់ធូលីខ្ចាត់ខ្ចាយ ព្រឹក្សាអន្តរាយ រលីករលំគ្មានសល់ ។
ញាប់ញ័រប្រឹថពីមណ្ឌល បោកបក់ទៅដល់ ដំបូកធំស្កុកខ្ពស់ខ្ពង់ ។
ខ្យល់បក់ធាបធក់ត្រូវត្រង់ ដំបូកនៅគង់ ដំហរដំហើមទប់ទល់ ។
នៅនឹងបីទ្រមឹងដួចដល់ ឥតមានអំពល់ កក្រើកអំពើកឡើយណា ។
វាយោពពកគិតថា យើងមានទទរណា មកទល់អគ្គអញជាខ្យល់ ។
អញបក់ព្រឹកព្រៃគ្មានសល់ ប្រឹថពីមណ្ឌល ញាប់ញ័ររន្ធត់ណាស់ណា ។
ពោះទឹកសមុទ្រគង្គា អញបក់បែកជា រលករលាមគ្មានសល់ ។
កាលនោះវាយោគិតឆ្ងល់ ក្នុងចិត្តខ្វាយខ្វល់ ថាអះដំបូកស្កុកស្កឹង ។
ដំហាមគ្រមាមបីទ្រមឹង ទ្រមឹកស្កឹកស្កឹង រឿងរេងមិនចាញ់នរណា ។
ឈ្មោះអញជាមហាវាតា ព្រោះអញប្រាថ្នា កើតជាដំបូកវិញចុះ ។

រាយោពពកគិតហ្វោះ លែងជាតិខ្យល់នោះកើតជាដំបូកស្កុកស្គឹង ។
ព្រងើយព្រមើយព្រមឹង ខ្យល់បក់ទៅទិង មិនមានកម្រើកដល់តិច ។
ពោះបីខ្យល់ព្យុះម្តេចៗ បក់ហោកខ្លាំងតិច ដំបូកក៏នៅទឹងថ្កល់ ។
ដំបូកចចកឥតធ្លល់ ថានេះត្រូវកល់ ចិត្តអញប្រាថ្នាមួនមាំ ។
ខ្យល់ព្យុះបក់ចុះគគ្រាំ ភ្លៀងគួរជោគជាំ អញទ្រាំអញទ្រទ្រង់បាន ។
កាលនោះមានសត្វតិរច្ឆាន ក្ដាន់ព្រោសមួយមាន ហ្វូងក្ដាន់ដើរតាមត្រៀបត្រា ។
ក្ដាន់ដល់ដំបូកនោះណា ចូលលិទ្ធភោក្តា ខ្ទះវ័ធខ្ទះដល់នោមជុះ ។
ខ្ទះកាយរលាយរលុះ ដំបូកធំនោះ ពុំអាចទ្រាំទ្រនៅបាន ។
ដីជ្រាយធ្លុះធ្លាយចេញថ្កាន ក្ដាន់លែងជាណាន រលំដំបូកនោះទៅ ។
ចចកដំបូកនោះក្បូ ខេរខឹងក្រញូវ ក្រញ៉ងអង្រួនសិរសា ។
ដំបូកចចកគិតថា អញចង់ប្រាថ្នា ទៅកើតជាក្ដាន់នោះវិញ ។
គិតហើយប្រែប្រាណចាកចេញ ពីដំបូកមិញ ទៅកើតជាក្ដាន់ដូចចិត្ត ។
ក្ដាន់ដើររកស៊ីឆ្ងាយជិត ឥតមានភ័យកិត ក្នុងចិត្តត្រេកអរគិតថា ។
អញបានដូចចិត្តប្រាថ្នា ម៉្លេះគ្មាននរណា ជាពីរទឹងអញទៀតទេ ។
ប្រទះក្ដាន់ព្រោសនៅឯ ព្រៃផលពាល់តែ បាលបាញ់រត់ខ្ញាញ់ចូលព្រៃ ។
ដំណើរក្ដាន់ព្រោសនោះនៃ ឈប់ស្ទះវិលវៃ ពុំមានទិទានឡើយណា ។

## បទកាកគតិ

នេះនឹងប្រែបទ កាកគតិកំណត់ កំណាព្យបរោ
គេកាលនោះមាន ព្រានព្រៃមួយណា ត្រេចត្រង់យាត្រា
រុករកបាញ់ ។
រូបភងកំប៉េស កំប៉ោងក្រញេស ក្រញិញក្រញ៉ាញ់
ក្រញូវក្រញើត ក្អែកស្មើតសក់ព្រាញ់ ក្ដួចចាក់កណ្ដាញ់
កណ្ដបពងពាស ។
ព្រានដើរត្រុក ព្រៃស្បាតភនរុក រកបាញ់រមាស
រមាំងប្រើសក្ដាន់ កាប់កាន់បេញពាស រកស៊ីដើរដាស
ក្រហាមតាំងព្រៃ ។
រីក្ដាន់ដំបូក រូបភងធំស្ដុក ការហ៊ុនរំពៃ
មានក្ដាន់ទៀងក ចូលមកពក់ពៃ ក្ដាន់ដេញកិតក័យ
ចូលជិតពុំបាន ។
រីឯព្រានព្រៃ ឃើញក្ដាន់ធំក្រៃ អរពន់ប្រមាណ
តម្រង់ស្នាក្រិត ក្រអឹតប្រុងប្រាណ លុះលបឈរឈាន
ដើរទាតិចទៅ ។

លូនវារចូលជិត　　វិក្កមាន់ព្រានបិទ　　ម្ខាងបើកក្រឡៅ
ក្រឡេកមិចមៀវ　　ស្រងៀវសំងៅ　　សម្រុកត្រង់ទៅ
លោះកៃស្នាក្បត់　　ៗ

ត្រូវត្រង់ជាន់ឡើង　　ក្ដាន់ដួលបះជើង　　ស្ទុះក្រោកឡើងថ្ងាត់
ឈើគៀបផ្សាយផ្សា　　ឧកក្ដៅក្ដាត់　　ជរធក់វាកាត់
ថ្លើមធ្លុះធ្លាយចេញ　　ៗ

ឈាមហូរច្រាសច្រាល ទំនៃងរន្ទាល　　ជោរជនពាសពេញ
ប្រឹងប្រែបែរបោល　　ដួលជ្រោលចុះវិញ　　ដង្ហើមប្រដេញ
ញាក់ញ័រអង្គា　　ៗ

ក្ដាន់គិតរំពឹង　　ថាអញនេះនឹង　　ក្ស័យពោលរូបា
បើអញនឹងក្ស័យ　　ប្រល័យជន្មា　　សូមតាប់ជាតិជា
បន្ទោះស្នាវិញ　　ៗ

ក្ដាន់គិតតែម៉្លោះ　　ក្សិណក្ស័យសូន្យសោះ　　ក្រឡាប់ជាតិចេញ
ពីក្ដាន់ចបក　　ផ្លោះផ្លុកវិលវិញ　　វិលវឹងមកមិញ
កើតជាព្រ័ត្រស្នា　　ៗ

រីឯព្រានព្រៃ　　ឃើញក្ដាន់ក្សិណក្ស័យ　　ព្រានចូលម៉្មា
ពន្លះយកសាច់　　សម្រេចភោជនា　　ឆ្អឹងឆ្អៃងលោ
ក្បាលព្រានពោលចេញ　　ៗ

រួចហើយព្រានទៅ ផ្ទះវិលនៅ ព្រានជួបដើមវិញ
មានកាលមួយថ្ងៃ ព្រានព្រៃចេញ ទៅរកបាញ់
សត្វជួបសព្វគ្រា ។
ពុំបានសត្វសោះ វិលមកពីនោះ ព្រានគន់គិតថា
អញដើរចេញ រកបាញ់ម្រឹគា សព្វថ្ងៃហាក់ជា
មានជ័យមានលាភ ។
អះឱអញស្តាយ កាលអញស៊ីបាយ ភ្លេចថ្វាយបាយ៉ាប
ហេតុនេះអញស្វែង ភ្នែងឥតលាភ ណ្ហើយបុះបាយ៉ាប
ថ្ងៃក្រោយសឹមថ្វាយ ។
ហើយទើបព្រានព្រៃ ធៀងភ្នែករំពៃ ព្រឹក្សាតាំងឡាយ
មានមែកសាខា បុប្ផារីករាយ ភ្នកទឹកសប្បាយ
ក្នុងចិត្តគិតថា ។
ខអស់ផ្កាផង ក្រអូបកខ្វង់ សប្បាយណាស់ណា
អញចង់ច្រៀងជ្រង បានម្តងទៅកី ហើយព្រានច្រៀងថា
ទំនុកស្និទ្ធស្នេហ៍ ។
ជ្រងអើយនាងជ្រង បងចេញបាញ់ម្តង ត្រកាលជាងគេ
ភ្នែងអប្រិយ បានអ៊ីផ្ញើមេ វិលវិញទទេ
លិទ្ធដេះដើក្រាន ។

ស្រែកប្រៀនបណ្តើរ ក្រោកឡើងដើរ មើលខ្លួនប្រាណ
មុខស្ងួញមាត់ស្ញេញ សង្កេញដូចបាន ព្រានប្រៀនកំសាន្ត
ដើរដោយមាគ៌ា ។

លុះបានដល់ម្លប់ ជ្រៃមួយចូលឈប់ ចូលបតនិទ្រា
នៅក្រោមម្លប់ជ្រៃ ព្រានព្រៃផ្អែកស្នា ប្រុបគល់ព្រឹក្សា
ដេកលង់លក់ទៅ ។

មែនមានបបក កំព្រយកំព្រក កំព្រឹងហង្សសៅ
ចេញពីព្រឹក្សា ម្ចីមាចូលទៅ ត្រង់ព្រានដេកនៅ
ក្រោមម្លប់ជ្រៃនោះ ។

បបកថាព្រាន រាបាញ់មិនបាន សត្វមួយដល់សោះ
អញចាំគោក្ដា ដោយសារព្រាននោះ ថ្ងៃនេះខែងសោះ
គ្មានអ្វីគោក្ដា ។

បបកមើលទៅ ឃើញស្នាផ្អែកនៅ គល់ជ្រៃសាខា
បបកថាទុ លាគោលាកា អញទៅចំពា
បន្ទោះស្នានោះ ។

អន្ទៀមស៊ីលេង កុំឲ្យរាំខែង រាបង់ជើងសោះ
បបកចំពា ព្រឹត្រស្នាក្រៀមក្រោះ ពាល់ជ្រាយដាច់ស្នោះ
ស៊ីថាគោក្ដា ។

ឯគ្នាធំនោះ　ប្រាជ្ញាចំពោះ　កើតជាព័ត្រស្នា
លុះផលបបក　កំព្រកមោហា　ទំពាព័ត្រស្នា
ជាប់ទៅដូច្នោះ　។

វែងទីងគ្នាន់ខ្លាញ់　គិតជាអគ្គអញ　កើតជាបន្ទោះ
ស្នានេះមានរិទ្ធិ　ស័ក្តិសិទ្ធិចំពោះ　ឥតគេស្មើស្មោះ
ផ្ទឹមទឹងអញបាន　។

ឥឡូវបបក　នេះតើរមក　ពីណាហៅហាន
ចូលមកទំពា　ព័ត្រស្នាជាប់បាន　បបកនេះមាន
អំណាចជានា　។

បើហ្នោះគួរអញ　ប្រាជ្ញាវិលវិញ　យោនយកជាតិជា
បបកទើបបាន　មែនមានបុត្រា　គិតស្រេចការឡា
ក្រឡាប់ជាតិទៅ　។

កើតជាបបក　កំព្រយកំព្រក　កំព្រើលហ្វងសៅ
ដូចដើមដែលវិញ　គៀទេញតាមទៅ　ព្រោះលោកកម្មៅ
កម្ចាំងមោហោ　។

លោកលន់លើសលែង ហេតុកម្មនោះឯង　នាំឲ្យប្រាជ្ញា
កើតជាបបក　កំព្រកនោះណា　ឥតគេស្នេហា
ជាមិត្តនិត្យនៅ　។

ហេតុនោះពាក្យព្រេង ព្រឹទ្ធប្រាជ្ញទុកតែង ទូន្មានកូនចៅ
ឲ្យប្រែលះលាក ចេញតាកពោលទៅ កូនអើយនេះហៅ
គំនិតឆ្កែតឿ ៗ
ទុកតជាច្បាប់ ទៅមុខគ្រាន់ត្រាប់ គ្រាន់ត្រង់កុំធ្វើ
កុំឲ្យចូលចិត្ត គំនិតឆ្កែតឿ គួរចាំគួរជឿ
គួរចៀសឲ្យឆ្ងាយ ៗ
កុំត្រាប់ចចក មោហាកំព្រក កំព្រើលអន្តរាយ
លោកក្រៅគន្លង អ្នកផងទាំងឡាយ លោកលុះអន្តរាយ
ជាតិជួរប្រើយ ៗ

## បទព្រហ្មគីតិ

នេះបទព្រហ្មគីតិ ចប់ដុំដិតជូនសេចក្ដី
ល្បិចល្បើកលើកជាថ្មី ពីដំណើរសត្វចចក ៗ
ចែងចប់គ្រប់និទាន ពីបុរាណមានរៀងមក
និយាយពយកប់រក ជាតំណាតទៅមុខ ៗ
លើកគ្រាន់មើលកំសាន្ត គ្រាន់ទីងបានកែអផ្សុក
ជាកេរ្តិ៍តទៅមុខ មានប្រការជួរចេះស្រាប់ ៗ
ព្រះពុទ្ធ(១)សករាជគ្រាន់ គ្រប់ពីរពាន់បួនរយកប់
វស្សាប្លាយឯកសព្ទ ខែកន្ទង់ជប់មាសា ៗ

---

១- ព.ស. ២៤១៧ គ.ស. ១៨៧៤ ។

ថ្ងៃបានម្ភៃប្រាំកើ ក្នុងឆ្នាំបឆសកា
ហេមន្តរដូវជា ខែផល្គុនខាងឯខ្មែរ ។
ថ្ងៃព្រហស្បតិ៍ វេលាទីដប់ពីរកើត
ពាក្យពេចន៍ពោលពុំជើត ខុសខាតជួនផ្លួនមិនសម ។
នាមខ្ញុំឈ្មោះសោតសឹង អ្នកផងដឹងមិនប្រឡំ
អក្សរត្លួ ម ចំ ដើមបុកក្រោមដាក់ កា មុខ ។
ហើយគួសលើពីរផង តាមទំនង់អ្នកប្រាជ្ញទុក
ឲ្យរៀនជាទំនុក ចិត្តសម្គាល់ត្លួអក្ខរ ។
បើលោកណាមើលមៀង កុំក្លួចដៀងដៀលនិន្ទា
ឆ្នាំឆ្គងពាក្យត្រង់ណា ជួយតម្រង់ផងឲ្យមាន ។
សូមរេបបទបរិយាយ ជានិយាយពីបុរាណ
រៀងមកឯវិមាន ប្រការដូច្នេះឯងហោង ។

## កំណត់សម្គាល់:

តាមសេចក្ដីបញ្ចប់នៃពាក្យកាព្យ “ល្បើកបចក” នេះ នាំឲ្យយើងស្គាល់ថាជាស្នាដៃលោកឧកញ៉ាសុន្ទរវោហារ ម៉ុក ដែលបានតែងឡើងតាមតម្រាយរឿងចាស់ គឺរឿងថ្កែតៀ ។ លោកបានតែងពីថ្ងៃ ១២ កើត ខែផល្គុន ឆ្នាំ ចឆស័ក ព ស ២៤១៧ ។

ដើម្បីប្រមូលទុកនូវស្នាដៃរបស់កវីធំគ្រកាលនេះ យើងក៏បានចម្លងចេញពីក្បាប់ស្លឹករឹតមកបោះពុម្ពក្នុងពេលនេះ ទុកជាហិតប្រយោជន៍សម្រាប់អ្នកស្រាវជ្រាវអក្សរសាស្ត្រជាតិ ។

ល.ឆ.ត.

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា

## នូ - កាន

## ប្រែ - រៀបរៀង

(ត)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ  អ្នកភាន់វៃឆ្លាតបើបានអាន
> នឹងចេះឧបាយកលចំណាន  ទាំងមានសត្តានស្នេហាជាតិ
>
> យូរ-អ៊ុន

កៀនអ៊ុយ បានស្តាប់សព្វាក្យខុនបេងពោលដូច្នោះ ក៏ចុះចិត្តគិតឃើញផែនឆ្ងាយ, សេចក្តីទោមនស្សក៏ស្រាយពីហទ័យទៅ ជ្រះថ្លា លើកហត្ថានុទគំនាប់ខុនបេងទៀបបាទដោយអភិវាទគោរព, ខុនបេងក៏ទាញដៃកៀនអ៊ុយឲ្យក្រោកឡើង ឲ្យអង្គុយសិប់លើរទេះជាមួយគ្នា ហើយបរម៉ឺមៗត្រឡប់ទៅក្នុងបន្ទាយ កាលចូលទៅដល់ទីសម្នាក់ហើយ ខុនបេងក៏ឲ្យរៀបអាហារលើតុតាំងអញ្ជើញកៀនអ៊ុយបរិភោគសេពសុរា, ខុនបេងក៏ធ្វើបដិសណ្ឋារៈពិគ្រោះនឹងការយកស្រុកគៀនស៊ុយ និងស្រុកសៀងផង ព្រោះយល់ឃើញចិត្តកៀនអ៊ុយមិនប្រែផ្សេងពីគ្នា ។ កៀនអ៊ុយឆ្លើយថា ឈ្មោះអ៊ុនឆៀង និងលៀងស៊ុំដែលជានាយទាហានទៅក្នុងស្រុកគៀនស៊ុយនោះ ជាកឿនទុក ទុកចិត្តរបស់ខ្ញុំបាទ ។ នឹងធ្វើកលឧបាយឲ្យឈ្មោះទាំង ២

នាក់ស្ម័គ្រចិត្តមកចូលនៅនឹងមហាឧបរាជឲ្យបាន, ឧបាយនោះ ខ្ញុំបាទនឹងគិតគានសរសេរជាសំបុត្រ ២ ច្បាប់ ចងនៅចុងព្រួញហើយបាញ់ចូលទៅឲ្យអ៊ុនធៀននិងលៀងស៊ីធ្វើកលសឹកខាងក្នុងស្រុក សឹមយើងលើកទាហានពានសម្រុកពីទ្វពីក្រៅចូលទៅ គង់នឹងបានដោយងាយ ។

ខុងបេងឮដូច្នោះ ក៏យល់តាម ។ ទើបកៀងអ៊ុយសរសេរសំបុត្រភ្លាមបាន ២ ច្បាប់ ចងនឹងចុងព្រួញភ្ជាប់រួចហើយ ក៏ឡើងសេះ បរសំដៅទៅដល់ជើងកំពែង, លើកធ្នូឡើងត្រៀងបាញ់ចូលទៅ ។ ទាហានក្នុងស្រុកដែលនៅល្បាត ឃើញហើយក៏យកសំបុត្រនោះទៅឲ្យម៉ាជុន ។ យកទៅមើលដឹងសេចក្ដីក៏សង្ស័យណាស់ , និយាយនឹងហៃហ្វូលីមថា: អ៊ុនធៀននិងលៀងស៊ីពីរនាក់នេះ ហើយនឹងកៀងអ៊ុយនោះ ជាមនុស្សមិត្តភក្ដិនឹងគ្នាមកពីដើម, ឥឡូវនេះ អ៊ុនធៀនហើយនឹងលៀងស៊ីប្រែចិត្តគិតអាក្រក់ធ្វើជាកលសឹកខាងក្នុងហើយ តើយើងនឹងគិតប្រការម្ដេច ?

ហៃហ្វូលីមឆ្លើយថា : អ៊ុនធៀន, លៀងស៊ី ទាំង ២ នាក់នេះ នៅក្នុងកណ្ដាប់ដៃយើងហើយ, យើងត្រូវឲ្យបម្រើទៅហៅយកខ្លួនមកដោយឧបាយបញ្ឆោតកុំឲ្យដឹងខ្លួន, បើមកដល់ហើយ ត្រូវចាប់សម្លាប់ចោលទាំង ២ នាក់ទៅ ទើបអស់បម្រុងចម្រាស, មនុស្សទំនុកទុកចិត្តរបស់អ៊ុនធៀននៅជិតនោះ, លុះបានឮជាក់ ក៏លបលាក់គេចខ្លួនទៅប្រាប់អ៊ុនធៀន ។ ក៏រាងចុះទៅប្រាប់លៀងស៊ី តាមដំណើរហេតុគ្រប់ប្រការ ហើយថា :

យើងនឹងសៀមនៅម្ដេចបាន ប្រាណនៃយើងគង់នឹងស្លាប់អាសា, ត្រូវតែយើងរកឧបាយប្រញាប់លបចេញទៅស្រុកនៅនឹងខុងចេងវិញ ទើបរួចក្យន្តរាយ, លៀងស៊ុបានស្ដាប់ ក៏ចាប់ចិត្តគិតឃើញត្រូវណាស់, លុះវេលាយប់ ហៃហ្លូលឹមឲ្យបម្រើមកហៅលៀងស៊ុ - អ៊ុនទៀង ជាច្រើនសា ដើម្បីនឹងប្រឹក្សាការរាជការ, អ៊ុនទៀង - លៀងស៊ុ ក៏ពុំបាននៅ នៅតែពិគ្រោះគិតគ្នាថា យើងនឹងទៅឥឡូវនេះ មុខជាម៉ាជុននឹងសម្លាប់យើងហើយ, យើងកុំទៅឡើយ គួរនឹងគិតរកឧបាយដោះខ្លួនឲ្យរួចទៅបុះ, លុះពេលយប់ស្ងាត់ អ៊ុនទៀង និង លៀងស៊ុ ទាំង ២ នាក់ ក៏លបលាក់នាំទាហានដែលទុកទុកចិត្ត ១០ នាក់ ចេញទៅបើកទ្វារទទួលខុង-ចេងចូលទៅក្នុងស្រុកបាន ។ ហៃហ្លូលឹម និង ម៉ាជុន ឃើញពួកទា-ហានកងទ័ពខុងចេងចូលស្រុកបានដូច្នោះ ក៏ភ័យរលះរលាំង នាំទាហានសម្រាំងប្រមាណ ១០០ នាក់ រត់ចេញទៅតាមច្រកទ្វារទិសឯលិច គេចគម្រង់ទៅស្រុកកៀងសៀ ។

លៀង ស៊ុ និង អ៊ុនទៀងទទួលខុងចេងនាំទៅតាំងទ័ពប្រថាប់នៅក្នុងស្រុកហើយ ក៏បញ្ចុះបញ្ចូលកស្ត្រប្រជាឲ្យនៅជាប្រក្រតីធម្មតា, ខុងចេងក៏ពិគ្រោះប្រឹក្សាការផែនដី នឹងនាម៉ឺនមុខមន្ត្រីនាយទាហានថា : ធ្វើម្ដេចយើងនឹងវាយយកបានស្រុកសៀងចេងបាន, លៀងស៊ុឆ្លើយថា : លៀង-ខៀនដែលនៅឈរក្សាស្រុកនោះជាប្អូនខ្ញុំបាទ ។ និងស៊ុយកសាសាទៅ

ល្បួងលួងលោមលៀងខៀនឲ្យមានចិត្តស្ម័គ្រមកចូលខាងមហាឧបកដ ឲ្យ
បានទាំងស្រុកនោះផង, ខុនបេងពុទ្ធដោះ ក៏សោមនស្សពេកណាស់,
ប្រើឲ្យលៀងស៊ីរួតរះចេញទៅដល់ស្រុកសៀងតេង, លុះទៅដល់ហើយ
ក៏ចូលទៅជួបនឹងលៀងខៀន, បានសន្ទនាគ្នាដោយពាក្យល្បួងលួងលោម
តាមឧបាយ; លៀងខៀនក៏រួសរាយស្រាកស្រួលទទួលការ រួចទើបនាំ
គ្នាចូលមកគំនាប់ខុនបេង ៗ ក៏ទទួលសាទរមហិមា ឲ្យទ្រព្យជាបំណាច់
ដល់លៀងស៊ី, លៀងខៀន និងអ៊ិនចៀង យ៉ាងគួរសមដោយច្រើន រួច
ហើយ តាំងលៀងស៊ីជាទីចៅហ្វាយស្រុកតៀនស៊ុយ, តាំងលៀងខៀនជា
ចៅហ្វាយស្រុកសៀងតេង, តាំងអ៊ិនចៀងជាចៅហ្វាយស្រុកអេកគួន ៗ

ទាហានទាំងឡាយ ក៏និយាយសាកសួរខុនបេងថា : មហាឧបកដ
បើកវៃងហៃហួលឹមទៅវិញ ដោយប្រយោជន៍អ្វី ? ខុនបេងឆ្លើយថា:
យើងបើកវៃងហៃហួលឹមទៅវិញ ព្រោះឃើញបំណាញបានកៀងអ៊ុយ
ម្នាក់ ដូចបានសត្វពាហនៈ ១ ឲ្យបម្រើនការគ្រប់ជំពូក, វៃងហៃហួ-
លឹមទៅ ដូចលេងមាន់គក ១ ប៉ុណ្ណោះ, ស្លាប់បាំងចង់បាត់ទៅ បំពោះ
ទីងរកនរណាជំនួសគ្មានឡើយ; បានកៀងអ៊ុយមកហើយ ដូចជាបាំងចង
រស់ឡើងវិញដូចគ្នា, បណ្ដាពួកពលយោធាឮខុនបេងថាដូច្នោះ ក៏ក្រាបចុះ
ព្រមគ្នា សរសើរតម្រិះប្រាជ្ញាខុនបេងថា : មហាឧបកដវិសេសលើស
មនុស្សលោកយ, កិត្តិល្បីទៅវៃងឆ្ងាយណាស់ ៗ ក្នុងខណៈនោះ

បណ្តាស្រុកតូចធំនិគមជនបទនានា សឹងនាំគ្នាមកចំណុះចុះចូលខុនបេង ច្រើនណាស់, ខុនបេងក៏ប្រែផ្លាស់កសិជ្រះថ្ងៃ គិតក្តុំពលយោធាលើកទៅ វាយយកខេត្តដែនខាងព្រះចៅចូយ៉យថែមទៀត, លុះលើកទ័ពទៅដល់ក្នុង គីសាន ក៏ហោះបន្ទាយកាយកងទ័ពនៅក្បែរឆ្នេស៊ឹងអ៊ុយឈុន ។

ពួកល្បាតនេះ ក៏នាំគតិមានទៅចូលក្រុងឡូកអៀង ដើម្បីឲ្យយក សេចក្តីក្រាបទូលព្រះចៅចូយ៉យទ្រង់ជ្រាប, ខណៈនោះ ព្រះចៅចូយ៉យ សោយរាជសម្បត្តិបានគន្លះឆ្នាំ (គ.ស. ៧.?.) ជាទេសកាលខែមិគសិរ, ស្តេចចេញគង់ព្រះទីនាំងសេនទៀន, មាម៉ឺនតូចធំជួបជុំទូលថា: ហៃហ្វូ- លីបចេញទៅធ្វើការកេណ្ឌបញ្ច្រាមគ្រានេះ បាញ់ប្រៀបខុនបេង នៅទៅ នៅស្រុកកៀងសៀ, វេលានេះ ខុនបេងលើកកងទ័ពចូលមកក្នុងគីសាន ហើយ, ទ័ពស្រួចលើកមកដល់ទល់មាត់ស៊ឹងអ៊ុយឈុន ឲ្យតាំងបន្ទាយ នៅត្រើយខាងលិច, គួរយើងទំនេប្រើល្បិច លើកទ័ពទៅតទល់ពីចម្ងាយ ទើបបាន ។

ព្រះចៅចូយ៉យឮច្បាស់ ក៏ព្រួយព្រះទ័យណាស់ ត្រាស់ថា: បើ ដូច្នោះ តើនរណាខ្លះ ទំងានមានគំនិតចេញទៅធ្វើការយកជ័យជម្នះខុនបេង ឲ្យបាន ។ អង់ឡូងក្រាបទូលថា: បណ្តាមាម៉ឺនដែលមានបណ្តាស័ក្តិធំ ខ្ពស់មានកេរ្តិ៍ឈ្មោះតាំងពីព្រះចៅកុំណាកនេះមក នៅមិនទាន់ប៉ុន្មានតែ ចូជិន ១, [illegible]

ច័ត តាំងអស់ លើកព្យុហៈចំពេញទៅដោយស្រួកទ់ ទើបចាត់ការទាន់ កុំឲ្យខ្មុំបេងលើកកងទ័ពចូលមកទៀតបាន, ព្រះចៅចូយ៉យយល់ត្រូវ ទើប ត្រាស់ឲ្យហៅប៊ូជិនចូលទៅគាល់ហើយត្រាស់ថា កាលព្រះចៅចូកឺទៀប នឹងអស់ព្រះជន្មស្ក្រនោះ ក៏តាំងទុកព្រះទ័យផ្ញើផការផែនដីលើលោក ឲ្យជួយអភិបាលរក្សា, ឥឡូវ ខ្មុំបេងលើកព្យូហៈយោធាកងទ័ពចូលមក កាន់ផែនដីយើងជ្រុលណាស់ហើយ, ម្តេចក៏លោកធ្វើព្រងើយកន្តើយដូច្នេះ, លោកភ្លេចព្រះតម្រាស់បណ្តាំព្រះចៅចូក៏ហើយឬ ? ។

ប៊ូជិនទូលតបថា ទូលព្រះបង្គំជាខ្ញុំពុំបានភ្លេចព្រះតេជព្រះគុណព្រះ ចៅចូកឺសោះ តាំងចិត្តជាសមរសទៀងត្រង់ ប្រឹងខ្លួននឹងផ្ញើផការថ្វាយ ស្នងព្រះតេជព្រះគុណ ដែលជាទម្ងន់ត្រាតែអស់ជីវិត, តែទូលព្រះបង្គំជាខ្ញុំ មកជញ្ជឹងគិតឃើញថា, ខ្ញុំនេះឯងជាអ្នកមានសតិបញ្ញាតិចតួចស្តួចស្តើង ណាស់, នឹងចេញមុខទំរួះរះ ក៏ឃើញថាគង់នឹងមិនសម្រេចឲ្យហូតទៅ បាន, អង្ឡងឡើយទៀតថា : លោកជាមន្ត្រីធំខ្ពស់ មានយសពេញ ទីជាសេនាបតី ធ្លាប់ផ្ញើផការជួយទំនុកបម្រុងផែនដីមក តាំងពីកជព្រះ ចៅវ៉ុយអង ចម្បងលើសគេ, ដែលនឹងមកចាំតបផ្ទាបបទ្មោកខ្លួនព្លួន មុខដូច្នេះ ឃើញថាជាការមិនសមគួរសោះ, វេលានេះ គួរតែលោក នឹងអះអាងកាន់ក្រុង, ខ្ញុំដែលចាស់ជរាមានអាយុ ៧៦ ឆ្នាំហើយ ក៏នឹង ជួយចេញខ្លួនទៅអមកផការការពារផែនដីជាមួយនឹងលោកដែរ ។

ចូជិន បានឮដូច្នោះ, ក៏យកសេចក្ដីក្រាបទូលព្រះចៅចូយ៉យថា: ដែលទូលព្រះបង្គំជាខ្ញុំទូលដូច្នេះ, ព្រោះគិតជៀមខ្លួនណាស់, មិនមែនទីងព្រងើយកន្ដើយនោះទេ, បើប្រសិនមិនមានគេអ្នកឯណាមួយទីងចេញមុខយកអាសាហើយ ទូលព្រះបង្គំជាខ្ញុំទីងទៅខ្លួនឯង, ដើម្បីធ្វើការតបស្នងសងព្រះតេជព្រះគុណត្រាតែសូន្យជន្មាយុ មិនអាល័យស្ដាយ, តែសុំយកគុយហ្លួយជាបាល័ដ្ឋទ័ពជាប់ទៅផង ។ ព្រះចៅចូយ៉យ ក៏មានព្រះទ័យត្រេកអរណាស់, ត្រាស់តាំងចូជិនជាមេកងទ័ពធំ, តាំងគុយហ្លួយជាបាល័ដ្ឋទ័ព, តាំងអេងឡុងជាទីប្រឹក្សា, ឲ្យលើកពលៈយោធា ២០ មុឺនចេញទៅ ។ ចូជិន ក៏តាំងឲ្យប៉ូជុនជាអាចទ័ពស្រួច, តាំងប៉ូចានជាបាល័ដ្ឋ ។ លុះបានបុក្សពារជាឧក្ខតស្វស្ដិជ័យមង្គល ក៏ប្រជុំពួកពលជាក្បួនហៃយ៉ាងទ័ពក្សត្រិយ៍, លើកជាជួរសន្ធាត់ចេញពីទីក្រុង ។ ព្រះចៅចូយ៉យក៏ទ្រង់យាងជូនដំណើរទ័ពផុតកំពែងក្រៅ ។ កងទ័ពក៏លើកសំដៅទៅដល់ខេត្តស៊ីងគុយស៊ុយ ហើយក៏ចូងទៅត្រើយម្ខាង តាំងបោះទ័ពឈប់នៅទិសបស្ចិម ។

ចូជិន ក៏ប្រជុំសេនាពាហន ប្រឹក្សាការណ៍រណរង្គសង្គ្រាមជាមួយទីងអង់ឡុង, គុយហ្លួយ ដោយផ្វរកដការថា យើងទីងគិតធ្វើម្ដេច ទើបនឹងមានជ័យជម្នះខ្មាំងបានក្នុងវេលានេះ ។ អង់ឡុងឆ្លើយថា: ប្រសាសន៍កុំព្រួយឲ្យសោះ, អោលព្រឹកស្អែកនេះ, សូមឲ្យពាក់កាហានទៅលើក

ទន់ជ័យកាយខាងមុខបន្ទាយឲ្យជាទីរុងរឿង ,  ខ្ញុំបានទីងឡើងសេះចេញទៅបរបាទឹងខុនបេនឲ្យដឹងបទបាទ, គ្រាន់តែកាយខុនបេនដោយអណ្ដាត ២ ធ្លាប់ ក៏ទឹងចាប់ខុនបេនឲ្យលើកដៃប្រណម្យសំពះ យកជ័យជម្នះឲ្យបាន ហើយឲ្យខុនបេនត្រឡប់ទ័ពទាំងប៉ុន្មានវិលទៅស្រុកសៃឈ្មួនវិញ, ទាហានយើង ក៏មិនមានត្រូវពោះម្នាញវាវិលបាក់ឡើយ ។

ចូជិនពុទ្ធនោះហើយ ក៏សោមនស្សត្រេកអរណាស់, ក្រោកយ៉ាងរហ័សទៅសរសេរសំបុត្រមួយច្បាប់ បិទត្រា ឲ្យរេម្រឺនាំទៅឲ្យខុន-បេនក្នុងបន្ទាយ សេចក្ដីថា ពេលព្រឹកស្អែកនេះ, ឲ្យខុនបេនលើកទា-ហានចេញពីបន្ទាយមកចុះ ទីងបានច្បាំងគ្នាពីព្រលឹម , ហើយចូជិន ក៏បញ្ជាប់ទាហានទាំងពួងឲ្យហាំបាយស៊ី និងត្រៀមខ្លួនជាស្រេច តាំងពីយាម ៣, ព្រលឹមស្រាងទីងបានលើកទៅច្បាំងទីងខុនបេន ។ លុះព្រឹកឡើងទាហានទាំងបន្ទាយ ក៏កាយឈ្មោះគោះគន់ធូងគរលើកទ័ពចេញពីបន្ទាយកាយឲ្យប្រទល់ទ័ពជាលំដាប់នៅមុខក្ដីសានទាំងសង្ខាង, ទាហានខុនបេនក្រឡេកឃើញទាហានចូជិនមានកម្លាំងពលខ្លាំងពូកែ ជាជាងទាហានវៃហ-ហ្លិមច្រើនណាស់ ខ្វះក៏គិតកោតញញើតដៃ, ។ លុះបានជាតជ័យត្រូវលើកចេញទៅប្រទល់មុខគ្នាពេលាព្រឹកនោះ, ស្គរគងឃ្មោះ ក៏ស្ងប់ឈប់កាយទាំងសង្ខាង, អនឡុងក៏ឡើងសេះបរចេញទៅបញ្ឈរពីមុខទា-ហាន ឲ្យចូជិននៅអមខាងស្ដាំ, គុយហ្វយនៅអមខាងឆ្វេង, នាយ

ទាហានទ័ពស្រួចទាំង ៦ កង ចេញត្រសងជាគួរឃៀងខាងមុខទ័ព ។

អង់ឡេងបង្គាប់ឲ្យទាហានសេះស្រែកទៅថា : ហើយទ័ពខាងឆាយ , ឲ្យអញ្ជើញចៅហ្វាយផះមេកងធំចេញមុខមក , ឲ្យចៅហ្វាយយើងបាន និយាយការបន្តិច ។ ខុងបេងបានឮដូច្នោះ ក៏ឡើងជិះរទេះតូចតែងខ្លួន ពេញទីជាមហាឧបរាជ ឲ្យគួនហ៊ុនទៅអមខាងស្ដាំ, ឲ្យទៀវប៉ៅទៅអមខាងឆ្វេង, ឲ្យជូឡុងនិងនាយទាហានឯទៀត ៗ ទៅជាកងក្រោយ, ហើយក៏លើកចេញទៅពីមុខទ័ពធំ ក្រឡេកទៅឃើញមេទ័ពម្ខាងកុំពលបញ្ជរសេះមុខទាហាន មានប៉ាំងសបូធន ជាគួរឃៀងរៀងកយគ្នា ទាំង ៣ សេះ, ខុងបេងក៏គិតត្រិះរិះថា នាយទាហានពាសដែកនៅកណ្ដាល ប្រហែលជាទីប្រឹក្សារទ័ពបម្រាប់ការ, ឲ្យហៅៈយើងចេញមកចរចា ប្រាថ្នានឹងបញ្ចុះបញ្ចូលឲ្យយើងទូលចំណុះចុះចាញ់ជាប្រាកដណាស់ ។ ខុងបេងក៏បររទេះស្រួតចេញហួសទៅមុខទ័ព បង្គាប់ទាហានឲ្យស្រែកតបទៅថា: ចៅហ្វាយធំរបស់យើង អញ្ជើញចេញមកហើយ, ចៅហ្វាយអ្នកឯង នឹងថ្លែងប្រស្រ័យយ៉ាងណា ឲ្យថាមកចុះ ។

( ទៅមានត )

# រឿង
# គ្រោះថ្នាក់នាវាចរដោយខ្យល់ព្យុះ
## របស់លោក វ៉ារិន្ទ្រណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សរល់

(តមកពីឆ្នាំ ១៩៦៩)

## វគ្គទី ៣៩

ព្រឹកស្អែកឡើង នាងហិមណាលិនីចូលទៅក្នុងបន្ទប់ឪពុក ឃើញលោកតម្រេតខ្លួនលើកៅអីវែងមួយ ដែលគាត់បានទាញមកដាក់នៅមាត់បង្អួចក្រោមចំណាំងព្រះអាទិត្យ ។

បន្ទប់លោកតាមិនមានគ្រឿងអីច្រើនទេ មានតែកៅអីវែងមួយ គ្រែតូចមួយ និងតុមួយប៉ុណ្ណោះ ។ នៅជញ្ជាំងមានរូបម្ដាយនាងហិមណាលិនី ដែលពព្រាកអស់ទៅហើយ តែមានក្របកញ្ចក់ថ្នាក់និងក្របកញ្ចក់មួយទៀត ជាផ្ទាំងសំពត់ប៉ាក់ ដែលជាស្នាដៃរបស់លោកយាយនោះ ។

នារីធ្វើជាខ្នុនគេ យ៉ល់សក់ស្ព្រីចដកជូនឪពុក អង្អែលស្មាគាត់ និយាយយ៉ាងស្រទន់ ៖

— ថ្ងៃនេះ យើងចាប់ញ៉ាំបាយៈទៅពុក ញ៉ាំរួចយើងនិយាយគ្នា

លេងនៅកន្លែងនេះ ពុកចាំនិយាយរឿងរ៉ាវពីអតីតកាលឲ្យខ្ញុំស្ដាប់ផង ខ្ញុំចូលចិត្តស្ដាប់ណាស់ . . . ។

លោកតា ដែលធ្លាប់រស់នៅជាមួយកូន ស្គាល់ចិត្តកូនណាស់ទៅហើយ គ្រាន់តែឮសម្ដីប៉ុណ្ណោះ គាត់យល់ភ្លាមថា: អាក់ស្ដាយមុខជាមកផ្ទះលោកមិនបានទេ ហើយនាងដែលនិយាយជម្រាបឪពុកថា ចង់មកនៅកន្លែងបន្ទប់នេះ តែពីរនាក់នឹងគាត់ព្រោះចង់ស្ដាប់រឿង មិនគិតអ្វីក្រៅអំពីចង់ចៀសមុខអាក់ស្ដាយឡើយ ។ លោកមួរ ម៉ៅនឹងដឹងថាកូនមិនសប្បាយចិត្ត ក៏ខ្នាក់កំហឹងទៅលើអ្នកបម្រើ ដែលដាក់ទឹកជូនលោកមិនពុះល្អ ។

— ធ្វើការអ្វីចំពើគងំគើង មើលតែបាឡាត់ ម៉េចឯងចង់ឲ្យអញបម្រើឯងវិញឬ បានជាធ្វើការអ៊ូស្មោះផ្ការ យ៉ាងនេះ ?

ពេលពិសាអាហារ លោកតាបញ្ចេញអាការៈប្រញាប់ប្រញាល់ខុសពីធម្មតា នាងទឹកឆ្ងល់ក៏សួរថា:

- ពុកប្រញាប់អញ្ជើញទៅណាឬ ?

— ទេ គ្មានទៅណាទេ ប៉ុន្តែអាកាសត្រជាក់ផឹកទឹកតែឲ្យក្ដៅចិត្តទៅវាស្រួល . . . ។

ពេលដន្ទ្រាដើរចូលមក អាក់ស្ដាយតាមស្ពឹតក្រោយ ។ អ្នកកន្ទោះតុបតែងខ្លួនស្អាតបាតណាស់ថ្ងៃនេះ គេកាន់ដំបងក្លាស់ព្រួតមួយ

ហើយនៅហោប៉ៅអាវកាត់ខ្លួនរបស់គេ មានខ្សែនាឡិកាដាក់មាសសំ-យាកចេញមកក្រៅផង ស្អាតមែនថ្ងៃនេះ ! ដៃឆ្វេងកាន់សៀវភៅមួយមានគ្របពណ៌ចំប៉ាក្រៀម ៗ នៅពេលដែលគេដើរចូលមក គេមិនទៅកាន់កន្លែងធម្មតាទេ គេទាញកៅអីមួយមកអង្គុយជិតនាងហាយណាលីនីហើយនិយាយ : ៗ

— នាឡិកាបែបដូចជាលឿនណាស់ថ្ងៃនេះ ៖

នាងមិនខ្វល់ឡើយ ហើយមិនទាំងងាកមុខមកទទួលម្ចាស់សម្លេងទៀតផង លោកតាយល់ចិត្តកូន រកលេសនាំកូនឡើងលើក្បាល ៗ

— មកកូនទៅលើ ទៅជួយយកខោអាវអាររបស់ពុកហាលថ្ងៃបន្តិច កុំឲ្យសត្វកាត់ ៗ

— កុំបាច់ប្រញាប់អី ព្រះអាទិត្យមិនទាន់តែទៅណាទេ (ដោះដន្ទ្រានិយាយបញ្ចេញខ្សល់ មិនពេញចិត្តនឹងអាកប្បកិរិយារបស់ឪពុក ) រួចហាមមិនចាក់ទឹកតែឲ្យអាក់ស្ហាយញ៉ាំផងទេឬ ?

អាក់ស្ហាយរីករាយណាស់ ផ្ទុះសំណើចកក្អឹក តែនារីគ្មានចាប់ចិត្តរវល់នឹងអ្នកកំទាះអាកព្ទះនេះសោះ នាងចាក់ទឹកតែពីរពែង ហុចមួយពែងជូនទៅបង រុញមួយពែងទៀតទៅចំពោះមុខអាក់ស្ហាយ រួចងាកមើលមុខឪពុក លោកយល់ជម្រៅក្ដីកូន ក៏និយាយបន្ថែម ៖

— ទៅកូន តែបន្តិចយូរ ថ្ងៃក្តៅណាស់នៅលើដំបូល . . . ។

— កុំទៅគិតអាខោអាវនោះ (ជោរជ្ត្រាប្រឡាក) ឲ្យវាទៅជាស្អី ទៅសិនទៅចុះ គិតតែរឿងឯនេះ អាក់ស្ហាយគេមកចង់និយាយ . . . ។

លោកតាត្រូសម្តីជោរជ្ត្រា ក្តៅធុល ប៉ះសម្តីគ្នាមាំងក្លាម ៖

— ឯងស្មានថាអញខ្លាចឯងតាំងពីរមក់នេះឬ? នែ! អញត្រាំសម្តីឯងយូរថ្ងៃមកហើយ អញមិនដែលប្រកែកមួយម៉ាត់ណាសោះ ឥឡូវនេះ អញទ្រាំមិនបានទេ ហ៊ឹមណាលើទ ចាប់តែថ្ងៃនេះទៅ ពុកទឹងកូនឯងញាំបាយតែពីរនាក់នៅខាងលើឯនោះបានហើយ មិនបាច់ចុះក្រោមទេ ។

លោកទាញដៃនាងដើរចេញ តែផងទាញឪពុកមកវិញយ៉ាងស្ងប់ ៖

— ឈប់សិនពុក ពីសាអីកំឲ្យហើយ ស្រួលបួលសិនទៅ រួចចុះ អាក់ស្ហាយ តើអ្នកអាចប្រាប់ខ្ញុំផងបានឬទេ តើកញ្ចប់ដែលអ្នកកាន់នោះជាកញ្ចប់អ្វី ?

— មិនមែនគ្រាន់តែត្រឹមប្រាប់បានទេ ខ្ញុំជូនមើលបានថែមទៅទៀត ថាៈ ហើយហុចកញ្ចប់ទៅឲ្យនាង ៖

នាងបើកទៅ ឃើញសៀវភៅកំណាព្យរបស់លោកតេន្នីសុន ចងក្រប់យ៉ាងស្អាត ៗ នាងភ្ញាក់ព្រើតចិត្តដូចត្រូវមួយដំបង ព្រោះម្តងមុន នាងបានទទួលអំណោយបែបនេះនោះរួចទៅហើយ ហើយនាងដាក់

ពេលសៀមក្នុងថតតុមិនឲ្យអ្នកណាដឹងមួយត្រចៀកសោះ ។

បងប្រុសឃើញដូច្នេះ ញញឹមហើយនិយាយបន្ថែម ៖

— អាថិកំប៉ាំងមិនទាន់ចេញមុខនៅឡើយទេ អ្នកនិយាយបណ្តើរ បើកសៀវភៅបណ្តើរ ហើយបង្ហាញសេចក្តីឧទ្ទិសខ្ទិចសរសេរដោយដៃ អាក់ស្ហាយ ៖

"ចំពោះស្រីមាទី ហិមណាលិទ ជាសក្ខីភាពនៃសេចក្តីកប់អាទរបស់ អាក់ស្ហាយ"

នារីពោលក្អកឃើញហើយ ទម្លាក់សៀវភៅពោលក្តុក ហក់ដូចជាដៃគម្ងន់ហើយក្តៅពេកនាំខ្លួនកើត ។ នាងងាកមុខចេញ និយាយទៅកាន់ឪពុក ៖

—មកពុក !

ឪពុកនឹងកូនស្រីដើរចេញពីបន្ទប់ទៅ ។

ក្អកជោរជេទ្រា ដាលប៉ដូចអណ្តាតភ្លើង មួយរំពេច

— ខ្ញុំមិនបាច់ខ្ចីនៅជ្រកក្រោមដំបូលផ្ទះនេះទៀតទេ ខ្ញុំទៅរស់ឯណាឲ្យបាត់ កុំឲ្យឃើញមុខខ្ញុំទៀត ខ្ញុំទៅបម្រើនគេយកលុយ ក៏រស់ដែរ..

អាក់ស្ហាយ អំណត់ណាស់ ទោះជាគេជះសំរុយលើមុខហើយ ក៏មិនខឹងដែរ . . . ។

— នែ ជោរជេទ្រា កុំធ្វើឲ្យកើតរឿង ខ្ញុំបានប្រាប់ឯងហើយតើ

ថាប្អូនឯងមិនដែលយកចិត្តទុកដាក់នឹងខ្ញុំទេ ហើយការដែលឯងនិយាយប្រាប់ខ្ញុំថា នាងសុខចិត្តរៀបការជាមួយខ្ញុំ គឺប្រាកដជាឯងយល់ច្រឡំ ។ ឯងមិនជឿខ្ញុំ ចេះតែបង្ខំខ្ញុំ ខ្ញុំក៏ព្រមមកតាមឯង ប៉ុន្តែខ្ញុំដឹងស្រេចទៅហើយថា នាងមិនមែនត្រូវការរូបខ្ញុំទេ ។ ណ្ហើយឈប់គិតទៀតទៅ បើយើងចង់ឲ្យនាងសុខចិត្តរៀបការនឹងអ្នកណាមួយ ទាល់តែចេះធ្វើម្តេចឲ្យនាងភ្លេចអាកាមេស្ហសិន ។

– ប្រាកដមែនហើយ តែធ្វើដូចម្តេច ?

– ឯងមិនត្រូវដាក់ចិត្តថា មានតែរូបខ្ញុំមួយនេះទេ ដែលអាចរៀបការជាមួយនឹងនាងបាន ។ ម្យ៉ាងទៀត ឯងត្រូវជឿឲ្យច្បាស់ថា បើសិនជាប្អូនស្រីឯង មានគំនិតដូចឯង រឿងអ្វីទាំងប៉ុន្មានមិនមែននៅប្រឆាំងដូច្នេះទេ ម៉្លេះចប់យូរណាស់ទៅហើយ ហើយម៉ែឪខ្ញុំក៏មិនព្រួយចិត្តនឹងខ្ញុំដែលមិនព្រមរកគូស្រករនោះដែរ—ប៉ុន្តែ បើនាងមិនយល់ស្របតាមយើងទេ យើងត្រូវតែរកអ្នកណាដែលនាងពេញចិត្តទៅ ក្រៅអំពីអាមនុស្សដែលនាងគ្រាន់តែក្រឡេកឃើញ នាងរត់ យកលេះថាទៅហាលទោសារនេះ ។

—ឯងនិយាយថា រកមនុស្សធ្វើប្តីឲ្យវា អ៊ីកំឆាយម្ល៉េះ អញមិនអាច Commander ឲ្យគេធ្វើប្តីឲ្យពេញចិត្តមួយឲ្យវាកើតដូចគេដាក់ឲ្យធ្វើនទេ ។

–កុំប្រញាប់រស់សង្ឃឹមពេក ឯងនិយាយតែបែបនឹង មុខជាគ្មាន គិតការធ្វើកើតទាំងអស់ ។ ឯងត្រូវកុំទាន់និយាយអំពីប្តីសាជាមួយនឹងនាង តែចំប្រញាប់និយាយ នាងមុខជាភ័យ ឯខាងប្រុសទៀតគេក៏ខ្លាចដែរ ។ ឯងត្រូវទុកពេលឲ្យនាងដឹងរឿងរ៉ាវឲ្យស្និទសិន សឹមរកឱកាសសើកគំនិត របស់យើង ។

– អើ នេះគឺសៀតបួយល្អ គួររើសយកមែន ប៉ុន្តែ ឯងចង់យក អ្នកណាមកឲ្យនាង អញចង់ស្គាល់ឈ្មោះវា ។

– មនុស្សនោះ ឯងមិនសូវបានស្គាល់ដិតដិតមែន ប៉ុន្តែឯងធ្លាប់ បានឃើញគេច្រើនហើយ គឺបណ្ឌិតណាលីណាក់ស្រា ។ តែ ! ចុះរឿងអ្វី បានជាឯងពេលខ្លះសម្លុះ បណ្ឌិតនោះមិនសូវមានឈ្មោះក្រអូបក្នុងព្រហ្ម សម្រាប់គំពិតមែនហើយ ប៉ុន្តែនៅរវល់ក៏ និយាយជល់ហើយមិនស៊ី ទុកឲ្យអ្នកណាស៊ីទៅវិញ ឯងគិតឲ្យមែនទែនទៅមើល !

– យើងមិនមែនថាគេមិនល្អទេ ឯងត្រូវយល់ឲ្យច្បាស់សម្លាញ់ តែក្រែងគេមិនសុខចិត្តរៀបការនឹងប្អូនយើង ។

– គ្នាមិនមែននិយាយថា បើឯងលើកប្អូនឯងទៅឲ្យគេ គេទទួល ភ្លាមនោះទេ ឯងត្រូវដឹងថា កាលវេលាអាចធ្វើការកែស្ពាយបាន ។ តែ ឯងស្តាប់អញសិន ស្អែកនេះ "ណាលីណាក់ស្រាត្រូវធ្វើសន្និសីទ មួយ ។ ឯងត្រូវបបួលនាងទៅស្តាប់នឹងគេទៅ ។ ណាលីណ្ណាបានរ៉ា-

ហារណាស់ ហើយត្រូវដឹងថា គ្មានអ្វីក្រៅអំពីពេលហារនេះទេ ដែលអាចទាញចិត្តស្រី ៗ បាន ស្រី ៗ ចូលចិត្តមនុស្សពេះនិយាយ ជាជាងមនុស្សពេះស្តាប់បង្គាប់ ?

—ចុះណាលីណាកស្ហានោះ យ៉ាងម្តេចខ្លះ តាមដែលឯងធ្លាប់ស្គាល់ ម្តេចក៏មិននិយាយពីគេប្រាប់យើងផង ។

- យើងគ្មានចង់លាក់អ្វីនឹងឯងទៀយ តែឯងត្រូវដឹងជាមុនថា បើប្រសិនជាឯងឃើញសម្រាមខ្លះ ក្នុងប្រវត្តិរបស់គេ ឯងមិនត្រូវផ្តល់យកការនោះជាធំទេ ព្រោះថាសម្រាមនេះជាកម្លាំងរបស់យើងទៅវិញទេ ព្រោះយើងត្រូវបណ្តិតគេ ដើម្បីប្រយោជន៍អ្វីមួយ ។

បន្ទាប់មក អាក់ស្ហាយកធ្វើសេចក្តីសង្ខេបអំពីប្រវត្តិលោកណាលីណាក់ស្ហា :

" ពុកណាលីណាក់ស្ហា ឈ្មោះកផបល្ហា គាត់មានទីលំនៅនៅក្វាប៉ុរី ។ លុះគាត់បានអាយុប្រមាណជា ៣០ ឆ្នាំ គាត់ចូលខ្លួនទៅកាន់សាសនាព្រាហ្ម ប៉ុន្តែប្រពន្ធគាត់មិនព្រមតាម បែរជាក្រាញទៅកាន់សាសនាដែលជាទំនៀមរបស់គាត់ពីដើមមកទៅវិញ ការខ្វែងគំនិតគ្នាបែបនេះ ធ្វើឲ្យកផបល្ហាមិនសូវពេញចិត្តនឹងប្រពន្ធគាត់ ។ ចំណែកណាលីណាក់ស្ហាជាកូនប៉ោយគេបានពេលនោះ ហើយពេះនិយាយត្រូវចិត្តអ្នកស្តាប់ ក៏ត្រូវបានសាសនាព្រាហ្មណ៍នេះ ទទួលគាំទជាសមាជិកមួយរូប

យ៉ាងឆាយ ៗ បន្ទាប់មក អ្នកបានចូលខ្លួនទៅបម្រើក្នុងក្រុមវិជ្ជា វិទ្យា របស់រាជការខេត្ត ហើយត្រូវគេចាត់ឲ្យដើរមើលអ្នកស្រុក ពីកន្លែងមួយ ទៅកន្លែងមួយ តាមក្រសួងត្រូវការ ៗ នៅគ្រប់តែកន្លែងដែលគេបានទៅគេទុកអនុស្សាវរីយ៍ជាទីគាប់ចិត្តគ្រប់យ៉ាងឲ្យបណ្ដាជនទាំងខាងផ្លូវការងារទាំងខាងផ្លូវចិត្ត ទាំងខាងសម្ដីផ្អែមល្ហែម ៗ

ស្រាប់តែមានរឿងចលាចលមួយកើតឡើង ដោយកជបាល្លាសម្រេចចិត្តថានឹងយកនាងមេម៉ាយមួយធ្វើជាប្រពន្ធ សម្រាប់គាំទ្រវ័យចាស់របស់គាត់ ហើយដកលេះចោលប្រពន្ធដើម មិនដឹងទុក្ខធុរៈគាត់សោះថែមទាំងមិនព្រមកាន់សាសនាតាមគាត់ផង ៗ គាត់និយាយប្រាប់គេឯងថា " ខ្ញុំយល់ថា ខ្ញុំមុខជាខុសធំហើយ បើសិនជាខ្ញុំនៅត្រាំមិនព្រមយកប្រពន្ធមួយទៀត ដែលមានចិត្តមួយនឹងខ្ញុំ " ទោះជាអ្នកជិតខាងមិនយល់ស្រប ហើយទូន្មានបង្អាក់គាត់យ៉ាងណា គាត់ក៏នៅតែចចេស យកនាងមេម៉ាយក្មេងនោះទាល់តែបាន ៗ

ឃើញថ្ងៃប្រចិត្តប្ដីបោះ ឆ្ងាយណាស់លីណាក់ស្ហាក៏រៀបចំដកខ្លួនថយទៅនៅបណ្ដោយសេះទៅ ៗ ចំណែកណាលីណាក់ស្ហាជាកូន ដែលកំពុងតែជាអ្នកបុះប៉ូលច្រើន ក៏សុខចិត្តបះបង់ការងាររបស់ខ្លួន ដើម្បីទៅតាមម្ដាយ ដោយគ្មានព្រួយព្រួយអ្វីសោះ ៗ ឃើញដូច្នោះ ម្ដាយលោករំភើបចិត្តណាស់ ហើយប្រាប់ទៅកូនថា " កូនមិនត្រូវលះមុខការរបស់

កូនដើម្បីមកតាមម្ដាយទេ ព្រោះយើងទាំងពីរនាក់មានគំនិតមិនស្របគ្នា"។

ការពិត គឺណាលិណាក់ស្ហាតួបចិត្តទឹងផុតុក ដែលធ្វើឱ្យម្ដាយខ្លួន វេទនា ហើយដាក់ចិត្តថា គាត់ត្រូវធ្វើដូចម្ដេច ឲ្យតែម្ដាយគាត់បាន សប្បាយចិត្ត ហេតុដល់គាត់អស់ជីវិត ម៉្ងោះហើយទើបលោកទៅតាម ម្ដាយលោកនៅឯបេណារេស ។ បន្ទាប់ពីនោះបន្តិចមក ម្ដាយលោក សួរលោកថា "ម៉េចកូនឯងមិនគិតគូរកប្រពន្ធកូនអ៊ីទេឬ ព្រោះថាកូនមិន ត្រូវស៊ូទ្រាំនៅតែឯង ដោយសារតែរូបម្ដាយមួយនេះទេ កូនត្រូវរើសយក ស្ត្រីណា ដែលកូនពេញចិត្ត ជាគូរជីវិតទៅចុះ ម្ដាយនឹងមិនជំទាស់ចិត្ត កូនឡើយ "

ក្រោយពីពេលដែលម្ដាយលោកបាននិយាយពីរឿងប្រពន្ធប៉ុន្មានជា ពីរឬបីថ្ងៃក្រោយមក ណេកគិតសព្វគ្រប់ហើយ ក៏បានជំរាបទៅលោក យាយនោះវិញ :

" អ្នកម្ដាយ កូនបង់នាំស្រីម្នាក់ដែលកូនពេញចិត្ត មកជូនអ្នកម្ដាយ មើល បើពីរឿងគំនិតមារយាទនិងការរាប់អានក្នុងគ្រួសារវិញ អ្នកម្ដាយ នឹងមិនព្រួយប្រះដៅនាងនោះទៀតឡើយ ព្រោះនាងមានសន្ដានចិត្តជា មនុស្សអត់ធ្មត់ មានចិត្តធន់ធ្ងរនឹងការងារណាស់ " ។

ក្រោយមក លោកណាលិណាក់ស្ហាក់ទៅរកប្រពន្ធនៅឯបង់ក្លាល

រឿងក៏បន្ទាប់ពីនោះមក យើងមិនបានដឹងច្បាស់ទេ ឯដំណឹងដែលយើងទទួលសោកក៏មិនដូចគ្នាទៀត ៗ អ្នកខ្លះថាលោកបានរៀបការនឹងស្រីកំព្រាម្នាក់ មិនបានយូរប៉ុន្មាននាងនោះស្លាប់ទៅ ៗ អ្នកខ្លះមិនជឿនិយាយប្លែកទៅវិញ ឯចំណែកខ្ញុំ ខ្ញុំយល់ថាលោកនេះជិតនឹងរៀបការទៅហើយ តែដល់ទីបំផុតទៅ ទៅជាខកខានទៅវិញទេ បើពុំនោះ ម្ដេចក៏គាត់គ្មានប្រពន្ធ ? តែទោះជាយ៉ាងម្ដេចក៏ដោយ យើងគិតលៃលកដូចម្ដេច ឲ្យតែណាលីណាក់ស្ហា បានឃើញនាងហិមណាលិនីសិនទៅ លោកមុខជាចាប់ចិត្តលើរូបនាងមិនខានឡើយ ៗ

( នៅមានត )

# រឿងខ្លី ៗ មានន័យវែង

## ដកស្រង់ពីអដ្ឋកថាជាតក

អ្នកនិពន្ធតែងសេចក្ដី **ផល-ធិត** នៅក្រុមជំនុំព្រះត្រៃបិដក

( ត )

ពេលនោះ កណ្ដុរមេខ្វាន ដែលមានខ្លួនធំហើយខ្លាំងពូកែ ចាប់សង្ស័យទៅលើចចកធម្មិក: ក៏បន្ទំខ្លួនដើរពីក្រោយគេបង្អស់ ក្នុងពេលដែលនាំគ្នាទៅធ្វើការក្រាបប្រណិបតន៍ចំពោះចចក ដូចថ្ងៃមុន ១ ៗ វេលាដែលកណ្ដុរទាំងនោះវិលមកវិញ, ចចកធម្មិក: ឃើញឱកាសល្អ ក៏ស្ទុះលោតទៅស្គ្របចាប់កណ្ដុរមេហ្វូង ដែលកំពុងដើរក្រោយគេ ៗ ដោយការប្រុងស្មារតីទុកជាមុនស្រេច កណ្ដុរមេហ្វូង ក៏ហក់លោតថយក្រោយផុតពីមាត់ចចក ហើយស្រែកថា ណែះ ! ប្នឹងហើយឬ ជាវត្តសមាទានរបស់ឯង ? គាត់ឯង ឥតបានប្រព្រឹត្តធម៌សោះ បែរជាយកធម៌ធ្វើជាទង់បន្លំបៀតបៀនអ្នកដទៃទៅវិញ ៗ រំពេចនោះ កណ្ដុរទាំងអស់ នាំគ្នាបែរមុខស្ទុះលោតទៅខាំក្រញីចចកដាច់ខ្ទួចខ្ទីស្លាប់ ក្នុងពេលនោះឯង ៗ

កុសលាវៀវត្ត

# ១២- ចចករុងរឿង

លលាដ៍ក្បាលអ្នកបែកចេញខួរ ឆ្អឹងទាំងពីរផ្លូវក៏បាក់ខ្ទេច
ត្រូវដំរីកាចជាន់កម្ទេក ធ្វើម្ដេចអ្នកនឹងបានរុងរឿង ។

ចចកមួយ កំពុងតែដើររកស៊ី ជួនជាពើបពក់នឹងរាជសីហ៍ ។ កាលដឹងថា "ពុំអាចនឹងគេចខ្លួនរួច" ចចកក៏ប្រថុយចូលខ្លួនទៅក្រាបជិតជើងរាជសីហ៍ ហើយនិយាយថា ខ្លួនមកសុំធ្វើជាបាវព្រាវបម្រើរាជសីហ៍ ។ រាជសីហ៍ក៏ព្រមតាមសេចក្ដីសុំ ហើយនាំចចកនោះទៅលំនៅរបស់ខ្លួន រួចនិយាយថា នែជម្ពុក:(១)! បើឯងចង់ស៊ីសាច់សត្វអ្វី ចូរឯងដើរទៅរកមើលសត្វនោះ, បើឃើញនៅកន្លែងណា ត្រូវឯងមកប្រាប់យើងថា "រុងរឿងលោកម្ចាស់!" តែប៉ុណ្ណោះ យើងនឹងទៅប្រហារសត្វនោះ យកមកឲ្យឯងស៊ីតាមចិត្តចង់ ។ ចចកក៏ធ្វើតាមរបៀបនេះ រៀងរាល់ពេល ហើយបានស៊ីសាច់ក្របី-ដំរី-សេះជាដើម រហូតដល់មានសរីរៈកាយធាត់ថ្លោសទ្រលុច ទើបគិតថា អាត្មាអញ ជាសត្វជើងបួន, ឯរាជសីហ៍ ក៏ជាសត្វជើងបួនដែរ, គួរឲ្យខ្មាសណាស់ ដែលអាត្មាអញមិនហ៊ានសម្លាប់ក្របីដំរីសេះស៊ីដោយខ្លួនឯងដូចជារាជសីហ៍ ។ លុះគិតហើយ ក៏ទៅនិយាយនឹងរាជសីហ៍ថា លោកម្ចាស់! ខ្ញុំបាទបានទទួលទានសាច់ដ៏ល្អៗ

---

១- ចចក ។

ដោយសារលោកមកយូរហើយ, ថ្ងៃនេះ ខ្ញុំបាទសូមដេកលើទីដំណេករបស់លោកម្ចាស់ម្តង, ហើយសូមលោកម្ចាស់ចេញដើរទៅរកមើលដំរីដ៏ប្រសើរណាមួយ ដែលលោកម្ចាស់គាប់ចិត្ត រួចសូមមកប្រាប់ខ្ញុំថា "រុង-រឿង លោកម្ចាស់ចចក!" តែប៉ុណ្ណឹងចុះ, ខ្ញុំបាទនឹងទៅប្រហារដំរីនោះយកសាច់មកជូនលោកភ្លាម, សូមលោកម្ចាស់ មេត្តាកុំកំណាញ់ក្នុងរឿងសុំនេះធ្វើអ្វី! ។ រាជសីហ៍បានពន្យល់ចចកអំពីសមត្ថភាព ជាច្រើនដង, ប៉ុន្តែ លុះដល់ចចកអង្វរសុំដដែល ៗ ទើបព្រមអនុញ្ញាតតាមសេចក្តីសុំ ។ ខណៈនោះ ជួនជាដំរីចុះប្រេងមួយដើរមកដល់មុខលំនៅ , រាជសីហ៍ក៏ទៅប្រាប់ចចកភ្លាមថា រុងរឿង លោកម្ចាស់ចចក! ។ ចចកឮភ្លាមក៏លោតចេញពីគុហាមាស ដែលជាទីដំណេកនៃរាជសីហ៍ មកឈរមើលពត់ខ្លួនប្រាណ ងាកមើលគ្រប់ទិសទាំងបួន ស្រែកលូបីដង រួចក៏ស្ទុះហក់ប៉ោតលោតប៉ោងទៅ ដោយប៉ុនប៉ងថា "ខ្ញុំនឹងទៅទំពីលើពោងដំរី" តែកម្ព្រោស់ បែរជាទៅធ្លាក់ប្រកាច់ទៅនឹងជើងមុខដំរីវិញសោះ ។ ដំរីក៏លើកជើងជាន់ព្រួប បែកក្បាលចចក រួចលុញកម្ទេចទាល់តែល្អិតទៅមូលត្រុញមួយដុំ , ផុះកាចមដាក់ពីលើទៀត ហើយស្រែកកោញ្ចនាទបោលចូលព្រៃបាត់ទៅ ។

កកណ្ដកវិត្ត

# ១៣- សម្តីខុសកាល បណ្តាលឲ្យស្លាប់

វាចាខ្ពស់ហួសនិងខ្លាំងហួស   និងការពោលរួសខុសវេលា
រមែងសម្លាប់នូវម្ចាស់វា   ដូចសត្វទាស្លាប់ព្រោះមាត់ ។

នៅក្នុងព្រៃហេមពាន្ត, មានពួកឥសីមួយក្រុម តាំងអាស្រមបទនៅត្រង់កន្លែងដ៏ជាទីរមណីយដ្ឋានមួយ ។ កាលនោះ មានតាបសមួយរូបកើតកេតលឿន កំពុងតែអង្គុយកាន់ប៉ូវថៅពុះឧសក្បែរអាស្រម ។ មានតាបសមួយរូបទៀតជាមនុស្សមាត់ឆៅ ក៏ទៅអង្គុយក្នុងទីនោះដែរ ហើយចេះតែបង្គាប់បញ្ជាហៃហៃទៅលើតាបសអ្នកកាប់ឧសថា ហ៎ ! កាប់ខាងណេះវិញ ! ហ៎ ! កាប់ត្រង់នោះវិញ កានត្រូវចំទង . . . ។ តាបសកាប់ឧស នឹកខឹងទួលទប់ពុំទាន់ ក៏ស្រែកដេរថា លោកឯង ឥឡូវនេះឡើងបានៈជាអាចារ្យបង្រៀនសិល្បៈពុះឧសដល់អញឬ ? ។ ជាមួយនឹងពាក្យនេះ តាបសអ្នកកាប់ឧស វាត់ប៉ូវថៅយ៉ាងមុតនោះ សំពងចំបន្ទូលក្បាលតាបសប៉ុលប៉ូច តែមួយគូស ផ្ទុះបែកជាពីរភាគ ។ តាបសទាំងឡាយ មានសេចក្តីសង្វេគ ក៏នាំគ្នាធ្វើឈាបនកិច្ចសពតាបសនោះតាមប្រពៃណី ។

កាលនោះ មានសត្វទាមួយ អាស្រ័យនៅលើដំបូកក្បែរអាស្រមនៃពួកតាបសឥសីនោះដែរ ។ សត្វទានោះ តែងទំលើដំបូក រួចស្រែក

រងាវក្តែង ៗ រាល់ទិវារាត្រី ពុំស្គាល់កាលវេលាសោះឡើយ ។ ព្រានព្រៃម្នាក់ បានឮសម្លេងទតានោះ ក៏លបដេញតាមសូរស័ព្ទ ហើយលបបាញ់សម្លាប់ទតានោះ យកទៅធ្វើជាអាហារបាត់ទៅ ។

ប៉ាំសិវគ្គ

## ១៤-កុំសរសើរស្វា កុំថាក្របី

| | |
|---|---|
| អាងមាក់ងាយខ្ញុំបានដូច្នេះ | ទៅមុខស្វានេះគង់តែហ៊ាន |
| មើលងាយគេផ្សេងទៀតពុំខាន | ហើយវានឹងបានទុក្ខពុំលែង ។ |
| ព្រោះគេឯទៀតនោះមុខជា | សំឡេះក្បាលវា ទីនេះឯង |
| មិនកាំបាច់ខ្ញុំទំព្រឹងប្រែង | កម្លាំងកំហែងធ្វើវាទេ ។ |

ពានរឡេះឡោះមួយ ឃើញក្របីព្រៃមួយដែលតែងតែចូលមកជ្រកនៅក្រោមម្លប់ឈើដ៏ត្រជាក់មួយដើមដែលវាទៅអាស្រ័យ ក៏ចុះពីចុងឈើទៅជិះលើខ្នងក្របី ផុះ-នោមដាក់ ហើយតោងស្នែងតោងកន្ទុយយោលទោងលេង ជារៀងរាល់ថ្ងៃ ៗ ក្របីនោះ ជាសត្វស្លូត ពុំរវល់នឹងកិរិយាកខាចារបស់ស្វានោះឡើយ ។ ពេលមួយ ទេវតា ដែលអាស្រ័យនៅនាដើមឈើនោះ និយាយនឹងក្របីថា នែបងក្របី ! ហេតុអ្វីក៏បង

នៅត្រាំនឹងកិរិយាមាក់ងាយ របស់ស្វាកំហូចនោះម្ល៉េះ? ម៉េចក៏មិនសំពងប្រហារវាទៅ? ។ ក្របីឆ្លើយថា បពិត្ររុក្ខទេវតា! ពិតហើយ, បើខ្ញុំគិតពីជាតិ គោត្រកូល និងអាយុ, ខ្ញុំពុំអាចនឹងអត់ទោសឲ្យស្វានេះបានទេ, ប៉ុន្តែ ខ្ញុំពុំត្រូវការគិតដូច្នោះឡើយ, ម្យ៉ាងទៀត ស្វានេះ ថ្ងៃក្រោយឃើញក្របីណាមួយផ្សេងទៀត ស្មានថាជាសត្វស្លូតដូចខ្ញុំ ហើយទៅប្រព្រឹត្តអនាចារផ្សេង ៗ ដូច្នេះ, វាគង់តែនឹងត្រូវក្របីនោះប្រហារវាយ៉ាងធ្ងន់ពុំខាន, ដូច្នេះ ស្វាកំហូចនេះ គង់តែនឹងស្លាប់ ក្នុងពេលខាងមុខជាប់ ៗ ត្រង់ទីនេះឯង, ខ្ញុំមិនចាំបាច់បង់កម្លាំងយកខ្លួនទៅប្រឡូកកម្មពៀរជាមួយនឹងស្វាកំហូចនេះឡើយ ។

ក្រោយមកពីរបីថ្ងៃ ក្របីនោះក៏វិលមកជ្រកនៅទីនោះ ហើយមានក្របីមួយផ្សេងទៀត ចូលមកជ្រកក្រោមដើមឈើនោះម្ដងវិញ ។ មែន! ស្វាខិលនោះ ក៏ចុះពីដើមឈើទៅប្រព្រឹត្តអនាចារដូចក្របីមុនទៀត ។ ក្របីក្រោយនេះ ក្រេវក្រោធពុំអាចអត់ទ្រាំបាន ក៏រលាស់ខ្លួនគិលទម្លាក់ស្វាខ្ទាតមកដី រួចវាត់មួយស្នែង បែងមួយជើង ឡើងជាន់ឈ្លី ទាល់តែស្វានោះខ្ទេចខ្ទីស្លាប់ក្នុងពេលនោះមួយរំពេច ។

ឧទានវគ្គ

# ១៥- ស្វាយោកប៉ោល ចូលមាត់អណ្តើក

ស្វាអើយចៅស្វា អាប់ឥតប្រាជ្ញា សាវាឡេះឡោះ
ហ៊ានប៉ះហ៊ានពាល់ ពុំស្គាល់អ្វីសោះ ទាល់តែរងគ្រោះ
ប៉ះមាត់អណ្តើក ។

ពានរទ្រុស្តសីលមួយ ជាសត្វឡេះឡោះ តែងទៅប្រព្រឹត្តពុំគប្បី គឺយកអង្គជាតិរបស់ខ្លួន ទៅសេពមេថុនធម្មនឹងស្លឹកត្រចៀកឥសីមួយអង្គ ដែលលោកចំប្រឹងចម្រើនមជ្ឈត្តកម្មដ្ឋាន ។ ឥសី ពុំអើពើនឹងអកប្បកិរិយាដ៏ថោកទាបរបស់ស្វាឡើយ ទោះបីវាធ្វើយ៉ាងម៉េច ទៅលើរូបលោកក៏ដោយ ព្រោះលោកចំកសាងឧបេក្ខាបារមី ។ សម័យថ្ងៃមួយក្រោយមក មានអណ្តើកមួយ ឡើងពីទឹកមកដេកហាមាត់ប្រហាហាលថ្ងៃ ក្បែរផ្នែស្ទឹង ។ ស្វាខិល លុះឃើញអណ្តើកដេកហាមាត់ចំនងល្អ ក៏ម្ញប្ញាទៅជិត ហើយបញ្ចូលអង្គជាតិខ្លួនសេពមេថុននឹងមាត់អណ្តើកនោះ ។ អណ្តើកភ្ញារឡើង ភ្ញាក់ព្រើត បិទមាត់គ្រឹប ដូចជាគេបិទមាត់ស្នុកគ្រផ្ទប់អង្គជាតិស្វាយ៉ាងខ្ជាំង ។ ស្វាឈឺតើតពេក ស្រែករូងឡូងទ្រហោយំនឹករកអ្នកណាមួយជួយពុំបាន ក៏យកដៃទាំងពីរទ្រអណ្តើកលើកកាន់ដើរតេះតះទៅអង្វរករឲ្យឥសីជួយ ។ ឥសី លោកបានមេត្តាករុណាចំពោះសត្វទូទៅ ក៏មានដីកាសម្រុះសម្រួលអណ្តើក ឲ្យហាមាត់លែងអង្គជាតិពានរចេញ ។ ដោយសេចក្តីគោរពចំពោះឥសី អណ្តើកក៏សុខចិត្តលែង ។

ពានរបានរួចភ្លាម ក៏ថ្វាយបង្គំឥសី ថ្លែងអំណរគុណ ហើយបោលចូលព្រៃបាត់ លែងងាកមើលក្រោយ ។

ឧទានវគ្គ

# ១៦. ចោលសាច់ ស្រវាឆ្អឹង

អ្នកដែលលោភលន់តែងលង់លិច ស្រវាទ្រព្យតិចភ្លេចទ្រព្យច្រើន
ដូចស្វាល្ងង់ល្ងិតចិត្តភ្លើតភ្លើន ចោលសណ្ដែកច្រើនព្រោះមួយគ្រាប់ ។

ស្វាមួយកំពុងអង្គុយលើប្រគាបឈើក្នុងឧទ្យាន ក្រឡេកទៅឃើញគ្រាប់សណ្ដែកខ្មៅជាច្រើន ដែលព្រះករុណាទ្រង់ឲ្យដាក់ជាចំណីសេះព្រះទី-នាំង ក៏សម្រូតចុះពីមែកឈើ ទៅឆក់យកបានគ្រាប់សណ្ដែកខ្មៅទាំងនោះ ដោយបៀមទុកក្នុងមាត់ផង កាន់នឹងដៃទាំងពីរផង ហើយស្ទុះឡើងទៅអង្គុយលើប្រគាបវិញ ។ កំពុងតែរៀបរេចនឹងស៊ី ជួនជាគ្រាប់សណ្ដែកមួយគ្រាប់ របូតជ្រុះធ្លាក់ពីដៃ, ពានរល្ងង់ ក៏ខ្ជាក់គ្រាប់សណ្ដែកពីមាត់ លែងចោលពីដៃអស់ ហើយហក់សម្រូតចុះមករករើសសណ្ដែកមួយគ្រាប់ ដែលធ្លាក់ពីដៃទៅដីនោះវិញ, តែរាវរកមិនឃើញ! ។ ស្វាកម្សៀត ក៏

ឡើងទៅលើចុងឈើវិញទេ ហើយអង្គុយសំកុកកើតទុក្ខធ្វើមុខស្ងួតហ្មួញ ហាក់ដូចជាបាត់ក្តីអស់ទ្រព្យរាប់ពាន់ ។

ព្រះរាជាទ្រង់ឃើញកិរិយាស្វាដូច្នោះ ក៏ទ្រង់សួរពោធិសត្វថា ហៃបណ្ឌិត! ចូរលោកមើល! ហ្ន៎! ស្វានោះ ម៉េចក៏វាធ្វើមារយាទអ៊ីចឹង? ។ ពោធិសត្វក្រាបទូលថា បពិត្រព្រះនរបតី! ទំនៀមរបស់សត្វល្ងង់ ឥតប្រាជ្ញា មើលប្រយោជន៍ធំពុំឃើញ បែរជាឃើញប្រយោជន៍តូចវិញ តែងតែធ្វើនូវកិរិយាមានសភាពដូច្នេះឯង ។

កល្យាណធម្មវគ្គ

## ១៧- រាជបុត្របួនអង្គ ចង់ស្គាល់ដើមចារ

ការណ៍អ្វីដែលគេដឹងពុំសព្វ ការណ៍នោះតែងជាប់នៅសង្ស័យ
ដូចបុត្របួនអង្គនៃក្សត្រថ្លៃ នាំគ្នាសង្ស័យពីដើមចារ ។

ថ្ងៃមួយ ព្រះរាជបុត្របួនព្រះអង្គចង់ស្គាល់ដើមចារ ក៏ហៅនាយសារថីឲ្យជូនព្រះរាជដំណើរទៅទត ។ នាយសារថី ពុំបាននាំព្រះរាជបុត្រទាំងបួនព្រះអង្គឲ្យទៅទតព្រមគ្នាទាំងអស់អង្គតែមួយលើកទេ គឺលើកទី ១ នាំព្រះរាជបុត្រច្បងឲ្យយាងទៅទតដើមចារក្នុងនិទាឃរដូវ ដែលដើមចារកំពុង

ជ្រុះស្វិតអស់នៅសល់តែដើម ដូចជាដង្កត់ឈើត្រូវភ្លើងឆេះ, លើកទី ២ នាំព្រះរាជបុត្រទី ២ ទៅទៀត ក្នុងរដូវដែលដើមចាកំពុងលាស់ត្រួយជាថ្មី, លើកទី ៣ នាំព្រះរាជបុត្រទី ៣ ទៅទៀត ក្នុងពេលដែលដើមចាបញ្ចេញផ្កាក្រហមឆ្អៅ មើលទៅដូចជាដុំសាច់ស្រស់ប្រឡាក់ដោយឈាម, លើកទី ៤ នាំព្រះរាជបុត្រទី ៤ ទៅទៀត នៅរដូវដែលដើមចាបញ្ចេញផ្លែយោនយោន ។

ថ្ងៃមួយខាងក្រោយមក, ព្រះរាជបុត្រទាំង ៤ ព្រះអង្គ ក៏ទៅអង្គុយជុំគ្នានៅទីកន្លែងមួយ ហើយប្រារព្ធនិយាយពីរឿងដើមចា ។ ព្រះរាជបុត្របង្អស់មានព្រះរាជបន្ទូលថា ដើមចា មានរាងដូចជាឈើដែលត្រូវភ្លើងឆេះ, ព្រះរាជបុត្រទី ២ ថា ដើមចាដូចជាដើមជ្រៃ, ព្រះរាជ-បុត្រទី ៣ ថា ដើមចាដូចជាដុំសាច់ក្រហមឆ្អៅ ហើយព្រះរាជបុត្រទី ៤ មានព្រះរាជបន្ទូលថា ដើមចាមានរាងដូចជាដើមព្រេស ។ លុះជជែកយកត្រូវតែរៀងខ្លួន ពុំដាច់ស្រេច ទើបនាំគ្នាទៅបង្គំទូលសួរព្រះវររាជបិតាឲ្យជួយដោះស្រាយ ។ ព្រះបិតា ទ្រង់សួរពត៌មានសព្វគ្រប់ ទ្រង់យល់ការណ៍ ទើបមានព្រះរាជឱង្ការថា អ្នកពល់គ្នាបានឃើញដើមចាហើយនៅតែសង្ស័យទៀត, នេះ ពីព្រោះតែអ្នកពល់គ្នា មិនបានឲ្យនាយសា-រថីនាំទៅបង្ហាញ ឲ្យគ្រប់ទាំង ៤ រដូវ ។

សិលាវត្ត

# ១៨- អណ្ដើកក្រាញ បំផ្លាញខ្លួន

ទីណានៅបានសេចក្ដីសុខ   ទោះព្រៃឬស្រុកនោះប្រាជ្ញព្រឹទ្ធ
ហៅទីចម្រើនទីកើតពិត   នៃជនអ្នកគិតប្រយោជន៍ខ្លួន ។
គេអាចរស់នៅទីណាបាន   គួរតែនៅឋាននោះមាំមួន
កុំឲ្យឋានដែលធ្លាប់ពឹងពួន   អាចសម្លាប់ខ្លួនអ្នកនៅឡើយ ។

សម័យមួយ ពួកត្រីនិងអណ្ដើកបានដឹងថា ក្នុងឆ្នាំថ្មីនេះ នឹងមានភ្លៀងតិច ក៏នាំគ្នាចេញពីបឹងដែលនៅអាស្រ័យ ទៅនៅក្នុងស្ទឹងទន្លេអស់ ក្នុងពេលដែលទឹកជំនន់កំពុងឡើងជន់រាប នៅសល់តែអណ្ដើកមួយ ដែលក្រាញនៅ ពុំព្រមទៅចុះស្ទឹងទន្លេគេសោះ ដោយមានគំនិតប្រកាន់ថា ទីកន្លែងនេះ ជាភូមិស្រុកកំណើតរបស់អាត្មាអញ ជាទីកន្លែងដែលអញរស់នៅ តាំងពីតូច រហូតមកដល់សព្វថ្ងៃ ហើយជាទីកន្លែងដែលម៉ែឪដីដូនដីតារបស់អញតាំងនៅមកច្រើនតំណហើយ ។ លុះដល់និទាឃរដូវ ទឹកក្នុងបឹង ក៏រីងស្ងួតហួតហែង ។ អណ្ដើកកំព្រា ក៏វារតើមភៅនៅបង្កប់ខ្លួនក្នុងដី ត្រង់ទីកន្លែងដែលព្រះពោធិសត្វតែងមកកាប់កាយយកអាចម៍ដីកិដ្ឋទៅធ្វើក្អមឆ្នាំង ។ លុះព្រឹកឡើង ពោធិសត្វ ក៏លីចបមួយយ៉ាងធំទៅកាប់កាយអាចម៍ដី ។ ទៅដល់ទីនោះ ពោធិសត្វ រៀបចំហើយ លើកចបកាប់ដីយ៉ាងអស់ទំហឹង ស្រាប់តែទៅត្រូវចំខ្នងអណ្ដើក ពុស្ងូរ ប្រឹស! ។ ដោយស្មានថាដុំថ្ម ពោធិសត្វ ក៏កាយទាញចេញមក ។

អណ្តើក បែកស្នូក ឈឺខ្លោចផ្សា ស្រែកយំរៀបរាប់ថា ឱ!អាត្មាអញអើយ! ព្រោះតែហេតុមិនព្រមលះចោលទៅស្រុកកំណើតនេះហើយ ទើបបានជាដល់នូវទុក្ខវេទនា-វិនាសអន្តរាយខ្លួនដូច្នេះ ។

កល្យាណធម្មវិត្ត

# ១៩-សម្លេងប្រាប់មាតា

កូនអើយ! បើអ្នកទៅទីនេះ ត្រូវបេះបៃប្រើសម្លេងតិច
គេនឹងស្គាល់ពូជឯងតុំរំពេច បើអ្នកបញ្ចេញភាសាខ្លួន ។

រាជសីហ៍មួយ ទៅធ្វើសន្ថវៈ(១)ជាមួយនឹងមេចចក បានកូនមួយ ។ កូននោះមានម្រាមជើង ក្រចក រោម សក់ ពណ៌សម្បុរ និងទ្រង់ទ្រាយជារាជសីហ៍សុទ្ធ តែសម្លេងវិញ ដូចសម្លេងចចក ។ ពេលមួយ ក្នុងខណៈដែលភ្លៀងបង្អុរចុះរួចហើយរាំងទៅវិញ ពួកកូនរាជសីហ៍ទាំងឡាយក៏ហក់លោតប្រឡែងគ្នាលេង ព្រមទាំងស្រែកសីហនាទកងរំពង ។ ឯកូនរាជសីហ៍កើតពីមេចចកនោះ ក៏លោតប្រឡែងជាមួយនឹងគេដែរ, លុះត្រូវគេស្រែក ក៏ប្រឹងស្រែកសប្បាយជាមួយនឹងគេ ប៉ុន្តែសម្លេងវា ត្រូវ

១- រួមស្នេហា ។

គ្រលួចដូចជាសម្លេងចចកលូ ។ កូនរាជសីហ៍ឯទៀតឮសម្លេងលូដូច្នោះ កំឈប់ស្ងៀមទាំងអស់គ្នា ។ ពេលនោះ កូនរាជសីហ៍មួយចូលទៅសួរ រាជសីហ៍ជាបិតាថា ពុក ! រាជសីហ៍មួយនេះ រូបរាងដូចគេដែរ ចុះហេតុអ្វី ក៏បានជាសម្រែកឮផ្សេងពីគេ ? ។ រាជសីហ៍បានប្រាប់ថា កូនអើយ ! រាជសីហ៍មួយហ្នឹង វាជាបងប្អូនរួមឈាមនឹងកូនឯងដែរ តែម្ដាយវាជាសត្វចចក បានជារូបរាងវាដូចឪពុក តែសម្លេងវាដូចម្ដាយ ។

រាជសីហ៍បិតា ក៏ហៅកូនរាជសីហ៍ដែលកើតពីមេចចកនោះមកប្រៀនប្រដៅថា ម្នាលកូន ! បើកូនរស់នៅក្នុងចំណោមពួករាជសីហ៍ទាំងនេះដរាបណា, ចូរកូនប្រើសម្ដីឲ្យតិច ដរាបនោះ, បើពុំដូច្នោះទេ ពួកគេនឹងស្គាល់កំណើតរបស់កូនឯងថា " កើតពីមេចចកពុំខាន " ។

អស៊ិសវត្ត

## ២០-កុំអួតដូចត្រី កុំកាត់ក្ដីដូចអរណ្ណិក

យើងសួរហេតុណា អ្នកពុំប្រាប់ បែរជាសារស័ព្ទហេតុទីទៃ
សត្វអួតខ្លួនឯងថាប្រពៃ ខុសអធ្យាស្រ័យពីយើងណាស់ ។

មានត្រីពីរ គឺត្រីមួយឈ្មោះ គង្គា, ត្រីមួយទៀតឈ្មោះ យមនា ។

ថ្ងៃមួយ ត្រីទាំងពីរហែលមកជួបគ្នា ក៏និយាយកក់ទាក់គ្នាយ៉ាងស្និទ្ធស្នាល រួចត្រីគង្ហាចាប់និយាយអួតល្អខ្លួនថា "រូបរបស់ខ្ញុំ ល្អហើយសមជាងអ្នក, រូបអ្នកពុំសូវល្អហើយសមដូចជារូបរបស់ខ្ញុំទេ" ។ ត្រីយមនាទាស់ចិត្តណាស់ ក៏ប្រកែកឡើងថា "មិនមែនខ្ញុំទេ ! រូបទេតើ ដែលល្អហើយសមជាងអ្នក, រូបអ្នកនៅទាស់ចិត្តគេច្រើនណាស់" ។ ដដែក គ្នាពុំដាច់ស្រេច, ត្រីទាំងពីរក៏នាំគ្នាទៅប្តឹងអណ្តើក ដើម្បីឲ្យជួយវិនិច្ឆ័យរកយុត្តិធម៌ ។

រីឯអណ្តើក ក៏កាត់សេចក្តីឲ្យត្រីទាំងពីរថា "បងត្រីគង្ហា ក៏ល្អ, បងត្រីយមនា ក៏ល្អដែរ, ប៉ុន្តែ រូបខ្ញុំវិញ ល្អហើយសមជាងអ្នកទាំងពីរទៅទៀត" ។ ពុំដូច្នោះ ត្រីទាំងពីរក៏កើតក្តៅចិត្តខឹងប្រឡេតតោត ត្អូញដេរប្រទេចអណ្តើកថា "អាសត្វគម្រក់នេះ មិនគិតឆ្លើយនូវពាក្យដែលយើងសួរទេ ត្រឡប់ជានិយាយអួតខ្លួនឯង ដោយពាក្យកំព្រើលផ្សេងទៅវិញ" ។ និយាយហើយ ត្រីទាំងពីរ ក៏វាយកន្ទុយទឹក ឲ្យបាចសាចលើក្បាលអណ្តើក រួចហែលទៅកាន់ទីកន្លែងរៀង ៗ ខ្លួនវិញ ទាំងក្តៅក្រហាយ ។

កល្យាណធម្មវត្ត

# ២១- កុំរសដូចជ្រូក កុំលោភចំណីពិស

កុំឃើញចំណីធំផ្ទិតផ្ទង់ ដែលគេផ្គត់ផ្គង់ឲ្យជ្រូកធី
ថាជាអាហារ ខ្ពស់ពីសី ព្រោះជាចំណីឲ្យឆាប់ងាប់ ។
ចូរអ្នកកុំគិតខ្វល់រើសអើង ស៊ីស្មៅចំបើងតាមទម្លាប់
នេះជាលក្ខណៈប្រសើរគាប់ ឲ្យយើងមានភ័ព្វអាយុវែង ។

គោឈ្មោះចូឡលោហិតជាប្អូន និយាយនឹងគោឈ្មោះមហាលោហិតជាបងថា " បង ! នៅក្នុងត្រកូលម្ចាស់ផ្ទះយើងនេះ បើមានការងារធ្ងន់ៗជាធុរៈកើតឡើង, ម្ចាស់យើង ប្រើតែយើងពីរនាក់ឲ្យដឹកនាំភារៈនោះៗ យ៉ាងនឿយហត់ ហើយឲ្យយើងស៊ីតែស្មៅនិងចំបើង ។ ម្ចាស់យើងបែរជាយកចិត្តទុកដាក់ ចិញ្ចឹមបំប៉នចំណីតែជ្រូកឈ្មោះមុណិក ដែលគ្មានជួយធ្វើការអ្វីសោះ រវល់តែទ្រលទ្រលស៊ីដេកៗនោះ ដោយអាហារដ៏ឆ្ងាញ់ពិសាទៅវិញ, តើហេតុដូចម្តេច បានជាជ្រូកនោះ មានវាសនាខ្ពង់ខ្ពស់ បានចំណីអាហារដ៏ល្អដូច្នេះ ? " ។

គោបងឆ្លើយថា " អូនអើយ ! ចូរអូនកុំពេញចិត្តនឹងអាហារភោជនរបស់ជ្រូកហ្នឹងឡើយ ព្រោះជ្រូកនោះ វាស៊ីមតាហារ (អាហារងាប់) របស់វាទេ, អូនចាំមើលតែដល់ថ្ងៃរៀបការកូនក្រមុំម្ចាស់យើង ក្នុងពេលខាងមុខឆាប់ៗនេះ គេនឹងសំឡេះជ្រូកនេះ ធ្វើជាម្ហូបលៀងភ្ញៀវពុំខាន, ចូរអូនកុំគិតខ្វល់ច្រើន ហើយស៊ីតែស្មៅនិងចំបើងចុះ ព្រោះការស៊ីអាហារ

របៀបនេះ ជាលក្ខណៈឲ្យយើងមានអាយុវែង » ។

ក្បូរគ្គិ

## ២២-ចេះឧបាយ រួចកាយពីទ្រុង

ម្ដេចនឹងសម្រេចគុណវិសេស បើយើងប្រហែសពុំរិះគិត
ចូរអ្នកមើលផលនៃគំនិត ខ្ញុំគិតក៏រួចពីទ្រុងស្លាប់ ។

កាលនោះ ព្រានម្នាក់ចាប់បានចាបជាច្រើនអំពីព្រៃ យកទៅដាក់ទ្រុងទុកឯផ្ទះ សម្រាប់លក់យកកម្រៃចិញ្ចឹមជីវិត ។ បណ្ដាចាបដែលជាប់នៅក្នុងទ្រុងទាំងនោះ មានចាបមួយគិតថា បើអាត្មាអញស៊ីចំណីអាហារ និងផឹកទឹកដែលព្រាននេះដាក់ឲ្យ, ព្រាននេះចាប់អញលក់ឲ្យគេពុំខាន, តែបើអញពុំបរិភោគ, រូបកាយអញ មុខជានឹងស្គាំងស្គម, កាលបើឃើញអញស្គមជាងគេហើយ មុខជាពួកអ្នកទិញ ពុំត្រូវការទិញអញឡើយ ហើយអាត្មាអញនឹងមានឱកាសបានសួស្តីពុំខាន ។

( នៅមានត )

# ផ្នែកកំណត់-ប្រវត្តិការណ៍

## វិជ្ជាអប់រំសុខភាពចំពោះព្រះសង្ឃ

ដោយសារមានបំណងចង់ផ្តល់នូវសុខភាពល្អប្រពៃ ចំពោះព្រះសង្ឃ ព្រមទាំងពុទ្ធបរិស័ទចំណុះជើងវត្ត ឲ្យបានប្រកបតាមអនាម័យ ក្នុងក្បួនវេជ្ជសាស្ត្រសម័យថ្មី, ព្រះរាជរដ្ឋាភិបាល បានបង្កើតការហ្វឹកហ្វឺនវិជ្ជាអប់រំសុខភាពចំពោះព្រះសង្ឃ ដោយក្រសួងសុខាភិបាល និងក្រសួងធម្មការ ធ្វើសហការនិមន្តព្រះសង្ឃដែលគង់នៅវត្តនានា ជាតំណាងអាណាខេត្តក្នុងព្រះរាជាណាចក្រ មកទទួលការអប់រំនេះ នៅក្រុងភ្នំពេញ ក្រោមកិច្ចចាត់ចែងផ្ទាល់នៃក្រសួងសុខាភិបាល ។

ដើម្បីប្រគេន និងជូនជ្រាបអំពីគោលបំណងនិងលទ្ធផលនៃកិច្ចការអប់រំនេះ យើងសូមចុះផ្សាយសុន្ទរកថាពីរ ដែលថ្លែងក្នុងពេលបិទពិធីហ្វឹកហ្វឺនប្រចាំឆ្នាំ ១៩៦៩ដែលទើបតែកន្លងទៅនេះ ។

# សុន្ទរកថា

## បិទសម័យសិក្សាវិជ្ជាអប់រំ
## សុខភាពចំពោះព្រះសង្ឃឆ្នាំ ១៩៦៩
## ថ្លែងដោយនាយកអប់រំសុខភាព

---

សូមពិតទូលថេរដីកាព្រះថេរានុថេរៈគ្រប់ព្រះអង្គ

សូមជម្រាបសហជីវិន តំណាងឯកឧត្តមឧបនាយករដ្ឋមន្ត្រីទី ២

ទទួលបន្ទុកក្រសួងសាធារណសុខាភិបាល

សូមជម្រាបសហជីវិន សហជីវិនី

សូមមានជ្រាប-សូមជ្រាប ៗ

ឱកាសនេះ ជាថ្ងៃប្រារព្ធពិធីបញ្ចប់ ការសិក្សាវិជ្ជាអប់រំសុខភាព ចំពោះព្រះសង្ឃជំនាន់ទី ៦ និងជាឱកាសមួយដ៏ប្រសើរ ដែលខ្ញុំព្រះករុណាខ្ញុំបាទ សូមក្រាបថ្វាយបង្គំ និងសូមថ្លែងអំណរព្រះគុណ ដោយគោរពចំពោះព្រះថេរានុថេរៈគ្រប់ព្រះអង្គ ដែលបានយកព្រះទ័យទុកដាក់ ទំសិក្សានូវវិជ្ជាអប់រំសុខភាព អស់រយៈពេលចំនួន ១ ខែ ៗ

សូមធ្វើគារវកិច្ច និងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះសហជីវិនតំណាងឯកឧត្តមឧបនាយករដ្ឋមន្ត្រីទី ២ ដែលបានអញ្ជើញមកជាអធិបតីនៃពិធីនេះ និងចំពោះសហជីវិនរដ្ឋលេខាធិការ ក្រសួងធម្មការ

ព្រមទាំងចំពោះសហជីវិន.សហជីវិនី ដែលបានអញ្ជើញមកជាកិត្តិយស ក្នុងពិធីនេះ ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ

សហជីវិនតំណាងឯកឧត្តមឧបនាយករដ្ឋមន្ត្រីទី ២

សហជីវិនរដ្ឋលេខាធិការ

សហជីវិន សហជីវិនី

ការសិក្សានូវវិជ្ជាអប់រំសុខភាព របស់ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ដែលបានប្រព្រឹត្តទៅអស់រយៈពេល ១ ខែនេះ គឺបានប្រកបដោយៈជោគជ័យ និងប្រកបដោយសេចក្តីសុខសាន្តល្អណាស់ ។ ខ្ញុំព្រះករុណា ខ្ញុំបាទ ដែលទទួលភារៈជាអ្នករៀបចំ នូវកម្មវិធីសិក្សា សូមសម្តែងនូវសេចក្តីពេញចិត្ត និង សេចក្តីរីករាយយ៉ាងក្រៃលែង ។

មួយផ្នែកទៀត ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមថ្លែងនូវអំណរគុណដ៏លើសលុប ចំពោះសហជីវិនទាំងអស់ ដែលបានទទួលភារៈធ្វើជាសាស្ត្រាចារ្យនៃការសិក្សានេះ ដោយសទ្ធានចិត្តដ៏ស្មោះស្ម័គ្រ ព្រមទាំងបានញ៉ាំងកិច្ចការនេះ ឲ្យបានសម្រេចដូចគោលបំណង ។

បន្ទាប់ពីនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុញ្ញាតពិតទូលថេរដីកា និង សូមជម្រាបបញ្ជាក់អំពីចំនួនព្រះសង្ឃ ដែលបាននិមន្តមកពីខេត្តនានា

ក្នុងព្រះរាជាណាចក្រ មកទទួលទូវវិជ្ជាឈប់សុខភាពក្នុងពេលនេះ ដូចតទៅ ៖

ក្រុងភ្នំពេញ

-គណៈមហានិកាយ ៥ អង្គ

-គណៈធម្មយុត្តិកនិកាយ ៣ អង្គ

ខេត្តនានា

-គណៈមហានិកាយ ៦៥ អង្គ

-គណៈធម្មយុត្តិកនិកាយ ២៧ អង្គ

រួមទាំងអស់ ទាំងពីរគណៈត្រូវជា ១០០ អង្គ ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ

នៅថ្ងៃបញ្ចប់ការសិក្សានេះ តាមទម្លាប់ដែលបានធ្វើរួចមកហើយ ក្រសួងសាធារណសុខាភិបាល តែងប្រគេនទូវវិញ្ញាបនប័ត្រ ១ សន្លឹកមួយអង្គ ដើម្បីជាការបញ្ជាក់ទូវចំណេះវិជ្ជាឈប់សុខភាព ដែលព្រះថេរានុថេរៈគ្រប់ព្រះអង្គបានសិក្សា ។ នៅក្នុងពេលនេះ ក៏មានការប្រគេនទូវវិញ្ញាបនប័ត្រ ដូចពេលមុនៗដែរ ដែលព្រះថេរានុថេរៈគ្រប់ព្រះអង្គ នឹងបានទទួលពីសហជីវិនតំណាងឯកឧត្តមឧបនាយករដ្ឋមន្ត្រីទី ២ ក្នុងពេលបន្តិចទៀតនេះ ។

# សុន្ទរកថា
## បិទសម័យសិក្សាវិជ្ជាអប់រំ
## សុខភាព ចំពោះព្រះសង្ឃ ឆ្នាំ ១៩៦៩
## ថ្លែងដោយតំណាង ឧបនាយករដ្ឋមន្ត្រីទី ២
## ទទួលបន្ទុកក្រសួងសុខាភិបាល

---

សូមលំទុនកាយក្រាបថ្វាយបង្គំដោយគោរព ចំពោះព្រះថេរានុថេរៈ គ្រប់ព្រះអង្គ,

សូមគោរពសហជីវិន រដ្ឋលេខាធិការ ក្រសួងធម្មការ,

សូមជំរាបសហជីវិន-សហជីវិនី,

សហជីវិនឧបនាយករដ្ឋមន្ត្រីទី ២ ទទួលបន្ទុកក្រសួងសាធារណសុខាភិបាល មានកិច្ចរវល់ជាបន្ទាន់ មានសេចក្តីស្តាយជាអនេក ដោយពុំបានអញ្ជើញមកផ្ទាល់ ដើម្បីជាអធិបតី នៃពិធីបិទសម័យសិក្សាវិជ្ជាអប់រំសុខភាព ចំពោះព្រះសង្ឃនាពេលនេះ ៗ សហជីវិនឧបនាយករដ្ឋមន្ត្រីទី ២ បានឲ្យខ្ញុំព្រះករុណា ខ្ញុំបាទមកជាតំណាងក្នុងពេលនេះ ៗ

នៅក្នុងឱកាសដ៏ប្រសើរនេះ, ខ្ញុំព្រះករុណា-ខ្ញុំបាទ, តាងនាមនៃសហជីវិនឧបនាយករដ្ឋមន្ត្រីទី ២, សូមថ្វាយជាបឋម នូវអំណរព្រះគុណ និង អំណរគុណដ៏ជ្រាលជ្រៅ ចំពោះព្រះថេរានុថេរៈគ្រប់ព្រះអង្គ និង

ចំពោះសហជីវិន-សហជីវិនី ដែលបាននិមន្ត និង អញ្ជើញមកជួបជុំនៅក្នុងពិធីបិទសម័យសិក្សាវិជ្ជាអប់រំសុខភាពនាពេលនោះ ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ

ការសិក្សា នូវវិជ្ជាអប់រំសុខភាព ឬ ហៅថា វិធីអនាម័យ ដែលព្រះថេរានុថេរៈគ្រប់ព្រះអង្គ បានយកព្រះទ័យទុកដាក់ខំសិក្សាដោយម៉ឺងម៉ាត់ អស់រយៈកាលចំនួនជា ១ ខែនេះ បានធ្វើឲ្យក្រសួងសាធារណសុខាភិបាលទាំងមូល មានសេចក្ដីពេញចិត្តជាអតិបរមា ។

ការសិក្សា នូវវិជ្ជានេះ បើពិចារណាឲ្យល្អិតល្អន់បន្តិច ឃើញថា មានន័យទូលំទូលាយណាស់ ព្រោះវិជ្ជាអប់រំសុខភាព ឬ ហៅថា វិធីអនាម័យនេះ ជាមូលដ្ឋាននៃសុខភាពទៅនៃមនុស្សយើង ហើយតម្លៃនៃសុខភាពនេះសោត ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ក៏សុទ្ធតែបានជ្រាបរួចហើយថា មនុស្សយើងគ្រប់រូប ដែលនឹងធ្វើកិច្ចការអ្វីមួយ ឲ្យបានសម្រេចទៅ កើតលុះតែរូបកាយមានសុខភាពមាំមួន ទោះជាធ្វើសកម្មក្ដី ធ្វើជំនួញក្ដី ឬ ធ្វើសមាធិកម្មដ្ឋានក្ដី ។

នៅក្នុងចំណុចនេះ ប្រទេសកម្ពុជា ឯករាជ្យអព្យាក្រឹត្យ ដែលកំពុងតែធ្វើដំណើរយ៉ាងលឿន និង យ៉ាងស្វាហាប់ក្នុងផ្លូវចម្រើន ក្រោមព្រះមគ្គាបាយដឹកនាំដ៏ត្រចះ នៃសម្ដេចសហជីវិនព្រះប្រមុខរដ្ឋជាទីស្នេហាដ៏ខ្ពង់ខ្ពស់ស្មើដោយជីវិតនៃយើង ដើម្បីឈានទៅកាន់សេចក្ដីថ្កុំថ្កើ-

ចំរើនរុងរឿងដូចសម័យអង្គរនោះ បានពឹងផ្អែកជាចាំបាច់ទៅលើសុខភាពនៃប្រជាពលរដ្ឋ ។ ដោយហេតុយ៉ាងនេះហើយ បានជានៅក្នុងសម័យសង្គមនិយមព្រះពុទ្ធសាសនាយើងនេះ ក្រសួងសាធារណសុខាភិបាលបានបង្កើត និង ពង្រីកយ៉ាងខ្លាំង នូវវិធានការការពារជម្ងឺ, ការពាររោគធ្ងន់ ឬ រោគកាចត្បាតនានា កុំឲ្យប៉ះពាល់មកលើពលរដ្ឋរបស់យើងតាំងពីបឋមវ័យរហូតដល់មជ្ឈិមវ័យ ។

ពិតមែនហើយថា មនុស្សគ្រប់រូប ដែលកើតមកលើពិភពលោកយើងនេះ គ្មានអ្នកណាម្នាក់អាចគេចឲ្យផុតពីជម្ងឺ ឬ ពីរោគនានាបានក៏ប៉ុន្តែ បើយើងប្រៀបធៀបពីសម័យមុន និង សម័យសព្វថ្ងៃនេះឃើញថា សម័យសព្វថ្ងៃប្រជាពលរដ្ឋយើង មានសុខភាពដ៏បរិបូណ៌ ជាងពីដើមឆ្ងាយណាស់ ហើយរោគកាចត្បាតទៀតសោត ក៏បានអន់ថយជាលំដាប់ដែរ ។ នេះ គឺមកពីវិធានការ ការពារដ៏ម៉ឺងម៉ាត់ របស់ក្រសួងសាធារណសុខាភិបាលយើង ហើយប្រជាពលរដ្ឋទៀតសោតក៏បានយល់ ព្រមទាំងបានប្រព្រឹត្តតាមវិធីអនាម័យ កាន់តែក្រាស់ក្រែលដែរហើយ ។

ចំពោះជនខ្លះ ដែលត្រូវជម្ងឺ ឬ ត្រូវរោគបៀតបៀន ដោយមកពីខ្វះវិធីអនាម័យសម្រាប់ជារបងការពារ ឬ ក៏ការពារពុំឈ្នះខ្លះនោះ ក៏ត្រូវបានក្រសួងសាធារណសុខាភិបាលដោយរួបរួមជាមួយព្រះសង្ឃ និង

ប្រជាពលរដ្ឋគ្រប់ឋានៈ បង្កើតមន្ទីរពេទ្យ, មណ្ឌលសុខភាព និងកិ-លានដ្ឋានយ៉ាងច្រើនដេរដាស នៅក្នុងព្រះរាជាណាចក្រ ដើម្បីនឹងព្យា-បាលជម្ងឺនៃជននោះ ៗ ឲ្យជាសះស្បើយឡើងវិញយ៉ាងឆាប់រហ័ស ។

សារុបសេចក្ដីទៅ វិធានការទាំងពីរ ឬ កងទាំងពីរ គឺកិច្ចការពាររោគ និង កិច្ចព្យាបាលរោគ ត្រូវតែរិលទៅជាមួយគ្នា ទើបយើងមានប្រសិទ្ធភាព ក្នុងការស្វែងរកនូវសុខភាព ជូនប្រជាពលរដ្ឋរបស់យើងៗ វិធានការទាំងពីរនេះ ពិតមែនតែសព្វថ្ងៃ មានល្បឿនជឿនលឿនគួរឲ្យពេញចិត្ត និង គួរឲ្យកក់ក្ដៅ តែការនេះគ្មានទីបំផុតឡើយ ។ ដោយហេតុយ៉ាងនេះ ហើយបានជាក្រសួងនេះតែងពង្រីក នូវមធ្យោបាយផ្សេង ៗ តទៅទៀត ដូចជាការនិមន្តព្រះសង្ឃពីខេត្តនានា មកសិក្សានូវវិជ្ជាអប់រំសុខភាពជាដើម ដែលបានប្រព្រឹត្តទៅចំនួន ៦ លើកហើយ ដោយរាប់ទាំងលើកនេះផង ដែលបូករួមព្រះសង្ឃទាំងអស់ មានចំនួន ៣៣៣ អង្គ ។

ការនិមន្តព្រះសង្ឃមកសិក្សា នូវវិជ្ជាអប់រំសុខភាពបែបនេះ ពុំមែនមានន័យថា ព្រះសង្ឃ លោកមិនយល់ មិនស្គាល់ នូវវិធីអនាម័យនោះទេ, តាមពិត គឺព្រះសង្ឃលោកបានចេះ-ដឹងយ៉ាងពិតប្រាកដ តាមក្បួនច្បាប់នៃព្រះពុទ្ធសាសនា ព្រមទាំងបានប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនផង ដូចជាការសំអាតស្បង់ចីពរ, ការសំអាតចង្ហាន់, ការកាត់ក្រចក និង

ការដោះទុក្ខសត្វក្នុងបង្គន់ជាដើមដែលសុទ្ធតែជាវិធីអនាម័យ ក្នុងកិច្ចការ-ពារពេត ៗ ដូច្នេះការដែលនិមន្តព្រះសង្ឃមកសិក្សានេះ គ្រាន់តែបំពេញទៅតាមលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ ៗ

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ

ដូចសេចក្តីដែលខ្ញុំព្រះករុណាបានធ្វើអត្ថាធិប្បាយខ្លីៗមកនេះ អំពីគុណប្រយោជន៍ និង អំពីគោលដៅនៃការសិក្សានោះ ខ្ញុំព្រះករុណាក្នុងនាមនៃក្រសួងសាធារណសុខាភិបាលទាំងមូល សូមពឹងផ្អែកលើព្រះតេជព្រះគុណគ្រប់ព្រះអង្គ សូមមេត្តាជួយផ្សព្វផ្សាយនូវវិធីអនាម័យ ដែលព្រះតេជព្រះគុណបានសិក្សានេះ ឲ្យបានជ្រួតជ្រាបទៅដល់ប្រជាពលរដ្ឋទូទៅ ដែលជាពុទ្ធបរិស័ទឲ្យបានផង តាមលទ្ធភាព និងតាមកាលៈទេសៈដែលអាចធ្វើទៅបាន ៗ ខ្ញុំព្រះករុណាមានសេចក្តីសង្ឃឹមកក់ក្តៅខ្លាំងណាស់លើព្រះតេជព្រះគុណគ្រប់ព្រះអង្គ ក្នុងការជួយផ្តល់និងពង្រីកនូវសុខភាព ឲ្យមានបរិបូណ៌ដល់ប្រជាពលរដ្ឋទូទៅ ព្រោះព្រះអង្គជាប់ជាមគ្គុទេសក៍ស្រាប់ក្នុងការពន្យល់ បំភ្លឺ . ណែនាំពុទ្ធបរិស័ទ ឲ្យដើរទៅក្នុងផ្លូវត្រូវ - ផ្លូវសុខ - ផ្លូវចម្រើន តាមព្រះមាគ៌ានៃព្រះសម្មាសម្ពុទ្ធ ព្រះបរមគ្រូជាអម្ចាស់ ចំពោះផ្នែកពុទ្ធចក្រ និងតាមព្រះមាគ៌ានៃសម្តេចសហជីវិនព្រះប្រមុខរដ្ឋ ចំពោះផ្នែកអាណាចក្រ សឹងមានសមិទ្ធិជាកស្តុតាងយ៉ាងច្រើនដេរដាស នៅក្នុងព្រះរាជាណាចក្រទាំងមូលស្រាប់ ៗ

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ

សហជីវិន - សហជីវិនី

មុននិងបញ្ចប់នូវសុន្ទរកថានេះ ខ្ញុំព្រះករុណា - ខ្ញុំបាទ សូមយកពេលដ៏ខ្លីនេះ សម្តែងនូវសេចក្តីពេញចិត្ត និងអំណរព្រះគុណ អំណរគុណដ៏ខ្លាំងក្លា ចំពោះព្រះថេរានុថេរៈគ្រប់ព្រះអង្គដែលបាននិមន្តមកពីគ្រប់ជិតឆ្ងាយ មកទទួលនូវវិជ្ជាអប់រំសុខភាពនាពេលនេះ ចំពោះសហជីវិននាយកអប់រំសុខភាព ដែលបានយកចិត្តទុកដាក់ខំរៀបចំកម្មវិធីសិក្សាឲ្យបានប្រសើរ និងចំពោះសហជីវិនទាំងអស់ដែលបានទទួលភារៈមកធ្វើជាសាស្ត្រាចារ្យនៃការសិក្សានេះ ប្រកបដោយសន្ដានចិត្តដ៏ស្មោះស្ម័គ្រ និងប្រកបដោយលទ្ធផលដ៏ល្អប្រពៃ ។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណអំណរគុណអតិបរមា ចំពោះអង្គការមូលនិធិអន្តរជាតិសង្គ្រោះកុមារ ( UNICEF ) ដែលបានធ្វើភាគទានដ៏ថ្លៃថ្លារៀងរាល់ឆ្នាំជាសម្ភារៈខ្លះ ជាបច្ច័យខ្លះ ដើម្បីឲ្យក្រសួងអាចញ៉ាំងកម្មវិធីសិក្សានេះ ឲ្យបានសម្រេចដូចគោលបំណង ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា - ខ្ញុំបាទ សូមឧទ្ទិសចំពោះគុណបុណ្យព្រះរតនត្រ័យ និង ព្រះបារមីនៃព្រះមហាក្សត្រទាំងឡាយមានព្រះបារមីនៃព្រះករុណាព្រះសុវណ្ណកោដជាប្រធាន សូមមេត្តាប្រសិទ្ធពរជ័យ ប្រគេន និង ជូនចំពោះព្រះថេរានុថេរៈគ្រប់ព្រះអង្គ, ចំពោះសហជីវិន-សហជីវិនី

ជាសហការីទាំងអស់ ដែលបានជួយឧបត្ថម្ភការសិក្សានេះ ឲ្យបានសម្រេចជោគជ័យ និង ចំពោះសហជីវិន-សហជីវិនីទាំងអស់ ដែលបានអញ្ជើញមករួបរួមកងពិធីនេះ សូមបានប្រកបដោយសុខសួស្តីសិរីមង្គលវិបុលសុខគ្រប់ប្រការជានិរន្តរតទៅ ។

ជាពិសេស ខ្ញុំព្រះករុណា-ខ្ញុំបាទ ជាមួយនឹងព្រះថេរានុថេរៈគ្រប់ព្រះអង្គ ព្រមទាំងសហជីវិន សហជីវិនីទាំងអស់ សូមមេត្តាគាំងហប្ញទ័យ-តាំងចិត្តប្រមូលផ្តុំនូវបុញ្ញរាសី ដែលកើតមកអំពីកិច្ចការជាកុសលនេះ ឧទ្ទិសថ្វាយជាព្រះរាជកុសលចំពោះព្រះវិញ្ញាណក្ខន្ធ នៃសម្តេចព្រះសង្ឃរាជ ថ្នាក់ទី ១ និងថ្នាក់ទី ២ ដែលព្រះអង្គមានព្រះមហាករុណាទិគុណដ៏ធំធេងមកលើកិច្ចការនេះ ដោយព្រះអង្គទ្រង់សព្វព្រះរាជហប្ញទ័យ ជួយឧបត្ថម្ភតាំងពីដើមទីមកនោះ សូមព្រះអង្គទ្រង់សោយតែសម្បត្តិសួគ៌ និងសម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។